# ភូរិទត្តជាតក



នេះកាលព្រះភូរិទត្តនាគរាជអធិដ្ឋានឧបោសថសីល
ត្រូវព្រាហ្មណ៍អាលម្ពាយចាប់ធ្វើបាប

ដឹកនាំការរៀបរៀងដោយ
ខ្ញុំព្រះករុណាខ្ញុំបាទ

**ភុល ផេង**

**ព.ស. ២៥៦៣**

## **គម្ពីរទេសជាតកពិស្ដារ**

## **អធិបតីក្នុងការរៀបរៀង**
**បណ្ឌិត ក្ងុល ផេង**

*ប្រធានសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

*និងជាប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

## **អ្នកបកប្រែពីអដ្ឋកថាភាសាបាលី**

*លោក* **គង់ សំអឿន** *និស្សិតសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

## **ក្រុមជំនុំពិនិត្យ**

*បណ្ឌិត* **ក្ងុល ផេង** *ប្រធាន*

*ព្រះធម្មឃោសាចារ្យ* **ឃី សុវណ្ណរតនា**

*ព្រះញាណកោសល* **យ៉ន សេងយៀត**

*ព្រះភិក្ខុ វជិរប្បញ្ញោ* **គូ សុភាព**

*ព្រះភិក្ខុ កិត្តិបាលោ* **ពេញ វិបុល**

*បណ្ឌិត* **ប៉ក់ ថាវិន**

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *អគ្គលេខាធិការពុទ្ធិកបណ្ឌិតសភា*

*ព្រឹទ្ធាចារ្យ* **ដាំ កុយ**

*លោក* **លឹម លឿម**

*លោក* **ដុង សុភឿន**

*លោក* **ទិព្វ សៅ**

*លោក* **សំណាង សំណាក់**

*លោក* **ស៊ន់ គឹមឈន់**

*លោក* **ប៉ាល់ ចំរើន**

*លោក* **ហ៊ុន ពិសេស**

*លោក* **ហន សុខេមនុ** *លេខាធិការ*

## ក្រុមបច្ចេកទេស និងរចនា

*លោក* **អ៊ុន ស៊ីយ៉ុន្ដា** *ប្រធាន*

*លោក* **ម៉ម ម៉ានិត** *អនុប្រធាន*

*លោក* **យុន សុវណ្ណរិទ្ធិ** *វិចិត្រករ សមាជិក*

## រចនាសម្ពន្ធពុទ្ធិកបណ្ឌិតសភា
## នៃសាកលវិទ្យាល័យបញ្ញាសាស្ដ្រកម្ពុជា
## ក្រុមប្រឹក្សាភិបាល និងស្ថាបនិក

*បណ្ឌិត* **ករុល ផេង** *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*ព្រះធម្មឃោសាចារ្យ* **ឃី សុវណ្ណរតនា** *អនុប្រធាន*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *សមាជិក*

*ព្រះមហា* **សុន្ទរ៍ សារមៀន** *សមាជិក*

*ព្រះមហា* **គូ សុភាព** *សមាជិក*

*បណ្ឌិត* **ជា សានចាន់ថន** *សមាជិក*

*បណ្ឌិត* **ប៉ក់ ថាវិន** *សមាជិក*

*សាស្ដ្រាចារ្យ* **ម៉ក់ វ៉ាន់** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ហេង គឹមហោ** *សមាជិក*

*សាស្ត្រាចារ្យ* **រស់ សារេវន** *សមាជិក*

*សាស្ត្រាចារ្យ* **ជិត ជន** *សមាជិក*

*សាស្ត្រាចារ្យ* **ជា ត្រិស្នា** *សមាជិក*

*សាស្ត្រាចារ្យ* **អ៊ុំ សុវណ្ណា** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ដាំ កុយ** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *អគ្គលេខាធិការ*

## ក្រុមជំនុំប្រតិបត្តិ

*បណ្ឌិត* **កុល ផេង** *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*ព្រះញាណវង្ស* **ឃឹម សន** *ឧត្តមប្រឹក្សាពុទ្ធិកបណ្ឌិតសភា*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *អនុប្រធាន*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *អគ្គលេខាធិការ*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *ប្រធានគណៈកម្មការត្រួតពិនិត្យ*

*ព្រះមហា* **គូ សុភាព** *ប្រធានគណៈកម្មការបច្ចេកទេស*

*លោក* **ហ៊ាត ណាហំ** *ប្រធានរដ្ឋបាល*

*លោក* **ហាន សុខេមន្ទ** *សមាជិកគណៈកម្មការបច្ចេកទេស*

## ក្រុមជំនុំអប់រំសីលធម៌ និងស្រាវជ្រាវអក្សរសិល្ប៍

*បណ្ឌិត* **កុល ផេង** *អធិបតីក្រុមជំនុំ*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *សមាជិក*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *សមាជិក*

*ព្រះមហា* **ពេញ វិបុល** *សមាជិក*

*ព្រះមហា* **គូ សុភាព** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *សមាជិក*

*លោក* **ហ៊ាត ណាហាំ** *សមាជិក*

*លោក* **គង់ សំអឿន** *សមាជិក*

## ក្រុមជំនុំផ្សាយព្រះធម៌ និងភាសាបាលី

*លោកគ្រូ ធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *ប្រធាន*

*ព្រះមហា សក្យមុនីបុត្តោ* **ជា សុមាលា** *សមាជិក*

*លោក* **ហ៊ាត ណាហាំ** *សមាជិក*

*លោក* **ចាន់ ហួរ** *សមាជិក*

*លោក* **ហួយ វ៉ាន់ថន** *សមាជិក*

*លោក* **សំ សុផល** *សមាជិក*

## ក្រុមជំនុំពិនិត្យ និងបោះពុម្ពផ្សាយសៀវភៅធម៌

*ព្រះញាណកោសល* **យ៉ន សេងយៀត** *ប្រធាន*

*ព្រះមហា* **គូ សុភាព** *អនុប្រធានទី ១*

*លោក* **គង់ សំអឿន** *អ្នកបកប្រែពីភាសាបាលី អនុប្រធានទី ២*

*ព្រះមហា* **ពេញ វិបុល** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ដាំ ភុយ** *សមាជិក*

*ធម្មាចារ្យ* **ហ៊ាត ណាហាំ** *សមាជិក*

*លោក* **លឹម ល្មឿម** *សមាជិក*

*លោក* **សំណាង សំណាក់** *សមាជិក*

*លោក* **ដុខ សុភឿន** *សមាជិក*

*លោក* **ហ៊ុន ពិសេស** *សមាជិក*

*លោក* **ស៊ន់ គឹមឈយន់** *សមាជិក*

# សូមថ្វាយព្រះរាជកុសល
# ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង
# ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
# ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
# ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត

## *បពិត្រព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង*

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់ និងភរិយាព្រមទាំងបុត្រ សូមលំឱនកាយក្រាបថ្វាយបង្គំទូលថ្វាយ ព្រះសព្ទសាធុការពរបវរមហាប្រសើរ និងប្រកបដោយសិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការ ថ្វាយ* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។*

*ទូលព្រះបង្គំជាខ្ញុំសូមថ្វាយព្រះរាជកុសល ដែលទូលព្រះបង្គំជាខ្ញុំបានដឹកនាំរៀបរៀងនូវសៀវភៅ "***គូរិទត្តជាតកពិស្តារ***" តម្កល់ទុកក្នុងព្រះពុទ្ធសាសនា ។ បពិត្រ* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** *សូម* **ព្រះករុណាជាអម្ចាស់** *អនុមោទនានូវមហា*

*កុសល ដោយព្រះរាជហឫទ័យដ៏ខ្ពង់ខ្ពស់បំផុត ។ សូមឧទ្ទិសចំពោះបារមីនៃព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គដែលបានត្រាស់កន្លងមកក្នុង ហើយនឹងត្រាស់ដឹងក្នុងអនាគត និងដោយអំណាចគុណបុណ្យព្រះរតនត្រ័យ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និងបារមី នៃអតីតៈព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី គ្រប់ព្រះអង្គ ព្រមទាំងវត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោក សូមជួយអភិបាលថែរក្សា* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះបាទសម្តេច ព្រះបរមនាថនរោត្តម សីហមុនី** *ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គទ្រង់ មានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះជន្មយឺនយូរ ព្រះបញ្ញាញាណវាងវៃ និងគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ ប្រជារាស្ត្រ ដើម្បីទទួលបាននូវសេចក្តីសុខក្សេមក្សាន្ត ចម្រើនរុងរឿង ជានិច្ចនិរន្តរ៍តរៀងទៅ ។*

*សេចក្តីគួរពុំគួរ សូម* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ដោយព្រះរាជហឫទ័យអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត ។*

*ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ,*

*ថ្ងៃ ៩ កើត ខែអស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨*

**កុល ផេង**

**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

## សូមថ្វាយព្រះរាជកុសល
## សម្តេចព្រះមហាក្សត្រ នរោត្តម មុនីនាថ សីហនុ
## ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត

### *បពិត្រសម្តេចព្រះមហាក្សត្រជាអម្ចាស់ជីវិតតម្កល់លើត្បូង*

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់ និងភរិយាព្រមទាំងបុត្រ សូមលំឱនកាយក្រាបថ្វាយបង្គំទូលថ្វាយ ព្រះសព្ទសាធុការពរបវរមហាប្រសើរ និងប្រកបដោយសិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការ ថ្វាយ* **សម្តេចព្រះមហាក្សត្រ នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។*

*ទូលព្រះបង្គំជាខ្ញុំសូមថ្វាយព្រះរាជកុសល ដែលទូលព្រះបង្គំជាខ្ញុំបានដឹកនាំរៀបរៀងនូវសៀវភៅ "***ត្រូវិទត្តជាតកពិស្តារ***" តម្កល់ទុកក្នុងព្រះពុទ្ធសាសនា ។ បពិត្រសម្តេចព្រះមហាក្សត្រ ជាអម្ចាស់ជីវិតតម្កល់លើត្បូង សូមទ្រង់អនុមោទនានូវមហាកុសលដោយ ព្រះរាជហឫទ័យដ៏ខ្ពង់ខ្ពស់បំផុត ។ សូមឧទ្ទិសចំពោះ បារមីនៃព្រះសម្មាសម្ពុទ្ធ*

គ្រប់ព្រះអង្គដែលបានគ្រាស់កន្លងមកក្នុង ហើយនឹងត្រាស់ដឹងក្នុង អនាគត និងដោយអំណាចគុណបុណ្យ ព្រះរតនត្រ័យ ទេវតាថែរក្សា ព្រះមហាស្វេតច្ឆត្រ និងបារមី នៃអតីតៈព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី គ្រប់ព្រះអង្គ ព្រមទាំងវត្ថុសក្តិសិទ្ធិទាំងឡាយ ក្នុងលោក សូមជួយអភិបាលថែរក្សា **សម្តេចព្រះមហាក្សត្រ នរោត្តម សីហមុនី ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និង សុភមង្គល** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គ ទ្រង់មានព្រះរាជ-សុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះជន្ម យឺនយូរ ព្រះបញ្ញាញាណវាងវៃ និងគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ ប្រជារាស្ត្រ ដើម្បីទទួលបាននូវសេចក្តីសុខក្សេមក្សាន្ត ចម្រើនរុងរឿង ជានិច្ចនិរន្តរ៍តរៀងទៅ ។

សេចក្តីគួរពុំគួរ សូម **សម្តេចព្រះមហាក្សត្រ** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ដោយព្រះរាជ-ហឫទ័យអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត ។

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ,

ថ្ងៃ ៩ កើត ខែអស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨

**គុល ផេង**

**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# សូមគោរពជូនមហាកុសល
# សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## *សម្ដេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់*

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់ និងភរិយាខ្ញុំបាទ សូមគោរពជូនបុណ្យកុសល និងសព្ទសាធុការពរ បវរមហាប្រសើរ សិរីសួស្តីជយមង្គល វិបុលសុខគ្រប់ប្រការជូនចំពោះ* **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** *និង* **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** *ជាទីគោរពដ៏ខ្ពង់ខ្ពស់ ។*

*ខ្ញុំបាទសូមគោរពជូនមហាកុសល ដែលខ្ញុំបាទបានដឹកនាំការរៀបរៀងចងក្រងនូវសៀវភៅ "***តួរិទត្តជាតកពិស្តារ***" តម្កល់ទុកក្នុងព្រះពុទ្ធសាសនានេះ ។ សូម* **សម្ដេច** *និង* **លោកជំទាវ** *មេត្តាទទួលអនុមោទនានូវមហាកុសលនេះ ។ ដោយតេជះគុណានុភាពនៃព្រះរតនត្រ័យ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ វត្ថុសក្តិសិទ្ធិ ក្នុងលោក សូមជួយបីបាច់ថែរក្សានិងប្រសិទ្ធិពរជ័យជូន* **សម្ដេច** *និង* **លោកជំទាវ** *ព្រមទាំង* **បុត្រាបុត្រី** *និង* **ចៅ** *ៗ ជាទីស្រឡាញ់របស់* **សម្ដេច**

*សូមមានសុខភាព ល្អបរិបូណ៌ ជន្មាយុយឺនយូរ បញ្ញាញាណវាងវៃ ដើម្បីដឹកនាំប្រទេសជាតិ ឆ្ពោះទៅរកត្រើយសុខសន្តិភាព និងការអភិវឌ្ឍឲ្យសម្បូរសប្បាយ រុងរឿងជានិច្ចនិរន្តរ៍តរៀងទៅ ។*

*ខ្ញុំបាទសូមកោតសរសើរដោយសុទ្ធចិត្តនូវវិរិយភាពដ៏អង់អាចរបស់* **សម្តេច** *ដែលបានបំពេញនូវបេសកកម្មដ៏លំបាក ក្នុងការស្វែងរកសេចក្តីសុខជូនចំពោះប្រជាពលរដ្ឋ និងការអភិវឌ្ឍក្នុងព្រះរាជាណាចក្រកម្ពុជាយើង នាំមកនូវភាពចម្រើនរុងរឿង នាសម័យបច្ចុប្បន្ននេះ និងក្នុងអនាគតកាល ។*

*សូម* **សម្តេចអគ្គមហាសេនាបតីតេជោ** *និង* **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** *ប្រកបដោយសិរីមង្គល វិបុលសុខមហាប្រសើរ ព្រមទាំងទទួលបាននូវធម៌ដ៏ប្រសើរទាំង ៥ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។*

*រាជធានីភ្នំពេញ,*

*ថ្ងៃ ៩ កើត ខែ អស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨*

**កុល ផេង**
**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**
**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

## បុព្វកថា

*រឿងកូវិទត្តនេះ គឺជាជាតកមួយក្នុងមហាទសជាតក៏ ដែលមានប្រភពដើមជាភាសាបាលីនៃគម្ពីរអដ្ឋកថា ។ យើងដឹងហើយថា នៅប្រទេសកម្ពុជាយើងបច្ចុប្បន្ននេះ មានអ្នកចេះភាសាបាលីជាស្ពានសម្រាប់ឆ្លងទៅស្វែងយល់នូវពុទ្ធវាទជាភាសាបាលីនេះ មានចំនួនតិចតួច ។ បើទុករឿងក្នុងជាតកទាំងអស់ឲ្យនៅជាភាសាបាលី ដូច្នេះជាឧបសគ្គដ៏ធំសម្រាប់អ្នកសិក្សាភាគច្រើន រួមទាំងសិស្ស និស្សិត និងបញ្ញវន្តទាំងអស់ដែលមិនបានសិក្សាភាសាបាលី ។ ម្យ៉ាងវិញទៀត ប្រទេសកម្ពុជាយើង ក៏ធ្លាប់មានសៀវភៅសង្ខេបទសជាតក ដែលប្រែ និងរៀបរៀងដោយលោក* **ឈឹម ស៊ុម** *កាលពីឆ្នាំ ១៩៥៩ មួយក្បាលគ្រប់ទាំង ១០ រឿងរួចមកហើយឃើញថា មានសេចក្តីសមល្មមគ្រប់គ្រាន់សម្រាប់ពុទ្ធសាសនិកជនសម័យនោះសិក្សារៀនសូត្រ តែមកដល់សម័យបច្ចុប្បន្ននេះ រឿងសង្ខេបទសជាតកនោះ មិនទាន់ឆ្លើយតបល្មមដល់តម្រូវការនៃការស្រាវជ្រាវរបស់សិស្ស និស្សិត បញ្ញវន្ត និងពុទ្ធសាសនិកនៅឡើយ ។*

*សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា មើលឃើញពីតម្រូវការនេះ ថាជាការចាំបាច់បំផុតក្នុងការចូលរួមចំណែកជួយអប់រំសង្គម ទើបខ្នះខ្នែង ចាត់ចែង រៀបចំបកប្រែ និង រៀបរៀងកូវិទត្តជាតកនេះ*

ម្តងទៀត ឲ្យមានសេចក្តីពិស្តារ តាមច្បាប់ដើមក្នុងអដ្ឋកថា ជាភាសាបាលី ក្នុងគោលបំណងជួយបំពេញបន្ថែមដល់ការសិក្សាស្រាវជ្រាវរបស់ សិក្ខាកាមគ្រប់កម្រិតនិងដល់ពុទ្ធបរិស័ទគ្រប់រូប ។

ការរៀបរៀងសៀវភៅនេះ ដំបូងយើងប្រែពីភាសាបាលីមកជាភាសាខ្មែរ បន្ទាប់មក យើងចាប់ពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ ដោយប្រើសំនួនវោហារតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជ ជួន-ណាត ជោតញ្ញាណោ ជាគោល ។ ខ្លឹមសារសេចក្តី យើងប្រើពាក្យពាយសាមញ្ញ ងាយអាន ងាយស្តាប់ ងាយយល់ ដល់អ្នកសិក្សាគ្រប់កម្រិត ។ ម្យ៉ាងទៀត ពាក្យពិបាកខ្លះដែលជាប់ដោយភាសាបាលី ដែលខ្មែរយកមកប្រើជារាជសព្ទ និងសង្ឃសព្ទ យើងមិនអាចចៀសវាងបាន ក៏ត្រូវរក្សាទុក ដោយដាក់លេខយោងពន្យល់នៅផ្នែកខាងក្រោមនៃទំព័រ ។

ពាក្យពេចន៍ អក្ខរាវិរុទ្ធ ឃ្លា ល្បះ និងខ្លឹមសារសេចក្តីក្នុងសៀវ-ភៅនេះ ទោះបីយើងខំប្រឹងប្រែងពិនិត្យកែជាច្រើនលើកច្រើនសាដោយផ្ចិតផ្ចង់ក៏ដោយ ក៏គង់មានចំណុចខ្វះចន្លោះផ្នែកអក្ខរាវិរុទ្ធ និងសេចក្តីនៅមានធ្គាំធ្គង់ខ្លះ ៗ មិនខាន ។ សូមអស់លោកអ្នកអានឃើញខុសត្រង់ណា មេត្តាជួយកែតម្រូវក្នុងលក្ខណៈស្ថាបនាឲ្យបានរីកចម្រើនដើម្បីបានជាក្បួនខ្នាតទុកសម្រាប់កុលបុត្រសិក្សាតទៅអនាគត ។

សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា សូមចែករំលែកនូវកងការមហាកុសលដែលកើតឡើងពីការបកប្រែរៀបរៀងសៀវភៅភូរិទត្ត

*ជាតកពិស្តារនេះ ថ្វាយ ប្រគេន ជូនដល់អស់លោកអ្នកដែលបានកាន់សៀវភៅនេះអាន និងដល់បុព្វការីជន ញាតិមិត្រ សាច់សាលោហិតទាំងអស់ក្នុងសង្សារវដ្ត សូមឲ្យលោកអ្នកមានគុណទាំងនោះ បានសម្រេចនូវសម្បត្តិ ៣ គឺសម្បត្តិមនុស្ស សម្បត្តិទេព្តា និងសម្បត្តិព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។*

*សូមសត្វលោកទាំងពួងបានប្រកបដោយសេចក្តីសុខជានិរន្តរ៍តទៅ ។*

*រាជធានីភ្នំពេញ,*

*ថ្ងៃ ៩ កើត ខែអស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨*

**កុល ផេង**

**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# មាតិកា

## ជំពូកទី១

មនុស្សនិងនាគនៅរួមគ្នា

ឧបោសថជាមូលហេតុនៃនិទាន..............................................១

ស្តេចព្រហ្មទត្តនិរទេសរាជបុត្រ...........................................៣

នាគញីមេម៉ាយ......................................................................៥

រាជបុត្រជាប់ស្នេហ៍នាគញី......................................................៧

រាជបុត្រយកនាគញីជាមហេសី..............................................៩

នាគញីបានកូន២ ...............................................................១១

ពនេចរជួបរាជបុត្រ.............................................................១២

រាជបុត្រឡើងគ្រងរាជ្យ.......................................................១៣

នាគញីបែកពីស្វាមីនិងកូន...................................................១៥

## ជំពូកទី២

សត្វអណ្តើកដឹកនាំរឿងស្នេហា

អណ្តើកឈ្មោះចិត្តចូឡេ.....................................................១៨

អណ្តើកកុហកស្តេចធតរដ្ឋថាខ្លួនជាទូតផ្លូវទឹក......................២៣

អណ្តើកប្រើល្បិចពួនក្នុងស្រះ...............................................២៥

ព្រះរាជាបដិសេធថ្វាយធីតាដល់ស្តេចធតរដ្ឋ.........................២៧

មាណពនាគថ្វាយដំណឹងដល់ស្តេចធតរដ្ឋ..........................៣០

ស្តេចក្រុងពារាណសីថ្វាយរាជធីតាដល់ស្តេចនាគ...............៣៣

សមុទ្ទជារស់នៅក្នុងភពនាគ................................................៣៧

## ជំពូកទី៣

### កំណើតព្រះភូរិទត្ត

សមុទ្ទជាមានរាជបុត្រ៤អង្គ..................................................៣៩

សក្កទេវរាជថ្វាយនាមពោធិសត្វថា ភូរិទត្ត............................៤១

ភូរិទត្តរក្សាឧបោសថ...........................................................៤៤

## ជំពូកទី៤

### *ភូរិទត្តយកចិត្តទុកដាក់ចំពោះព្រាហ្មណ៍*


*ព្រាហ្មណ៍និងសោមទត្តដើរព្រៃ*..........................................៤៦

*ព្រាហ្មណ៍ជួបភូរិទត្ត*..........................................................៤៨

*ភូរិទត្តនាំព្រាហ្មណ៍និងកូនទៅភពនាគ*................................៥០

*ព្រាហ្មណ៍លាភូរិទត្តទៅមនុស្សលោកវិញ*............................៥៤

*ព្រាហ្មណីដេញវាយតាព្រាហ្មណ៍*........................................៦១

*គ្រុឌពាំនាគកាត់ព្រៃ*...........................................................៦៤

*គ្រុឌប្លែងខ្លួនសួរតាបស*.......................................................៦៥


## ជំពូកទី៥

### *នាគរាជភូរិទត្តសម្តែងរបាំ*


*តាបសបង្រៀនមន្តចាប់ពស់ដល់ព្រាហ្មណ៍ទុគ៌ត*..................៦៨

*នេសាទព្រាហ្មណ៍ជួបអាលម្ពាយ*.........................................៧០

សោមទត្តខឹងឪពុករត់ទៅបួស.............................................៧៦

អាលម្ពាយចាប់កូរិទត្ត........................................................៨១

កូរិទត្តនាគរាជសម្ដែងរបាំ...................................................៨២

## ជំពូកទី៦

### កូរិទត្តនិងបងប្អូនជួបព្រះមាតុលានៅរាជធានី

ទំនួញរបស់ព្រះនាងសមុទ្ទជា...............................................៨៥

បងប្អូនបែកផ្លូវគ្នារកកូរិទត្ត..................................................៩២

អាលម្ពាយនិងសុទស្សនៈបង្ហួតឫទ្ធិគ្នា....................................៩៥

កម្លាំងពិសរបស់នាងអជមុខី...............................................១០៣

## ជំពូកទី៧

### ទន្លេយមុនាមិនអាចលាងបាបដែលបុគ្គលធ្វើហើយទេ

នេសាទព្រាហ្មណ៍ទៅលាងបាបក្នុងទន្លេយមុនា.................១១០

សុភោគៈចាប់ជ្រមុជនេសាទព្រាហ្មណ៍ទៅក្នុងទឹក..............១១១

សុភោគៈចាប់នេសាទព្រាហ្មណ៍ទៅកពនាគ......................១១៤

## ជំពូកទី៨

ទ្រឹស្តីកាណារិដ្ឋៈខុសពីសេចក្តីពិត

កាណារិដ្ឋៈពោលថាព្រាហ្មណ៍ជាបុត្រមហាព្រហ្ម...............១១៦

កាណារិដ្ឋៈពោលថាព្រហ្មអ្នកបែងចែកវណ្ណៈ៤ .................១១៧

កាណារិដ្ឋៈថ្លែងពីមូលហេតុកើតស្នឹងទន្លេសមុទ្រ...............១២១

កាណារិដ្ឋៈថ្លែងពីមូលហេតុកើតភ្នំ.....................................១២៤

កាណារិដ្ឋៈថ្លែងពីមូលហេតុទឹកសមុទ្រប្រៃ..........................១២៥

## ជំពូកទី៩

ព្រះនាងសមុទ្ទជាជួបព្រះបិតានិងព្រះជេដ្ឋា

ភូរិទត្តដោះស្រាយមិច្ឆាកថា................................................១២៨

គ្រួសារភូរិទត្តជួបជុំគ្នា.........................................................១៣៨

ព្រះសាស្តាប្រជុំជាតក..........................................................១៤២

# ជំពូកទី ១

## មនុស្សនិងនាគនៅជាមួយគ្នា

### និទានខាងដើម

*ធម្មទេសនាដែលមានពាក្យផ្តើមថា "យំ កិញ្ចិ រតនំ អត្ថិ" ដូច្នេះ នេះ គឺព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង បានត្រាស់សម្តែងប្រារព្ធទៅនឹងឧបាសកទាំងឡាយអ្នករក្សាឧបោសថ ខណៈពេលដែលព្រះអង្គគង់នៅក្នុងវត្តជេតពនជិតក្រុងសាវត្ថី ។*

*មានសេចក្តីតំណាលថា ក្នុងវេលាព្រឹកមួយនៃថ្ងៃឧបោសថ មានពួកឧបាសកមួយក្រុម អធិដ្ឋានឧបោសថរួចហើយ បានឲ្យទាន ។ លុះដល់វេលាក្រោយភត្ត ឧបាសកទាំងឡាយនោះ បានយកគ្រឿងក្រអូបនិងផ្កាកម្រងជាដើមដើរដង្ហែគ្នារជយ[១] ទៅកាន់វត្តជេតពន ដល់ហើយនាំគ្នាអង្គុយស្តាប់ព្រះធម៌ក្នុងទីសមគួរ ។ ព្រះសាស្តា ស្តេចយាងមកកាន់ធម្មសភា គង់ប្រថាប់លើពុទ្ធាសនៈ[២]ដែលគេក្រាលថ្វាយ ហើយ*

---

[១] (កិ. វិ.) (រ-ជយ) *ដែលដើរត ៗ គ្នាតាមលំដាប់លំដោយ : ដើររជយ ។*

[២] (--ស:ន៉:) *អាសនៈនៃព្រះពុទ្ធ, អាសនៈសម្រាប់តម្កល់ព្រះពុទ្ធរូប ។*

ទ្រង់ទតព្រះនេត្រមើលទៅភិក្ខុសង្ឃ ។ ធម្មតាព្រះតថាគត[៣]ទាំងឡាយមុននឹងសម្ដែងធម្មកថាប្រារព្ធទៅនឹងបុគ្គលទាំងឡាយណា មានភិក្ខុជាដើម ព្រះអង្គតែងចរចាជាមួយនឹងជនទាំងឡាយនោះជាមុន រួចទើបសម្ដែងនូវធម្មកថាជាខាងក្រោយ ។ ព្រោះហេតុនោះ ព្រះសាស្ដាជ្រាបថា " ធម្មកថាក្នុងថ្ងៃនេះ នឹងត្រូវលើកឡើងអំពីបុព្វចរិយា[៤] ប្រារព្ធទៅនឹងឧបាសកទាំងឡាយ" ។ ដូច្នេះ ព្រះអង្គសំណេះសំណាលជាមួយនឹងឧបាសកទាំងឡាយនោះរួច ទើបសួរថា ៖

"ម្នាលឧបាសកទាំងឡាយ អ្នកទាំងអស់គ្នា សុទ្ធតែជាអ្នករក្សាឧបោសថមែនឬ ?"

"ព្រះករុណា ព្រះអង្គ" ពួកឧបាសកឆ្លើយ ។

---

[៣] តៈថាគត់, សំ.; បា. (ន.) ព្រះនាមវិសេសនៃព្រះសព្វញ្ញុពុទ្ធគ្រប់ព្រះអង្គៈ ព្រះតថាគត, ព្រះតថាគតទាំងឡាយ ។ល។ ប្រើជាបុរិសសព្វនាមផ្ទាល់ព្រះអង្គជាជំនួសពាក្យថា " ខ្ញុំ, អញ" ក៏បាន ឧ. ម្នាលភិក្ខុទាំងឡាយ អញតថាគតនឹងសម្ដែងធម៌ដល់អ្នករាល់គ្នា ។

[៤] (បុប-ព:-ចៈរ៉ិយ៉ា) ន. (បា.; សំ. បូវ៌ចយា) ចរិយាដើម គឺការប្រព្រឹត្ត, សំណាង ឬ មារយាទ, ទម្លាប់, សណ្ដាប់ធ្នាប់, ដែលបុគ្គលធ្លាប់បានប្រព្រឹត្តពីជាតិមុន ៗ មកជាប់ជាស្នាមតាមមកដល់ជាតិនេះ ។

*ព្រះសាស្ដាត្រាស់ថា ៖*

*"ប្រពៃណាស់ ឧបាសក ដែលអ្នកទាំងឡាយបានធ្វើនូវអំពើល្អ, ប៉ុន្តែមួយវិញទៀត ការដែលអ្នកទាំងឡាយ បាននូវព្រះពុទ្ធប្រាកដស្មើនឹងតថាគតធ្វើជាអាចារ្យ ជួយផ្ដល់ដំបូន្មាន ទើបអាចធ្វើនូវឧបោសថទៅបាន នេះមិនទាន់ជាអស្ចារ្យពេកទេ, ចំណែកបុរាណបណ្ឌិតទាំងឡាយ ថ្វីដ្បិតតែឥតអាចារ្យដឹកនាំ ក៏លោកក្លាហានលះបង់នូវយសសក្តិដ៏ធំខ្ពង់ខ្ពស់ ហើយធ្វើនូវឧបោសថបាន, នុ៎ះ ទើបជារឿងអស្ចារ្យក្រៃលែង"។*

## ស្ដេចព្រហ្មទត្តនិរទេស[៥]រាជបុត្រ

*ក្រោយពីព្រះពុទ្ធអង្គត្រាស់យ៉ាងនេះហើយ ឧបាសកទាំងនោះក្រាបទូលអារាធនាព្រះអង្គសម្ដែងរឿងនោះ ព្រះអង្គក៏លើកអតីតនិទាននោះមកបរិយាយដូច្នេះថា ៖*

---

*[៥] (ន.) (សំ.) (និទ៌េគ) ដំណើរបំបរបង់ឲ្យចេញពីស្រុក, ពីនគរខ្លួនទៅនៅស្រុក, នគរឯទៀត ។ ច្រើនប្រើជា កិ. ត្រូវនិរទេសវាទៅ !។*

ក្នុងកាលកន្លងកន្លងទៅយូរលង់ណាស់មកហើយ មានព្រះរាជាមួយអង្គ ព្រះនាមថា **ព្រហ្មទត្ត** សោយរាជ្យក្នុងនគរពារាណសី ។ ស្តេចអង្គនោះ បានប្រទានឋានៈឧបរាជ[៦] ដល់ព្រះរាជបុត្ររបស់ព្រះអង្គ ។ ព្រះអង្គឃើញព្រះរាជបុត្រមានសក្តិយសខ្ពង់ខ្ពស់ដូច្នោះ ក៏ចេះតែនឹកព្រួយបារម្ភ កើតមន្ទិលសង្ស័យក្នុងព្រះរាជហឫទ័យថា "បុត្រនេះ នឹងដណ្តើមរាជ្យអញ ៗ" ។ ព្រោះតែរឿងនេះ ព្រះអង្គនៅមិនសុខទេ ទ្រង់ក៏ប្រាប់រាជបុត្រថា ៖

"ហៃបា ! ចូរបុត្រចៀសចេញអំពីដែនរបស់យើងនេះ ទៅរស់នៅក្នុងទីកន្លែងណាតាមដែលអ្នកពេញចិត្តចុះ លុះអំណឹះ[៧]ឥតពីបិតាទៅ ចូរបុត្រត្រឡប់មកសោយរាជ្យស្នងត្រកូលបិតាចុះ" ។

---

[៦] (ន.) (សំ.),(បា.) (អ៊ុប៉ៈរ៉ាច ឬ អុប៉ៈ--) ព្រះរាជាបន្ទាប់ គឺក្សត្រិយ៍ដែលមានរាជស័ក្តិរងបន្ទាប់ក្សត្រិយ៍ទ្រង់រាជ្យ : សម្តេចព្រះឧបរាជ ឬសម្តេចព្រះមហាឧបរាជ (តាមបវេណីក្នុងកម្ពុជរដ្ឋ, នាទីរបស់សម្តេចព្រះមហាឧបរាជជាឋានៈសម្រាប់ត្រី ទាំងមន្ត្រីធំតូចសម្រាប់ព្រះអង្គ ក៏តាំងក្នុងឋានៈសម្រាប់ត្រីដែរ ។

[៧] (និ.) តមកឬតទៅ, ចំណោរកាលតមក ឬចំណោរកាលតទៅ : **អំណឹះពីនោះមក** តពីនោះមក ។ **អំណឹះតទៅ** ចំណោរកាលតទៅ ។ **អំណឹះឥតពី** លុះដល់ឥតពី, កាលបើឥតពី : ម្នាលអានន្ទ, អំណឹះឥតពីអញតថាគតទៅ ធម៌វិន័យនឹងជាសាស្តានៃអ្នកទាំងឡាយជាតំណាងអញតថាគត (ពុទ្ធបណ្តាំ) ។

*ព្រះរាជបុត្រ យល់ព្រម ថ្វាយបង្គំលាព្រះបិតា ចេញដំណើរឆ្ពោះទៅទន្លេយមុនា តាមលំដាប់ បានសាងបណ្ណសាលាមួយក្នុងរវាងចន្លោះនៃទន្លេយមុនា សមុទ្រ និងភ្នំ រួចស្នាក់នៅទីនោះ ដោយស្វែងរកមើមឈើ និងផ្លែឈើក្នុងព្រៃមកធ្វើជាអាហារ ។*

**នាងនាគីមេម៉ាយ**

*គ្រានោះ ក្នុងពិភពនាគខាងក្រោមបាតសមុទ្រ មាននាងនាគីម្នាក់ប្តីស្លាប់ ។ នាគីនោះកាលមើលឃើញយសរបស់នាងនាគីដទៃ ៗ ដែលមានប្តីនៅរួមរស់ នាងកើតក្តីអផ្សុក (ព្រោះគ្មានប្តីនឹងគេ) ដូច្នេះ នាងទើបចេញអំពីភពនាគដើរលេងលំហែតាមឆ្នេរសមុទ្រ ស្រាប់តែប្រទះឃើញស្នាមជើងរបស់ព្រះរាជបុត្រ ក៏ដើរតាមស្នាមជើងនោះទៅ ដើរទៅ ៗ បានឃើញបណ្ណសាលានោះ ។ គាប់ចួនពេលនោះ រាជបុត្រពុំបាននៅក្នុងបណ្ណសាលាទេ ទ្រង់ចេញទៅរកផលាផល[៩]មកធ្វើជា*

---

[៩] *(ផៈល៉ាផល់) ន. (សំ. បា.) ផ្លែតូចនិងផ្លែធំ (ផ្លែឈើតូចធំ) : ស្វែងរកផលាផលជាអាហារ ។ ផលានុផល (ផៈល៉ានុផល់) ន. (បា. ផល + អនុផល) ផ្លែនិងផ្លែតាមលំដាប់, ផ្លែមុននិងផ្លែក្រោយ; ផ្លែធំនិងផ្លែតូច ។ ពាក្យនេះ តាមទម្លាប់ដែលប្រើមក គឺសំដៅយកផលដំណាំសំខាន់ ៗ ដូចជាស្រូវ, ពោត ដែលប្រើជាអាហារចាំបាច់ និងផល*

អាហារ ។ នាងនាគី ចូលទៅក្នុងបណ្ណសាលាហើយ ឃើញរនាបឈើ និងគ្រឿងបរិក្ខារផ្សេង ៗ ទើបគិតថា ៖

"បណ្ណសាលានេះ គឺជាកន្លែងស្នាក់នៅរបស់អ្នកបួសតែម្នាក់ប៉ុណ្ណោះ អញនឹងសាកល្បងបព្វជិតនោះមើល ថាតើគេបួសដោយសទ្ធាឬក៏អត់ទេ ប្រសិនបើគេបួសដោយសទ្ធាមែន គេនឹងមិនមានចិត្តជាប់ជំពាក់ទេ ប្រាកដជាមិនត្រេកអរចំពោះអាសនៈដែលអញរៀបចំនេះឡើយ តែប្រសិនបើ គេត្រេកអរខ្លាំងចំពោះកាមវិញ គេមិនបួសដោយសទ្ធាទេ គេមុខតែនឹងដេកលើគ្រែនេះ កាលបើដូច្នេះ អញនឹងយកគាត់ធ្វើជាប្ដី រស់នៅទីនេះតែម្ដង" ។

លុះគិតដូច្នេះហើយ នាងនាគីក៏ទៅយកទិព្វបុប្ផា[៩] និងទិព្វគន្ធា[១០] ទាំងឡាយ នៅឯពិភពនាគ យកមករៀបជាទីសយនា[១១]ផ្កាទិព្វ ខាងក្នុង

---

ដំណាំបន្ទាប់បន្សំរាយរងផ្សេង ៗ ដូចជាល្ហុត, ស្វាយ, ចេក ជាដើម : ឆ្នាំនេះ ផលានុផលគ្រប់ប្រភេទនៅប្រទេសយើងបានចម្រើនកើនជាងឆ្នាំមុន ។

[៩] (ន.) បា. ផ្កាទិព្វ, បុប្ផាទិព្វ ។

[១០] (ន.) បា.ក្លិនទិព្វ, ក្លិនដ៏ជាទិព្វ ។

[១១] (ន.) (បា.),(សំ.) (ស: យ៉: ន៉ា) ទីឬកន្លែងដេក, ដំណេក; ការដេក, ឥរិយាបថដេក : ទៃនសយនា, រាជសព្ទ : គ្រែសម្រាប់ស្ដេចផ្ទំ, ក្រឡាបន្ទំ ។ **សយនកាល** ឬ--**វេលា** ពេលដេក ។ **សយនដ្ឋាន** កន្លែងសម្រាប់ដេក ។ **សយនាសនៈ** (បា. < សយន "ទី

បណ្ណសាលា ព្រមទាំងរោយរាយលម្អិតគ្រឿងក្រអូបពីលើផ្កា តុបតែង បណ្ណសាលា ឲ្យមានសណ្ដាប់ធ្នាប់ល្អនិងប្រកបដោយសោភណភាព[១២] រួចត្រឡប់ទៅកាន់ភពនាគវិញ ។

## រាជបុត្រជាប់ស្នេហ៍នាងនាគី

ព្រះរាជបុត្រត្រឡប់មកវិញ ក្នុងវេលាល្ងាច ចូលទៅក្នុង បណ្ណណ- សាលា ឃើញនូវការរៀបចំនោះ ក៏នឹកឆ្ងល់ថា "យីអើ! តើនរណាគេហ្ន៎ រៀបកន្ទេងដេកនេះ ?" កាលបរិភោគផលាផលហើយ ឈរសម្ងឹងពិនិត្យមើលទៅកន្ទេងដេក គិតស្ញើចក្នុងចិត្តថា ៖

"បុប្ផាទាំងឡាយ មានក្លិនក្រអូបអ្វីម៉្លេះទេហ្ន៎ ទាំងកម្រាលសយនា បុប្ផាទិព្វនេះ ក៏គួរឲ្យគាប់ចិត្តក្រៃពេក"

---

សម្រាប់ដេក" + អាសន "ទីសម្រាប់អង្គុយ") ទីដេកនិងទីអង្គុយ (សេនាសនៈ) ។ **សយ-នោកាស** (បា. សយន + ឱកាស) ឱកាសសម្រាប់ដេក; ពេលទំនេរសម្រាប់ដេក ។ល ។

[១២] (ន.) បា.ភាពល្អប្រសើរ, ភាពល្អក្រៃលែង, ភាពល្អកន្ទង់ ។ សព្វថ្ងៃនេះ ឃើញមានសរសេរពាក្យនេះខុសជាហូរហែដូចជា សោភ័ណ្ឌភាព, សោភ័ណភាពជាដើម ត្រូវសរសេរ សោភណភាព ដូច្នេះវិញ ទើបត្រូវតាមក្បួនវេយ្យាករណ៍ ។

ព្រះរាជបុត្រមានសោមនស្សរីករាយក្រៃលែង ព្រោះហេតុតែខ្លួនមិនមែនបួសដោយសទ្ធា ប្រះប្រាណដេកលើកម្រាលផ្កាទិព្វ ហើយក៏លង់លក់ស៊ុបស្រួលទៅ រហូតទល់ពេលព្រះអាទិត្យរះជាថ្មី ទើបភ្ញាក់ឡើង ក៏មិនបានបោសសម្អាតបណ្ណសាលាដូចសព្វដងទេ គាត់ដើរទៅរកបេះផលាផលតែម្តង ។

ចំណែកនាងនាគី ត្រឡប់មកក្នុងខណៈនោះ ឃើញផ្កាទាំងឡាយស្វិតស្រពោន ក៏ដឹងច្បាស់ថា ៖

"តាបសនុ៎ះ ពិតជាស្រឡាញ់កាមមែនហើយ បានជាដេកលើកម្រាលផ្កាទិព្វនេះ គាត់មិនមែនបួសដោយសទ្ធាទេ អញអាចចាប់តាបសនោះឲ្យធ្វើជាប្តីរបស់អញបានទេតើ"

គិតដូច្នេះហើយ នាងនាគីយកផ្កាចាស់ចេញ នាំផ្កាថ្មីស្រស់ផ្សេង ៗ មករៀបជាកម្រាលដេកយ៉ាងនោះម្តងទៀត តុបតែងបណ្ណសាលា រោយរាយផ្ការួចជាស្រេចហើយ បានទៅកាន់ភពនាគវិញ ។

តាបសនោះ ញ៉ាម[១៣]នឹងភាពស្រណុកសុខស្រួលនោះ ក៏ប្រេះ[១៤] ប្រាណលើកម្រាលបុប្ផាទិព្វនោះ ក្នុងថ្ងៃទីពីរទៀត ។ លុះដល់ថ្ងៃបន្ទាប់ រាជបុត្រកាន់តែឆ្ងល់ថា "នរណាហ្ន៎ មកតុបតែងបណ្ណសាលានេះ ?" ដើម្បីដឹងពីអាថ៌កំបាំងនេះ ទ្រង់មិនចេញទៅរកបេះផ្លែឈើទេ ថ្ងៃនេះ ទៅឈរនៅកន្លែងកំបាំងមួយនៅក្បែរបណ្ណសាលា ហើយពួនសំងំ រង់ចាំមើល ។

## រាជបុត្រយកនាងនាគីជាមហេសី

ថ្ងៃពីនាងនាគីឯណោះវិញ បានយកគ្រឿងក្រអូបនិងផ្កាជាច្រើន ទៅកាន់អាស្រមបទ ។ តាបសក្រឡេកទៅឃើញនាងនាគី មានរូបឆោម លោមពណ៌ស្រស់ល្អឆើត ក៏មានចិត្តប្រតិព័ទ្ធភ្លាម តែមិនបង្ហាញខ្លួនឲ្យ នាងនាគឃើញទេ ។ ក្នុងពេលនាងនាគីចូលទៅខាងក្នុងបណ្ណសាលា កំពុងតែរៀបចំទីដេក តាបសដើរលប ៗ ពីក្រោយ មិនឲ្យឮស្នូរជើង បន្តិច ចូលទៅតាមរួចសួរថា "នាងជាអ្នកណា ?"

---

[១៣] (កិ.) ជាប់ចិត្ត, ញៀនចិត្ត ឧ. ធ្លាប់បានស៊ីឆ្ងាញ់ម្ដងហើយ វាចេះតែញ៉ាមតទៅទៀត ។ ពាក្យផ្ទុយ ទ្រាន់, ណាយចិត្ត, រាងចាល ។

[១៤] ផ្ទៀងខ្លួនដេក, ផ្ដួលខ្លួនដេក ។

នាគី ៖ "ខ្ញុំជានាគ លោកម្ចាស់"

តាបស ៖ "តើនាងមានប្ដីហើយ ឬនៅលីវទេ ?"

នាគី ៖ "បពិត្រលោកម្ចាស់ ដើមឡើយនាងខ្ញុំមានប្ដី ប៉ុន្តែ ឥឡូវនេះ
ឥតមានប្ដីទេ ខ្ញុំជាស្រីមេម៉ាយ, ចុះលោកម្ចាស់វិញ
មានលំនៅក្នុងប្រទេសណាដែរ ?"

តាបស ៖ "អាត្មាភាព ជាបុត្ររបស់ស្ដេចក្រុងពារាណសី ឈ្មោះ
របស់អាត្មាគឺ ព្រហ្មទត្តកុមារ ចុះនាងលះបង់ភពនាគមក
ទីនេះ ព្រោះហេតុអ្វីដែរ ?"

នាគី ៖ "បពិត្រលោកម្ចាស់ នាងខ្ញុំឃើញពួកនាងនាគី ដែលមាន
ប្ដីក្នុងភពនាគនោះ គិតចង់មានប្ដីនឹងគេ កើតក្ដីអផ្សុក
ក៏ចេញអំពីទីនោះ ដើរស្វែងរកប្ដី"

តាបស ៖ "ហៃអូនសម្លាញ់ បើដូច្នោះ មិនជាអ្វីទេ, សូម្បីបងក៏មិនមែន
បួសដោយសទ្ធាដែរ ខ្ញុំមករស់នៅទីនេះដោយសារព្រះបិតា
បណ្ដេញ, នាងកុំព្រួយបារម្ភឡើយ ខ្ញុំនឹងធ្វើជាប្ដីរបស់នាង
យើងទាំងពីរនាក់ នឹងនៅរួមព្រមចិត្តគំនិតគ្នាជាប្ដីប្រពន្ធ
រួមសុខរួមទុក្ខនៅទីនេះ" ។

នាគី ៖ "ចាស បង" ។

តាំងពីគ្រានោះមក ជនទាំងពីររូបនោះ នៅរួមសមគ្គសំវាស[១៥] ជាប្ដីប្រពន្ធនឹងគ្នាក្នុងទីនោះឯង ។ នាងនាគី បាននិម្មិតគេហដ្ឋានដ៏ធំល្មម ដោយអានុភាពរបស់ខ្លួន យកបល្ល័ង្កដ៏ធំពីភពនាគក្រាលធ្វើជាកន្ទែងដេក ។ រាជបុត្រនោះ ក៏លែងបរិភោគមើមឈើ ផ្លែឈើតូចធំ តាំងពីគ្រាបាននាងនាគីធ្វើជាប្រពន្ធ និងសម្រេចជីវិតរស់នៅ ដោយបរិភោគបាយនិងទឹកជាទិព្វវិញ ។

ចំណេរកាលតមក នាងនាគីមានគភ៌ ហើយបានសម្រាលកូនប្រុសមួយ ហេតុតែកូននោះកើតទៀបឆ្នេរសាគរ ម្ដាយឪពុកក៏ដាក់ឈ្មោះគេថា "**សាគរព្រហ្មទត្ត**" ។ ក្នុងពេលកូននោះរឹងជើងចេះដើរបាន នាងនាគីបានសម្រាលកូនមួយទៀតជាស្រី ហេតុតែកូនកើតទៀបឆ្នេរសមុទ្រ ម្ដាយឪពុកដាក់ឈ្មោះនាងថា "**សមុទ្ទជា**" ។

---

[១៥] (សៈម៉ុក-គៈ-សង្វាស) (--ស័ង ឬ សង់-វ៉ាស) ការនៅរួមព្រមចិត្តគំនិតគ្នា, ការនៅរួមសុខរួមទុក្ខ (របស់ស្វាមីភរិយា) ។ល។

**ពរានចរជួបរាជបុត្រ**

ក្នុងគ្រានោះ ពរានចរ[១៦]ម្នាក់ ដែលមានលំនៅក្នុងក្រុងពារាណសី បានធ្វើដំណើរមកដល់ទីនោះ ។ ពេលនោះ ព្រះរាជបុត្រធ្វើបដិសណ្ឋារៈទទួល ពរានចរនោះចំណាំបានថាជាព្រះរាជបុត្រ ក៏សុំស្នាក់នៅទីនោះពីរបីថ្ងៃ ទើបថ្វាយបង្គំលារាជបុត្រថា ៖

"បពិត្រព្រះសម្មតិទេព ទូលបង្គំជាខ្ញុំនឹងរាយការណ៍ដល់រាជ-វង្សានុវង្សថា ព្រះអង្គកំពុងគង់នៅក្នុងទីនេះ"

ដូច្នេះ គេក៏ចៀសចេញ ធ្វើដំណើរទៅកាន់នគរវិញ ។

គាប់ចួនគ្រានោះ ព្រះរាជាចូលទិវង្គត ។ អស់នាហ្មឺនសព្វមុខមន្ត្រីរៀបពិធីបូជាសពព្រះមហាក្សត្រ លុះដល់ថ្ងៃជាគម្រប់ ៧ ពួកគេបានប្រជុំគ្នាប្រឹក្សាថា ៖

"ជាធម្មតា រាជាណាចក្រ ដែលឥតស្ដេចគ្រប់គ្រង នឹងឋិតថេរនៅយូរមិនបានទេ, យើងមិនដឹងថារាជបុត្រនៅទីណា ទាំងមិនដឹង

---

[១៦] អ្នកត្រាច់ទៅក្នុងព្រៃ ។

*ថាតើទ្រង់គង់ព្រះជន្មនៅឬក៏អត់ ដូច្នេះយើងនឹងលេងបុស្សរថ[១៧] ផ្សងរកអ្នកមានបុណ្យអស្ចារ្យធ្វើជាស្តេចផែនដី" ។*

*ក្នុងខណៈនោះ ពនេចរធ្វើដំណើរដល់នគរ ឮការប្រឹក្សានោះ ក៏ចូលទៅកាន់សម្នាក់របស់មន្ត្រីទាំងឡាយ ជម្រាបនូវដំណឹងនោះថា ៖*

*"ខ្ញុំបាទបានស្នាក់នៅ ៣-៤ ថ្ងៃ ក្នុងសម្នាក់ព្រះរាជបុត្រ ទើបតែត្រឡប់មកដល់នេះឯង" ។*

## រាជបុត្រឡើងគ្រងរាជ្យ

*មន្ត្រីទាំងឡាយ បានផ្តល់រង្វាន់ដល់ពនេចរនោះ យកគេធ្វើជាមគ្គុទ្ទេសក៍[១៨] ធ្វើដំណើរទៅកន្លែងព្រះរាជបុត្ររស់នៅ លុះទៅដល់ព្រះរាជបុត្របានធ្វើបដិសណ្ឋារៈទទួល ហើយពួកគេបានក្រាបទូលអំពីការសោយព្រះទិវង្គតរបស់ព្រះមហាក្សត្រ រួចក្រាបទូលយាងព្រះរាជ-បុត្រថា ៖*

---

*[១៧] រថមានបុស្បុកពណ៌ស ទឹមសេះឲ្យអូសដើរមុន ពួកសេនាបតីមន្ត្រីធំតូចទាំងអស់ដើរអមហែហមតាមក្រោយ ផ្សងរកអ្នកមានបុណ្យកព្វអស្ចារ្យទទួលរាជ្យ នៅពេលដែលផុតរាជវង្ស ឬមានតែព្រះរាជបុត្រីមិនគួរទទួលរាជ្យ ។*

*[១៨] អ្នកបង្ហាញផ្លូវ, អ្នកនាំផ្លូវ ។*

"បពិត្រព្រះរាជបុត្រ សូមព្រះអង្គទទួលរាជសម្បត្តិ ក្រាបទូល" ។

ព្រះរាជបុត្រ ចូលទៅរកនាងនាគី ក្នុងគោលបំណងចង់យល់អំពីចិត្ត របស់នាង ហើយមានព្រះបន្ទូលថា ៖

"ហៃអូន ព្រះបិតារបស់បងទ្រង់សោយទិវង្គតហើយ, មន្ត្រីទាំងឡាយមកអញ្ជើញបងឲ្យទៅទទួលស្វេតច្ឆត្រឡើងគ្រងរាជ្យ, តោះទៅអូនសម្លាញ់, យើងទាំងពីរនាក់នឹង សោយរាជ្យក្នុងក្រុងពារាណសី ដែលមានទំហំដី ១២ យោជន៍, អូននឹង បានឋានៈជាព្រះមហេសីច្បងលើអស់ស្រីស្នំទាំងឡាយ ១៦០០០ នាក់" ។

នាគី ៖ "ខ្ញុំម្ចាស់ មិនអាចទៅបានទេ បង" ។

រាជបុត្រ ៖ "ព្រោះហេតុអ្វី ?"

នាគី ៖ "កំណើតពួកខ្ញុំម្ចាស់ មានពិសឃោរឃៅ[១៩] មានចិត្តឆាប់ក្រោធខឹង សូម្បីដោយហេតុត្រឹមតែបន្តិចបន្តួច, ម្យ៉ាងទៀត ធម្មតា ជម្លោះរបស់ស្ត្រីដែលមានប្តីរួម វាមានទម្ងន់ធ្ងន់ណាស់, ប្រសិនបើខ្ញុំឃើញអ្វី ឬឮអ្វីដែលមិនល្អ ហើយ

[១៩] ខ្លាំងក្រៃ, គួរខ្លាច, ហៅហាន, មោះមុត, ឥតមានមេត្តាប្រណី ។

*កើតក្ដីមួម៉ៅខឹងសម្បា[២០] លោតែជ្រុលសម្ដីងអ្វីណាទីមួយ ហើយ អ្វីនោះនឹងខ្ទេចខ្ទីម៉ដ្ឋដូចផេះមួយក្ដាប់ដៃ, ដោយ ហេតុនេះ ខ្ញុំម្ចាស់មិនអាចនឹងទៅបានទេ បង" ។*

## នាគីបែកពីស្វាមីនិងកូន

*រាជបុត្រ បានអង្វរយ៉ាងនោះម្ដងទៀត ក្នុងថ្ងៃបន្ទាប់ ។ គ្រានោះ នាងនាគីក្រាបទូលយ៉ាងនេះចំពោះរាជបុត្រថា ៖*

*"ទោះបីដោយបរិយាយណាក៏ដោយ ក៏ខ្ញុំម្ចាស់នៅតែទៅមិនបាន ជាដាច់ខាត ប៉ុន្តែកូនទាំងពីរនេះ របស់ខ្ញុំម្ចាស់ ជានាគកុមារ មាន ជាតិជាមនុស្ស ព្រោះកើតដោយទឹកសម្ភពរបស់ព្រះអង្គ ប្រសិន បើព្រះអង្គមានសេចក្ដីស្រឡាញ់ចំពោះខ្ញុំម្ចាស់ សូមព្រះអង្គកុំ ប្រហែសធ្វេសចំពោះកូន ៗ យើងនេះអី ។ កូនទាំងពីរនេះ ពួកគេ ជាកំណើតទឹក មានសុខុមាលភាពល្អណាស់ កាលដើរផ្លូវឆ្ងាយ ពួកគេនឹងត្រូវលំបាកហត់នឿយ ដោយខ្យល់និងកម្ដៅថ្ងៃ ហើយ អាចស្លាប់បាន ព្រោះហេតុនោះ សូមព្រះអង្គឲ្យគេដាប់លុង ឈើធំមួយធ្វើជារាងសំពៅ ដាក់ទឹកឲ្យពេញ ឲ្យកូនតូចទាំងពីរ*

---

[២០] *ខឹងធាប់រសោយ ។*

លេងទឹកក្នុងសំពៅនោះ ។ សូម្បីដល់ក្នុងនគរហើយក៏ដោយ សូមព្រះអង្គឲ្យគេជីកស្រះបោក្ខរណី កាលបើយ៉ាងនេះ កូន ៗ យើងនឹងមិនលំបាកឡើយ" ។

នាងនាគី លុះនិយាយយ៉ាងនេះហើយ ក៏ថ្វាយបង្គំរាជបុត្រធ្វើប្រទក្សិណ ឱបកូនទាំងពីរដាក់ផ្ដេកលើចន្ទោះស្ដន ថើបជញ្ជក់តត្រង់ក្បាលកូន ៗ ហើយប្រគល់ទៅឲ្យរាជបុត្រ រួចយំកន្ទក់កន្ទេញ អន្តរធានបាត់ខ្លួនអំពីទីនោះ ទៅកាន់ភពនាគវិញ ។ ចំណែកឯរាជបុត្រវិញពោរពេញដោយទោមនស្ស ទ្រង់យាងចេញអំពីរាជនិវេសន៍ ទាំងមានព្រះភក្ត្រសើមជោកដោយទឹកព្រះនេត្រា យាងជូតព្រះនេត្រាបណ្ដើរចូលទៅរកពួកមន្ត្រី ។ ពួកមន្ត្រី បានរៀបពិធីអភិសេកព្រះអង្គឲ្យឡើងជាក្សត្រទ្រង់រាជ្យក្នុងទីនោះឯង រួចហើយក្រាបទូលព្រះអង្គថា ៖

"បពិត្រព្រះសម្មតិទេព សូមស្ដេចយាង ក្រាបទូល ពួកយើងនឹងទៅកាន់នគររបស់យើងវិញ" ។

ព្រះរាជាត្រាស់បង្គាប់ថា ៖

"បើដូច្នោះ ចូរអស់លោកប្រញាប់ធ្វើទូកមួយ ឲ្យបានលឿនជាទីបំផុត រួចលើកដាក់លើរទេះ ដងទឹកដាក់ឲ្យពេញ ពោយរាយផ្កា

នានាដែលបរិបូណ៌ដោយពណ៌និងក្លិនក្រអូប ។ រាជបុត្រទាំងពីរ របស់យើង ជាកំណើតទឹក ពួកគេលេងក្នុងទឹកនោះហើយនឹងទៅ ដោយមិនលំបាក" ។

មន្ត្រីទាំងឡាយ បានធ្វើតាមព្រះរាជឱង្ការ ។ ព្រះរាជាទ្រង់ស្ដេចយាង ទៅដល់ក្រុងពារាណសី បានចូលទៅកាន់នគរដែលគេតុបតែងយ៉ាង មានសោភណភាព ទ្រង់ត្រូវបានចោម រោមហែហមដោយស្រីរបាំ ចំនួន ១៦.០០០ និងពួកមន្ត្រីក្រុមការជាដើម ស្ដេចយាងឡើងខាងក្នុង ព្រះរាជមន្ទីរ សោយទឹកមហាបាន ៧ ថ្ងៃ រួចបង្គាប់ឲ្យគេជីកស្រះ បោក្ខរណី ដើម្បីប្រយោជន៍ដល់បុត្រទាំងពីររបស់ព្រះអង្គ ។ បុត្រទាំង ពីរនោះតែងក្រសាលលេងសប្បាយក្នុងស្រះបោក្ខរណីនោះជានិច្ច ។

# ជំពូកទី ២

## សត្វអណ្ដើកដឹកនាំរឿងស្នេហា

### អណ្ដើកឈ្មោះចិត្តចូឡោ

*តមកក្នុងថ្ងៃមួយ មានសត្វអណ្ដើកមួយក្បាល បានធ្វើដំណើរទៅតាមក្រសែទឹកដែលកំពុងតែហូរចូលទៅក្នុងស្រះបោក្ខរណីនោះ លុះចូលទៅដល់ខាងក្នុងស្រះហើយ រកផ្លូវចេញទៅវិញមិនបាន ក៏ដេកក្នុងបាតស្រះនោះឯង ។ ក្នុងពេលព្រះកុមារទាំងពីរ កំពុងក្រសាលលេងក្នុងស្រះនោះ អណ្ដើកបានផុសពីទឹក អើតក្បាលមើលព្រះកុមារទាំងពីរ រួចមុជចូលទៅក្នុងទឹកវិញ ។ ព្រះកុមារទាំងពីរឃើញអណ្ដើកហើយ កើតការភ័យខ្លាច ក៏ស្ទុះឡើងអំពីស្រះរត់សំដៅទៅរកព្រះបិតាដល់ហើយក្រាបទូលថា ៖*

> *"បពិត្របិតា ក្នុងស្រះមានយក្សមួយបានបន្ទាចពួកបុត្រ, ពួកបុត្រភ័យតក់ស្លុតខ្លាំងណាស់ ក្រាបទូល" ។*

*ព្រះរាជាទ្រង់សណ្ដាប់ដូច្នោះហើយ ក៏ត្រាស់បញ្ជារាជបុរសទាំងឡាយឲ្យទៅចាប់យក្សនោះ ។ រាជបុរសទាំងឡាយ បានបង់សំណាញ់រាវរក*

ស្រាប់តែចាប់បានអណ្ដើកមួយ ហើយក៏នាំគ្នាយកមកថ្វាយព្រះរាជាឲ្យទ្រង់ទត ។ ព្រះរាជកុមារទាំងពីរឃើញអណ្ដើរនោះភ្លាម ក៏ស្រែកថា ៖

"នុ៎ះ ជាបិសាច ព្រះបិតា" ។

ព្រះរាជា ហេតុតែស្រឡាញ់បុត្រ ទ្រង់បែរជាពិរោធ[២១] ចំពោះអណ្ដើកនោះយ៉ាងខ្លាំង ទើបត្រាស់បង្គាប់រាជបុរសទាំងឡាយថា ៖

"ចូរអ្នកទាំងឡាយធ្វើទារុណកម្មចំពោះអណ្ដើក" ។

បណ្ដាបុរសទាំងឡាយ បុរសមួយក្រុមមានយោបល់ថា ៖

"អណ្ដើកនេះជាគូពៀរ[២២] នៃព្រះមហាក្សត្រ គួរតែយើងយកវាទៅដាក់ក្នុងត្បាល់ ហើយយកអង្រែបុកឲ្យខ្ទេចខ្ទី" ។

មួយក្រុមទៀតថា ៖

"ទេ កុំធ្វើអ៊ីចឹងអី, គួរតែយើងគាបវានឹងតម្បុតអាំងស៊ីទៅ" ។

[២១] កំហឹង, ការឈ្លោះទាស់ទែង ។

[២២] គូសង្សឹក ដោយការចងចិត្តក្រោធគិតព្យាបាទគ្នា ។

ក្រុមមួយទៀតថា ៖

"គួរតែឆ្អើរស៊ីវិញ" ។

មួយក្រុមទៀតថា ៖

"ស្ងោរវាស៊ីវិញ ប្រសើរជាង" ។

ជាមួយគ្នានោះផង មានមន្ត្រីម្នាក់ជាអ្នកខ្លាចទឹកដោយធម្មជាតិ គាត់បានបញ្ចេញយោបល់មួយនឹងគេដែរថា ៖

"ខ្ញុំគិតថា យោបល់របស់អស់លោក មិនមែនជាទារុណកម្មដ៏ខ្លាំងក្លាចំពោះអណ្ដើកនេះទេ, បើតាមយោបល់ខ្ញុំ យើងគួរតែយកអណ្ដើកនេះទៅបោះត្រង់កន្លែងទឹកក្ដួចក្នុងទន្លេយមុនាឲ្យវាស្លាប់ដោយទឹកវិលក្ដួចនោះទៅចុះ" ។

សត្វអណ្ដើកឮសម្ដីរបស់មន្ត្រីនោះភ្លាម ក៏លេចក្បាលប្ញឹមចេញពីស្នូកនិយាយយ៉ាងនេះថា ៖

"ឱ ! អ្នកអើយ តើខ្ញុំបានធ្វើកំហុសដូចម្ដេចចំពោះអ្នក ទើបបានជាអ្នកចាត់ផែនការធ្វើទារុណកម្មដ៏ព្រៃផ្សៃបែបនេះចំពោះខ្ញុំ ពិត

ណាស់ ខ្ញុំអាចទ្រាំនឹងទារុណកម្មផ្សេង ៗ ក្រៅពីនេះបាន ប៉ុន្តែទារុណកម្មមួយនេះឃោរឃៅពេកណាស់ កុំអ្នកនិយាយចេញមកអ៊ីចឹងអី" ។

ទ្រង់ព្រះសណ្តាប់ដូច្នោះហើយ ព្រះរាជាមានព្រះតម្រិះថា ៖

"អណ្តើកនេះ សមនឹងទទួលរងនូវទារុណកម្មបែបនោះហើយ"

លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ទើបបង្គាប់ពួករាជបុរសឲ្យយកអណ្តើកនោះទៅបោះត្រង់ទីទឹកក្ដួចក្នុងទន្លេយមុនា ។ រាជបុរសទាំងឡាយបានធ្វើតាមព្រះរាជឱង្ការ ។ អណ្តើកនោះធ្លាក់ចំកន្លែងទឹកក្ដួចដែលតែងតែហូរទៅកាន់ភពនាគ អណ្តើកនោះមិនស្លាប់ទេ បានរសាត់ទៅតាមក្រសែទឹកហូរក្ដួចនោះរហូតទៅដល់ភពនាគ ។

គ្រានោះ ព្រះរាជបុត្រទាំងឡាយរបស់ស្តេចនាគធតរដ្ឋ កំពុងក្រសាលលេងនៅតាមក្រសែទឹកហូរនោះ ។ ពួកនាគមាណពឃើញអណ្តើកនោះហើយ និយាយថា ៖

"អ្នកទាំងឡាយ ចូរចាប់អាខ្ញុំបម្រើនោះ" ។

អណ្តើកឮដូច្នោះ ក៏នឹកអាណិតខ្លួនថា ៖

"ឱ! ខ្លួនអញអើយ បានរួចពីកណ្ដាប់ដៃស្ដេចក្រុងពារាណសីហើយ តែឥឡូវនេះ ស្រាប់តែមកធ្លាក់ក្នុងកណ្ដាប់ដៃពពួកនាគដ៏ព្រៃផ្សៃបែបនេះទៅវិញ តើអញគប្បីប្រើឧបាយដូចម្ដេចទៅហ្ន៎ទើបដោះខ្លួនឲ្យរួចបាន" ។

អណ្ដើកគិតមួយសន្ទុះ ទើបឃើញថាមានឧបាយបោកប្រាស់ថា ៖

"អ្នកទាំងឡាយ សុទ្ធតែជាកូនចៅរបស់ស្ដេចនាគធតរដ្ឋ ហេតុអ្វីក៏ហ៊ាននិយាយពាក្យយ៉ាងនេះចំពោះខ្ញុំអ៊ីចឹង ? ខ្ញុំជាអណ្ដើកឈ្មោះថា **ចិត្តចូឡោ** ថែមទាំងមានឋានៈជារាជទូតរបស់ស្ដេចក្រុងពារាណសីទៀតផង មូលហេតុដែលខ្ញុំធ្វើដំណើរមកកាន់សម្នាក់របស់ស្ដេចធតរដ្ឋ ពីព្រោះស្ដេចរបស់ខ្ញុំមានរាជបំណងថ្វាយរាជធីតារបស់ព្រះអង្គ ដល់ស្ដេចធតរដ្ឋទើបទ្រង់បញ្ជូនខ្ញុំមកក្នុងពិភពនាគនេះ, អ្នកទាំងឡាយ គួរតែនាំខ្ញុំទៅចូលគាល់ស្ដេចនាគធតរដ្ឋនោះវិញ ទើបជាការត្រឹមត្រូវ" ។

ពួកនាគមាណពឮដូច្នោះ មានចិត្តរីករាយជាខ្លាំង បាននាំអណ្ដើកនោះទៅកាន់សម្នាក់របស់ព្រះបាទធតរដ្ឋ ក្រាបទូលថា ៖

"បពិត្រព្រះសម្មតិទេព មានរាជទូតចង់ចូលគាល់ ក្រាបទូល" ។

ស្តេចនាគធតរដ្ឋ ទ្រង់រាជានុញ្ញាតឲ្យរាជទូតនោះចូលគាល់ ដោយរាជតម្រាស់ថា ៖

"អ្នកទាំងឡាយ ចូរនាំរាជទូតនោះចូលមក" ។

លុះទ្រង់ក្រឡេកទៅយល់នូវសត្វអណ្តើក ទ្រង់មិនសប្បាយព្រះហឫទ័យសោះ ទើបត្រាស់មើលងាយអណ្តើកនោះថា ៖

"អាសត្វមានខ្លួនប៉ុនអាចម៍ មិនអាចធ្វើទូតកម្មយ៉ាងនេះបានទេ" ។

ឮដូច្នោះ អណ្តើកក៏ផ្តើមពណ៌នាគុណារបស់ខ្លួនថា ៖

"បពិត្រមហារាជ ដែលហៅថាទូត ៗ ចាំបាច់ត្រូវមានខ្លួនប៉ុនដើមត្នោតទៅឬ ? តើព្រះអង្គទ្រង់ឲ្យតម្លៃទៅរូបកាយតូចឬធំជាសំខាន់ឬ ? ឬក៏យកលទ្ធផលការងារដែលសម្រេចបានក្នុងទីដែលខ្លួនទៅ ជាសំខាន់ ? បពិត្រមហារាជ ទូតនៃស្តេចរបស់ពួកទូលបង្គំ មានច្រើន ទូតមនុស្សឲ្យទទួលការងារផ្លូវគោក ទូតបក្សីទទួលការងារផ្លូវអាកាស ទូតបែបដូចទូលបង្គំជាខ្ញុំនេះ គឺព្រះអង្គប្រើធ្វើកិច្ចការក្នុងទឹក ។ ទូលបង្គំជាខ្ញុំជាសត្វអណ្តើក ឈ្មោះថា ចិត្តចូឡោ បានទទួលឋានន្តរសក្តិ និងជាសំណព្វព្រះហឫទ័យ

របស់ព្រះមហាក្សត្រ ដូច្នេះ សូមព្រះអង្គកុំមើលស្រាលលើទូលបង្គំជាខ្ញុំអី ក្រាបទូល" ។

គ្រានោះ ស្តេចធតរដ្ឋៈសួរអណ្តើកថា ៖

"ចុះស្តេចក្រុងពារាណសី បញ្ជូនឯងមកទីនេះ ព្រោះរឿងអ្វីដែរ ?"

អណ្តើកក្រាបទូលថា ៖

"បពិត្រមហារាជ ព្រះរាជាមានព្រះបន្ទូលនឹងទូលបង្គំយ៉ាងនេះថា ព្រះអង្គបានធ្វើមិត្តធម៌ជាមួយនឹងស្តេចទាំងឡាយក្នុងសកលជម្ពូទ្វីបអស់ហើយ ឥឡូវនេះ ព្រះអង្គមានរាជបំណងនឹងថ្វាយរាជធីតារបស់ព្រះអង្គនាមថា **សមុទ្ទជា** ដើម្បីធ្វើមិត្តធម៌ជាសម្ពន្ធមេត្រីភាពជាមួយនឹងស្តេចនាគធតរដ្ឋ លុះត្រាស់ដូច្នេះហើយ ព្រះអង្គក៏បញ្ជូនទូលបង្គំមកទីនេះឯង ។ បពិត្រមហារាជ សូមព្រះអង្គកុំយឺតយូរឲ្យសោះ ក្រាបទូល សូមប្រើរាជបម្រើឲ្យទៅជាមួយនឹងទូលបង្គំ ដេញពេលាកំណត់ថ្ងៃការយកកូនក្រមុំនោះ ក្រាបទូល" ។

ទ្រង់ព្រះសណ្ដាប់ដូច្នោះភ្លាម ស្ដេចធតរដ្ឋៈមានហឫទ័យត្រេកអរជាពន់ពេក បានធ្វើសក្ការៈដល់អណ្ដើកនោះ និងបញ្ជូននាគកំលោះ ៗ ៤ រូប ឲ្យទៅជាមួយនឹងអណ្ដើក ដោយព្រះរាជឱង្ការថា ៖

"អ្នកទាំងឡាយចូរទៅស្ដាប់ព្រះបន្ទូលរបស់ស្ដេចក្រុងពារាណសីកំណត់ថ្ងៃរៀបអាពាហ៍ពិពាហ៍ហើយ ចូរត្រឡប់មកវិញចុះ" ។

"ព្រះករុណាថ្លៃវិសេស" មាណពនាគទាំងឡាយនោះទទួលព្រះរាជបញ្ជាហើយ ក៏ចាប់អណ្ដើកចេញដំណើរអំពីភពនាគ ។

## អណ្ដើកប្រើល្បិចពួនក្នុងស្រះ

អណ្ដើកក្រឡេកឃើញស្រះឈូកមួយនៅរវាងចន្លោះនៃទន្លេយមុនា និងក្រុងពារាណសី វាមានបំណងរត់គេចខ្លួនដោយប្រើឧបាយកលមួយ ទើបនិយាយយ៉ាងនេះថា ៖

"ព្រះរាជារបស់យើងផង បុត្រនិងព្រះមហេសីរបស់ព្រះអង្គផង កាលបើឃើញខ្ញុំដែលជាសត្វត្រេចចរទឹក មកដល់រាជនិវេសន៍ហើយ ពួកទ្រង់តែងតែសុំនូវផ្កាឈូក និងក្រឱឈូក[២៣]អំពីខ្ញុំ ដូច្នេះ

---

[២៣] ខ្នែងដែលបែកចេញពីមើមឈូកទៅ ។

ខ្ញុំនឹងចុះទៅកាច់ផ្កាឈូកទាំងនោះខ្លះ ៗ យកទៅផ្ញើពួកទ្រង់ សូមអស់លោកលែងខ្ញុំទីនេះសិនចុះ កាលបើចាំយូរ មិនឃើញខ្ញុំឡើងមកទេ សូមអស់លោកនាំគ្នាទៅកាន់សម្នាក់ស្តេចមុនក៏បាន ខ្ញុំនឹងទៅជួបពួកលោកឯរាជវាំងឯណោះចុះ"។

ពួកមាណពនាគ ជឿសម្ដីអណ្ដើកហើយក៏លែងទៅ ។ រីឯអណ្ដើកទៅពួននៅនឹងកន្ទែងដ៏កំបាំងមួយក្នុងស្រះនោះ ។ នាគមាណពពីរនាក់រង់ចាំអណ្ដើកយូរទៅ ៗ មិនឃើញឡើងមកវិញ ក៏គិតថា ប្រាកដជាវាទៅសម្នាក់ព្រះរាជាហើយ ដូច្នេះពួកគេប្រែកាឡាភេទ[២៨]ជាមាណពចូលទៅគាល់ព្រះរាជា ។ ព្រះរាជាធ្វើបដិសណ្ឋារៈ រួចសួរថា ៖

"អ្នកទាំងឡាយ មកអំពីទីណា ?"

"បពិត្រព្រះសម្មតិទេព ពួកទូលបង្គំមកអំពីសម្នាក់របស់ស្ដេចធតរដ្ឋៈ ក្រាបទូល" មាណពឆ្លើយ ។

"ពួកលោកមកទីនេះ ព្រោះកិច្ចការអ្វីដែរ ?" ព្រះរាជាត្រាស់សួរ ។

[២៨] និម្មិតខ្លួនឲ្យប្លែកពីប្រក្រតីដើម ។

"បពិត្រមហារាជ ពួកទូលបង្គំជាខ្ញុំ ជារាជទូតរបស់ស្ដេចធតរដ្ឋៈ ទ្រង់ឲ្យពួកទូលបង្គំចូលមកក្រាបបង្គំទូលសួរព្រះរាជសុខភាព របស់ព្រះអង្គ ក្រាបទូល ។ ប្រសិនបើព្រះអង្គមានរាជបំណង ត្រាស់នូវពាក្យណា សូមទ្រង់មានព្រះបន្ទូលនឹងពួកទូលបង្គំមក ចុះ ។ បានឮដំណឹងថា ព្រះអង្គមានរាជបំណងប្រទានរាជធីតា របស់ព្រះអង្គ នាមថា **សមុទ្ទជា** ឲ្យធ្វើជាមហេសីនៃស្ដេចរបស់ពួក ទូលបង្គំ ពិតមែនឬ ? រតនៈណាមួយដែលមាននៅក្នុងនិវេសន៍ របស់នាគរាជព្រះនាម ធតរដ្ឋ រតនៈទាំងអស់នោះ នឹងក្លាយជា របស់ព្រះអង្គដោយពិត សូមព្រះអង្គទ្រង់ប្រទាននូវរាជធីតា ដល់ ព្រះរាជារបស់ពួកទូលព្រះបង្គំចុះ ក្រាបទូល" ។ នាគមាណព ក្រាបបង្គំទូលថ្វាយ ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយ តបថា ៖

"វិវាហៈ[២៥]ជាមួយនឹងពួកនាគដែលជាសត្វតិរច្ឆាននោះ គឺយើង មិនធ្លាប់ធ្វើក្នុងកាលណាម្ដងទេ យើងទាំងឡាយមានកំណើតជា

[២៥] ការនាំកូនស្រីទៅលំនៅឋានកូនប្រុស រៀបមង្គលការ ។

មនុស្ស នឹងចងសម្ពន្ធមេត្រីភាពជាមួយនឹងសត្វតិរច្ឆានដែលមាន
កំណើតមិនសមគួរនោះ ដូចម្តេចកើត ?”

ព្ទដូច្នោះ មាណពនាគទាំងឡាយក្រាបទូលថា ៖

“ប្រសិនបើសម្ពន្ធភាពជាមួយនឹងនាគរាជធតរដ្ឋៈ មិនសមគួរដល់
ព្រះអង្គមែននោះ តើហេតុអ្វី ព្រះអង្គបញ្ជូនទូតអណ្តើកឈ្មោះថា
**ចិត្តចូឡោ** ឧបដ្ឋាករបស់ព្រះអង្គ ទៅកាន់សម្នាក់ស្តេចនៃពួកទូល
បង្គំ ហើយក្រាបទូលថា ព្រះអង្គនឹងប្រទាននូវរាជធីតា សមុទ្ទជា
របស់ព្រះអង្គអ៊ីចឹង ? ឥឡូវនេះ ព្រះអង្គបែរជាមើលងាយចំពោះ
ស្តេចរបស់ពួកទូលបង្គំទៅវិញ ណ្ហើយចុះ ពួកទូលបង្គំដឹងថាគួរ
ធ្វើយ៉ាងណាចំពោះព្រះអង្គហើយ ព្រោះថា ពួកទូលបង្គំជាខ្ញុំ
គឺជានាគមាណព ”

និយាយដូច្នេះហើយ នាគមាណពទាំងឡាយ បានគំរាមដូច្នេះថា ៖

“បពិត្រព្រះអង្គជាធំជាងមនុស្ស ព្រះជន្មក្តី ដែនដីរបស់ព្រះអង្គក្តី
នឹងត្រូវវិនាសបង់ដោយពិត កាលបើព្រះអង្គធ្វើឲ្យនាគដែលមាន
អានុភាពខ្លាំងយ៉ាងនេះខឹងក្រោធហើយ ព្រះរាជាទាំងឡាយ ដូច
ជាព្រះអង្គនេះ នឹងត្រូវអស់ព្រះជន្មទៅដោយឆាប់ មុខតែត្រូវ

អន្តរធាន[២៦]ទៅក្នុងចន្លោះពុំខាន ។ បពិត្រព្រះសម្មតិទេព ព្រះអង្គជាមនុស្សមិនមានឫទ្ធិ ហ៊ានមើលងាយព្រះរាជាដែលមានឫទ្ធិ ជាកូនបង្កើតនៃព្រះបាទវរុណៈ ដែលកើតក្នុងទន្លេយមុនានេះផង !" ។

គ្រានោះព្រះរាជាត្រាស់តបថា ៖

"យើងមិនមើលងាយព្រះបាទធតរដ្ឋដ៏មានយសទេ ព្រោះថា ព្រះបាទធតរដ្ឋ ជាធំជាងនាគទាំងឡាយដ៏ច្រើន ក្នុងនាគពិភពទំហំ ៥០០ យោជន៍ ។ ស្ដេចធតរដ្ឋ បើទុកជាមានអានុភាពខ្លាំងក្លាយ៉ាងនោះក៏ដោយ ក៏ទ្រង់មិនសក្តិសមនឹងធីតារបស់យើងទេ ព្រោះថា ស្ដេចនោះមានកំណើតជាពស់ ចំណែកខាងយើងជាក្សត្រិយ៍របស់អ្នកដែនវិទេហៈ សមុទ្ទជាធីតារបស់យើង ជាមួយនឹងរាជបុត្រនៃស្ដេចវិទេហៈ ទើបមានជាតិដ៏ប្រសើរដូចគ្នា ។ គេទាំងពីររូបសមគួររួមសំរាសជាមួយគ្នា ។ សមុទ្ទជានោះ មិនសក្តិសមនឹងពស់ដែលមានកង្កែបជាចំណីទេ" ។

---

[២៦] ការបាត់, ការខូចបង់, វិនាស, អន្តរាយ ។ ខ្មែរប្រើជាកិរិយាសព្ទ ថា បាត់, ខូចបង់ វិនាស ។

## នាគមាណពថ្វាយដំណឹងដល់ស្តេចធតរដ្ឋ

មាណពនាគទាំងឡាយ មានបំណងធ្វើគុតព្រះមហាក្សត្រអង្គនោះដោយខ្យល់ប្រមុះ ក្នុងទីនោះភ្លាម ៗ តែម្តង, តែពួកគេបានគិតថា ៖

"ព្រះរាជាយើង បញ្ជូនយើងមកដើម្បីឲ្យកំណត់ថ្ងៃរៀបអាពាហ៍-ពិពាហ៍ទេតើ, ដូច្នេះ យើងមិនគួរសម្លាប់ព្រះរាជាអង្គនេះហើយត្រឡប់ទៅវិញទេ ពួកយើងទៅក្រាបទូលស្តេចរបស់យើងសិនទើបដឹងថាគួរធ្វើយ៉ាងណាទៀត"

នាគមាណពគិតដូច្នេះហើយ ក៏អន្តរធានបាត់ក្នុងទីនោះឯង ។

ស្តេចធតរដ្ឋសួរថា ៖

"នែអ្នកទាំងឡាយ ពួកអ្នកបានរាជធីតាហើយឬ ?"

មាណពនាគទាំងឡាយ កំពុងតែខឹងស្រាប់ផង ក៏បានប្រាប់នូវព្រះបន្ទូលដែលស្តេចក្រុងពារាណសីបានត្រាស់ហើយផង និងមិនបានត្រាស់ផង បណ្តាលឲ្យព្រះបាទធតរដ្ឋទ្រង់ព្រះពិរោធ ដោយពួកគេបានក្រាបបង្គំទូលយ៉ាងនេះ ៖

"បពិត្រព្រះសម្មតិទេព ព្រះអង្គបញ្ជូនពួកយើងទៅកន្លែងដែលមិនត្រូវទំនង ព្រោះហេតុអ្វី ? ប្រសិនបើព្រះអង្គមានរាជបំណងសម្លាប់ពួកទូលបង្គំ សូមសម្លាប់ក្នុងទីនេះមកចុះ ។ ស្ដេចក្រុងពារាណសីនោះ បានជេរផ្ដាសាចំពោះព្រះអង្គ លើកតម្កើងកូនស្រីរបស់ខ្លួនដោយជាតិមានះ" ។

ស្ដេចធតរដ្ឋ: បានចេញរាជបញ្ជាប្រកាសឲ្យបរិស័ទរបស់ខ្លួនមកជួបជុំគ្នា រួចមានរាជបន្ទូលថា ៖

"ពួកនាគឈ្មោះកម្ពលស្សតរា ដែលអាស្រ័យនៅឯបាតភ្នំព្រះសុមេរុ[២៧] ជាញាតិខាងព្រះមាតាយើង ចូរក្រោកឡើង ចូរប្រាប់នាគទាំងអស់ក្នុងទិសានុទិសឲ្យមកប្រជុំគ្នាឲ្យឆាប់" ។

---

[២៧] ( ន. ) [--មេ-រុ ឬ--ម៉ែ"] or សុមេរ៍ ( សំ., បា. ) (សុមេរុ "ភ្នំបៀតបៀនទូវភ្នំទាំងពួងដោយកម្ពស់របស់ខ្លួន គឺភ្នំខ្ពស់ជាងភ្នំទាំងអស់ក្នុងសាកលលោក") ឈ្មោះភ្នំមួយធំខ្ពស់ចម្បង ជាទីតាំងនៃត្រៃត្រិង្សសួគ៌ ដែលជាឋានរបស់ព្រះឥន្ទ្រ។ ពាក្យថា នេរុ, មេរុ, សិនេរុ, តិទិវាធរ, សុរគិរី, សុរាទ្រិ, សុរាស្រ័យ សុទ្ធតែជាឈ្មោះរបស់ភ្នំនេះឯង ប៉ុន្តែខ្មែរប្រើពាក្យ សុមេរុ ឬ សុមេរុ៍ ជាង : *ឋានត្រៃត្រិង្ស ឋិតនៅលើភ្នំព្រះសុមេរ៍*(ហៅសុមេរុបពត៌ ឬ សុមេរុរាជ ក៏បាន) ។

គ្រានោះ នាគទាំងអស់ឮរាជប្រកាសនោះហើយ ក៏ប្រញាប់ប្រញាល់មកប្រជុំគ្នា រួចសួរស្តេចធតរដ្ឋថា ៖

"បពិត្រព្រះសម្មតិទេព ព្រះអង្គហៅពួកទូលបង្គំមក ព្រោះទ្រង់មានព្រះរាជកិច្ចអ្វី ក្រាបទូល ?"

ស្តេចធតរដ្ឋត្រាស់ថា ៖

"នាគទាំងឡាយ ចូរទៅកាន់ក្រុងពារាណសី" ។

នាគទាំងឡាយទូលសួរថា ៖

"បពិត្រព្រះសម្មតិទេព ពួកទូលបង្គំត្រូវទៅធ្វើអ្វីនៅទីនោះ ? ពួកទូលបង្គំ ចាំបាច់ត្រូវកម្ទេចនគរនោះឲ្យទៅជាផេះ ដោយសន្ទុះខ្យល់ពីច្រមុះឬ ?"

ស្តេចធតរដ្ឋ ហេតុតែមានហឫទ័យប្រតិព័ទ្ធចំពោះរាជធីតា **សមុទ្ទជា** ដូច្នោះ ព្រះអង្គមិនប្រាថ្នាការវិនាសដល់ព្រះរាជធីតាទេ ទើបត្រាស់ថា ៖

"បណ្តាពួកឯងទាំងអស់គ្នា នរណាក៏ដោយ ក៏មិនត្រូវបៀតបៀនមនុស្សអ្នកក្រុងពារាណសីណាម្នាក់ឡើយ" ។

គ្រានោះ នាគទាំងឡាយសួរស្ដេចធតរដ្ឋៈថា ៖

"ប្រសិនបើ មិនឲ្យបៀតបៀនមនុស្សខ្លះទេ ពួកទូលបង្គំទៅទីនោះ ដើម្បីបំពេញរាជកិច្ចអ្វីទៅវិញ ក្រាបទូល ?"

គ្រានោះ ស្ដេចធតរដ្ឋៈតបថា ៖

"អ្នកទាំងឡាយ ដែលមានសរីរៈធំ ចូរសំយុងខ្លួនក្នុងនិវេសនដ្ឋានទាំងឡាយ ក្នុងស្រះ ត្រង់ផ្លូវដើរ ត្រង់ព្រះលាន លើចុងឈើ និងលើខ្លោងទ្វារ ។ ចំណែកខាងខ្ញុំ មានកាយធំ សម្បុរសសុទ្ធ នឹងទៅព័ន្ធព័ទ្ធនូវរាជបុរីដ៏ធំទូលាយ ដោយភ្នែនទាំងឡាយ និងញ៉ាំងភ័យឲ្យកើត ឡើងដល់ពួកអ្នកដែនកាសី" ។

## ស្ដេចក្រុងពារាណសីថ្វាយរាជធីតាដល់ស្ដេចនាគ

គ្រានោះ នាគទាំងឡាយទាំងពួង បានធ្វើតាមរាជបញ្ជានោះ ។ នាគទាំងឡាយ មានសម្បុរដ៏ច្រើន បានស្ដាប់រាជបញ្ជារបស់ព្រះបាទធតរដ្ឋ ហើយ ក៏ចូលទៅកាន់ក្រុងពារាណសី តែមិនបានបៀតបៀនបុគ្គលណាមួយឡើយ ។ នាគទាំងឡាយ ដែលមានសរីរៈធំ ៗ ក៏សំយុងខ្លួនក្នុងនិវេសនដ្ឋាន ក្នុងស្រះ ត្រង់ផ្លូវដើរ ត្រង់ព្រះលាន លើចុងឈើ និង

លើខ្លោងទ្វារ ។ នារីទាំងឡាយជាច្រើន បានឃើញនាគទាំងនុំះកំពុងសំយុងខ្លួន លុះឃើញពួកនាគបើកពពារ[២៨] ឲ្យសំឡេងរឿយ ៗ ដូច្នោះ ក៏កើតការភ័យខ្លាចយំកន្ទក់កន្ទេញ ។ ពួកជនក្នុងក្រុងពារាណសី កើតការតក់ស្លុតក្ដៅក្រហាយ ក៏លើកដៃសំពះយំកន្ទក់កន្ទេញទូលសុំព្រះរាជារបស់ខ្លួន ឲ្យព្រះអង្គប្រទានរាជធីតាដល់នាគរាជ ។

ស្ដេចក្រុងពារាណសី ទ្រង់ទើបតែទម្រេតបិដ្ឋិផ្ទំមិនទាន់លង់លក់នៅឡើយទេ ស្រាប់តែឮសំឡេងយំខ្សឹកខ្សួលរបស់ពួកអ្នកនគរផង របស់ករិយាទាំងឡាយផង ទ្រង់ពិតជាភិតភ័យចំពោះមរណៈយ៉ាងខ្លាំង ព្រោះទ្រង់ត្រូវបាននាគមាណពទាំងឡាយគំរាមហើយ ដូច្នោះព្រះអង្គបានស្រែកមួយអង្គឯងបីដងខ្លាំង ៗ ថា ៖

"យើងនឹងថ្វាយរាជធីតារបស់យើងដល់ស្ដេចធតរដ្ឋ ៗ" ។

ឮដូច្នោះហើយ ស្ដេចនាគទាំងឡាយទាំងពួងបានដកកម្លាំងថយពីកន្លែងនោះទៅចម្ងាយ ៣ គាវុត បាននិម្មិតនគរមួយដូចជាទេវនគរ

---

[២៨] ( ន. ) អាការសម្ដើមរបស់ពស់ ដែលប្រឹងដំឡើងកឲ្យរីកធំជាងប្រក្រតី : *ពស់ដកពពារ ។*

ស្នាក់នៅទីនោះ ហើយបញ្ជូនគ្រឿងបណ្ណាការនិងរាជសាសន៍ទៅថ្វាយស្តេចធនញ្ជ័យថា ៖

"សូមព្រះអង្គបញ្ជូនរាជធីតាមកឲ្យយើង" ។

ស្តេចក្រុងពារាណសី ទទួលនូវគ្រឿងបណ្ណាការហើយឲ្យពួកគេត្រឡប់ទៅវិញ ដោយព្រះរាជតម្រាស់ថា ៖

"អ្នកទាំងឡាយ អញ្ជើញទៅវិញចុះ យើងនឹងឲ្យពួករាជអាមាត្យនាំរាជធីតារបស់យើងទៅថ្វាយស្តេចរបស់អស់លោកជាខាងក្រោយ"

មានព្រះរាជឱង្ការដូច្នេះហើយ ទ្រង់បានឲ្យរាជបម្រើទៅយាងព្រះរាជធីតាចូលគាល់ រួចព្រះអង្គទ្រង់នាំរាជធីតាឡើងទៅប្រាសាទជាន់លើ បើកសីហបញ្ជរ[២៩] ពន្យល់ផ្តែផ្តាំព្រះរាជធីតាឲ្យចងចាំថា ៖

---

[២៩] (ព. ប្រ.) បង្អួចរបស់លោកអ្នកមានអានុភាពដូចសីហៈ គឺបង្អួចដំណាក់ឬប្រាសាទរបស់ក្សត្រិយ៍ទ្រង់រាជ្យ : *ព្រះរាជាទ្រង់ប្រថាប់ក្បែរសីហបញ្ជរ*។ ឬ បង្អួចមានរង្វង់ដូចជាទ្រង់ជំហរសីហៈ ។

"ហៃបុត្រីសម្លាញ់បិតា ចូរបុត្រីមើលទុំះ ជានគរដែលគេតុបតែង យ៉ាងវិចិត្រ បុត្រីនឹងបានធ្វើជាអគ្គមហេសីរបស់ស្តេចធតរដ្ឋ: សោយរាជ្យក្នុងនគរនោះ ។ នគរនោះនៅមិនឆ្ងាយអំពីនគររបស់ យើងនេះប៉ុន្មានទេ ក្នុងពេលបុត្រីកើតការអផ្សុក បុត្រីអាចមក នគរយើងនេះបាន, ឥឡូវនេះ បុត្រីត្រូវទៅកាន់នគរនោះដោយ ខានពុំបាន"

ពន្យល់ដូច្នេះហើយ ទ្រង់ឲ្យពួកអ្នកបម្រើផ្ទូតព្រះសីសៈបុត្រី តុបតែង ដោយគ្រឿងអលង្ការទាំងពួង ឲ្យគេលើកដាក់លើយានដែលមាន ដំបូល បិទបាំងដោយវាំងនន រួចទ្រង់ឲ្យពួករាជអាមាត្យនាំទៅ ។ ស្តេច នាគទាំងឡាយ ធ្វើការក្រោកទទួល ហើយធ្វើនូវសក្ការៈដ៏ធំថ្វាយព្រះ រាជធីតា ។ អាមាត្យទាំងឡាយ ចូលទៅកាន់នគរថ្វាយព្រះរាជធីតា នោះដល់ស្តេចធតរដ្ឋ រួចត្រឡប់មកវិញដោយបាននាំយកទ្រព្យសម្បត្តិ ជាច្រើនមកជាមួយផង ។ ពួកគេបាននាំព្រះរាជធីតាឡើងកាន់ប្រាសាទ ដាក់ឲ្យផ្ទំលើក្រឡាបន្ទំជាទិព្វដែលតុបតែងយ៉ាងល្អវិចិត្រ ។ រំពេចនោះ នាគញីទាំងឡាយ កាឡាភេទជាមនុស្សគមជាដើម មកចោមរោមគាល់ បម្រើព្រះរាជធីតា មើលទៅដូចជាអ្នកបម្រើដែលមានភេទជាមនុស្ស ដូច្នោះដែរ ។ រាជធីតាសមុទ្ទជា គ្រាន់តែដាក់ព្រះកាយទម្រេតលើ ក្រឡាបន្ទំជាទិព្វភ្លាម បានប៉ះនឹងសម្ផស្សទិព្វ ក៏លង់លក់មួយរំពេច ។

ស្ដេចធតរដ្ឋ បានមកចាប់បីរាជធីតាសមុទ្ទជា បាំងបាត់ខ្លួនអំពីទីនោះ ព្រមទាំងនាគបរិស័ទ ទៅប្រាកដខ្លួននៅនាគពិភពព្រមគ្នាវិញ ។ រាជធីតា ទ្រង់តើនឡើងភ្លាម ស្រាប់តែទតឃើញក្រឡាបន្ទំទិព្វមានក្បាច់រចនាដ៏វិចិត្រ និងប្រាសាទមាស ប្រាសាទកែវមណី ឧទ្យាន ស្រះបោក្ខរណីជាដើម ព្រមទាំងនាគពិភព ដែលប្រៀបបានទៅនឹងទេវនគរដ៏ស្រស់សោភា ព្រះរាជធីតាក៏ត្រាស់សួរបម្រើគមជាដើមថា ៖

"នគរនេះ មានសោភណភាពអ្វីម្ល៉េះហ្ន៎ ! មិនដូចជានគររបស់យើងទេ តើជារបស់អ្នកណាទៅហ្ន៎ ?"

បម្រើទាំងឡាយ ក្រាបទូលថា ៖

"នគរនេះជារបស់ស្វាមីនៃព្រះនាងម្ចាស់, បពិត្រព្រះទេវី បុគ្គលអ្នកមានបុណ្យតិច មិនអាចបាននូវសម្បត្តិបែបនេះទេ ព្រះនាងបានសម្បត្តិបែបនេះ ព្រោះព្រះនាងមានបុណ្យច្រើន" ។

ចំណែកព្រះបាទធតរដ្ឋៈ ទ្រង់បានចេញរាជបញ្ជាឲ្យគេទូងស្គរ ក្នុងភពនាគដែលមានទំហំ ៥០០ យោជន៍ ជាសេចក្ដីជូនដំណឹងថា ៖

"នាគណាហ៊ានបង្ហាញព្រះនាងសមុទ្ទជា នូវភេទជាពស់ នាគនោះនឹងត្រូវទទួលរាជអាជ្ញាខាងតែបាន" ។

ពួកនាគទាំងអស់បានឮរាជប្រកាសនោះហើយ គ្មាននាគណាមួយហ៊ានបង្ហាញភេទជាពស់របស់ខ្លួនឲ្យព្រះនាងសមុទ្ទជាឃើញឡើយ ។ រីឯព្រះនាងសមុទ្ទជា ទ្រង់តែងរីករាយសប្បាយ នៅរួមសំវាសដោយក្តីស្រឡាញ់ជាមួយនឹងស្តេចធតរដ្ឋ ក្នុងភពនាគនោះ ដោយគិតស្មានថាជាមនុស្សលោក ។

នគរកណ្ឌ ចប់ ។

# ជំពូកទី៣

## កំណើតព្រះភូរិទត្ត

## ឧបោសថកណ្ឌ

### សមុទ្ទជាមានរាជបុត្រ ៤ អង្គ

*ចំណេរកាលតមក ដោយអាស្រ័យការនៅរួមជាមួយនឹងស្តេចធតរដ្ឋនោះ ព្រះនាងសមុទ្ទជាបានតាំងព្រះគភ៌ ហើយប្រសូតបានបុត្រមួយ ប្រទាននាមថា "**សុទស្សនៈ**" ពីព្រោះបុត្រនោះមើលទៅគួរឲ្យស្រឡាញ់ ។ ក្រោយមក ព្រះនាងបានប្រសូតបុត្រមួយទៀត ប្រទាននាមថា "**ទត្តៈ**" ។ ទត្តៈនោះឯង គឺជាតួអង្គព្រះបរមពោធិសត្វ ។ ព្រះនាងប្រសូតបុត្រលើកទី ៣ ដាក់នាមថា "**សុភោគៈ**" លើកទី ៤ ដាក់ នាមថា "**អរិដ្ឋៈ**" ។*

*សរុបសេចក្តីមក ព្រះនាងសមុទ្ទជាទ្រង់មានព្រះរាជបុត្រចំនួន ៤ អង្គ ។ ទោះបីជាយ៉ាងនេះក៏ដោយ ព្រះនាងក៏នៅតែមិនបានដឹងថា ទីនោះគឺជាភពនាគឡើយ មើលទៅយល់ថា ជាភពមនុស្សធម្មតា ៗ ។ លុះដល់ថ្ងៃមួយ នាគមាណពទាំងឡាយ បានប្រាប់រាជកុមារអរិដ្ឋថា ៖*

"ព្រះមាតារបស់រាជបុត្រ ជាស្រីមនុស្ស មិនមែនជានាងនាគទេ" ។

ថ្ងៃមួយ ខណៈពេលដែលកុមារអរិដ្ឋៈនោះកំពុងតែបៅដោះព្រះមាតា ស្រាប់តែនឹកគិតចង់សាកល្បងម្ដាយមើល ក៏និម្មិតខ្លួនជាពស់ សំយុងចុងកន្ទុយទម្លាក់ទៅលើខ្នងជើងព្រះមាតា ។ ព្រះនាងទតឃើញខ្លួនពស់របស់បុត្រដូច្នោះ កើតភ័យតក់ស្លុតស្រែកខ្លាំង ៗ ចាប់បោកពស់នោះទៅនឹងដី បណ្ដាលឲ្យភ្នែករបស់កុមារអរិដ្ឋៈនោះបែកខ្ទាក់ម្ខាង ដោយសារប៉ះនឹងក្រចក ។ ឈាមបានហូរចេញអំពីភ្នែកនោះយ៉ាងសស្រាក់ ។ ស្ដេចធតរដ្ឋ ឮសម្រែករបស់ព្រះនាងដូច្នោះ ត្រាស់សួរថា "មហេសីយើងស្រែក ព្រោះរឿងអ្វី ?" លុះទ្រង់ជ្រាបនូវទង្វើដែលអរិដ្ឋកុមារបានធ្វើដូច្នោះ ស្ដេចទ្រង់យាងមកគំរាមថា ៖

"អ្នកទាំងឡាយ ចូរចាប់អាខ្ញុំបម្រើនោះយកទៅសម្លាប់ចោល" ។

ព្រះរាជធីតាសមុទ្ទជាដឹងថាព្រះស្វាមីកំពុងពិរោធ, ហេតុតែស្រឡាញ់បុត្រ ព្រះនាងក៏ក្រាបទូលអង្វរថា ៖

"បពិត្រសម្មតិទេព ភ្នែកម្ខាងនៃបុត្ររបស់ខ្ញុំម្ចាស់បែកហើយ សូមព្រះអង្គអត់ទោសគេផង ក្រាបទូល" ។

រីឯស្តេចធតរដ្ឋ កាលបើព្រះនាងមានព្រះសវនីយ៍យ៉ាងនេះ ទ្រង់បាន អត់ទោសដោយពោលថា ៖

"តើនឹងបង់ធ្វើដូច្នោះដូចម្តេចបាន ?"

ក្នុងថ្ងៃនោះ ព្រះនាងសមុទ្ទជាទើបដឹងច្បាស់ថា "ឋានដែលព្រះនាង កំពុងរស់នៅនោះគឺជាភពនាគ" ។ មួយទៀត តាំងអំពីគ្រានោះមក អរិដ្ឋៈតែងត្រូវគេហៅថា **កាណារិដ្ឋៈ** ។ ក្រោយមក បុត្រទាំង ៤ អង្គ របស់ព្រះនាងសមុទ្ទជា ក៏បានចម្រើនវ័យវឌ្ឍនាការធំឡើង ។

## សក្កទេវរាជថ្វាយនាមពោធិសត្វថា ភូរិទត្ត

គ្រានោះ រាជបិតាដ៏មានយសធំនោះ បានបែងចែកឲ្យបុត្រមួយ អង្គ ៗ នូវទឹកដី ១០០ យោជន៍ ៗ សម្រាប់សោយរាជ្យ ។ រាជបុត្រមួយ អង្គ ៗ ដែលសោយរាជ្យក្នុងតំបន់នោះ ៗ មាននាគកញ្ញា ១៦០០០ នាក់ ហែហមចោមរោម ដោយរៀង ៗ ខ្លួន ។ រាជាណាចក្ររបស់ព្រះបិតា មានត្រឹមតែមួយរយយោជន៍ប៉ុណ្ណោះ ។ រាជបុត្រទាំង ៣ តែងមក ក្រាបបង្គំទូលសួរសុខទុក្ខព្រះមាតាបិតាជារៀងរាល់ខែ ។ ចំណែក ព្រះពោធិសត្វ លោកតែងមកក្រាបបង្គំទូលសួរសុខទុក្ខព្រះមាតាបិតា រាល់កន្លះខែម្តង ។ រាល់បញ្ហាដែលកើតមានឡើងក្នុងភពនាគនោះ

មានតែព្រះពោធិសត្វមួយអង្គប៉ុណ្ណោះ ដែលមានសមត្ថភាពដោះស្រាយ ។ ព្រះពោធិសត្វតែងយាងទៅកាន់ទីឧបដ្ឋានរបស់ស្ដេចវិរូបក្ខមហារាជ ជាមួយនឹងព្រះបិតា សូម្បីបញ្ហាដែលកើតឡើងក្នុងសម្នាក់របស់ស្ដេចវិរូបក្ខមហារាជនោះ ក៏ព្រះពោធិសត្វទ្រង់ចេញមុខដោះស្រាយដែរ ។ តមកក្នុងថ្ងៃមួយ ស្ដេចវិរូបក្ខមហារាជទ្រង់យាងទៅឋានតាវត្តិង្ស[៣០] មួយអន្ទើដោយនាគបរិស័ទ អង្គុយចោមរោមហែហមសក្កទេវរាជ ស្រាប់តែមានបញ្ហាមួយបានកើតឡើង ក្នុងជំនុំនៃពួកទេវតា ។ គ្មាននរណាមួយអាចដោះស្រាយបញ្ហានោះបានឡើយ មានតែព្រះមហាសត្តប៉ុណ្ណោះ ដែលមានសេចក្ដីអង់អាចក្លាហាន ឡើងគង់លើបល្ល័ង្កដ៏បវរ ហើយដោះស្រាយបញ្ហា ។ គ្រានោះ ទេវរាជបូជាព្រះពោធិសត្វដោយគ្រឿងក្រអូបនិងបុប្ផានានា ព្រមទាំងបានថ្វាយព្រះនាមដល់ពោធិសត្វថា "**ភូរិទត្ត**" ដោយមានព្រះរាជឱង្ការថា ៖

> "ម្នាលទត្ត អ្នកប្រកបព្រមដោយប្រាជ្ញាដ៏ទូលំទូលាយ ស្មើដោយផែនប្រឹថពី ចាប់ពីគ្រានេះតទៅ អ្នកចូរមានឈ្មោះថា **ភូរិទត្ត**" ។

---

[៣០] ( ន. ) *[តាវ័ត-តឹង]* ( *បា., សំ.* ) (តាវត្តឹស; ត្រយស្រ្តឹសតិ) ឈ្មោះឋានកាមាវចរ-សួគ៌ជាន់ទី ២ (ឋានត្រ័យត្រិង្ស) ។

តាំងអំពីកាលដែលព្រះភូរិទត្តពោធិសត្វ បានទៅកាន់ទីឧបដ្ឋានរបស់សក្កទេវរាជមក ព្រះអង្គតែងឃើញនូវសម្បត្តិរបស់សក្កទេវរាជ ដែលប្រដាប់ដោយវេជយន្តប្រាសាទ ដេរដាសដោយស្រីទេពអប្សរទាំងឡាយ ជាទីមនោរម្យយ៉ាងក្រៃលែង ទ្រង់មានសេចក្តីពេញចិត្តក្នុងទេវលោក ទ្រង់មានព្រះតម្រិះថា ៖

"អត្តភាពស៊ីកង្កែបនេះ មានប្រយោជន៍អ្វីដល់អញ អញត្រឡប់ទៅកាន់ភពនាគវិញហើយ នឹងរក្សាឧបោសថ ធ្វើនូវហេតុដែលនាំឲ្យកើតក្នុងទេវលោកនេះឲ្យបាន"

ទ្រង់ព្រះតម្រិះដូច្នេះហើយ ភូរិទត្តទៅកាន់ភពនាគវិញ ក៏បានក្រាបបង្គំលាព្រះមាតាបិតាថា ៖

"បពិត្រព្រះមាតាបិតា ទូលបង្គំជាខ្ញុំនឹងធ្វើនូវឧបោសថកម្ម" ។ មាតាបិតាតបថា ៖

"ប្រពៃណាស់បុត្រ ! ចូរធ្វើចុះ ប៉ុន្តែបុត្រកុំទៅធ្វើនៅខាងក្រៅឲ្យសោះ ចូរធ្វើក្នុងវិមានស្ងាត់មួយកន្លែងក្នុងភពនាគនេះបានហើយ ព្រោះថា នាគទាំងឡាយកាលទៅខាងក្រៅ តែងតែមានភ័យធំកើតឡើង ណាបុត្រ !" ។

**ភូរិទត្តរក្សាឧបោសថ**

ព្រះពោធិសត្វយល់ព្រមធ្វើតាមព្រះបន្ទូលរបស់ព្រះមាតាបិតា ហើយនៅរក្សាឧបោសថក្នុងវិមានស្ងាត់មួយ ក្នុងរាជឧទ្យាននាពិភពនាគនោះឯង ។ គ្រានោះ នាគកញ្ញាទាំងឡាយ មានដៃកាន់នូវតូរ្យតន្ត្រីនានា មកចោមរោមព្រះពោធិសត្វ ដេញដំប្រគំផ្គុំកូតថ្វាយព្រះអង្គ ។ ព្រះពោធិសត្វគិតថា ៖

"ឧបោសថកម្មរបស់អញ នឹងមិនសម្រេចដល់ទីបំផុតទេ កាលបើអញនៅទីនេះ, បើដូច្នេះ គួរតែអាត្មាអញទៅធ្វើឧបោសថកម្មនៅឋានមនុស្សលោកវិញ"

ដោយខ្លាចព្រះមាតាបិតាឃាត់ ដូច្នេះព្រះពោធិសត្វទ្រង់មិនបានទៅក្រាបបង្គំលាពួកទ្រង់ទេ ហៅតែពួកមហេសីរបស់ព្រះអង្គមកជួបរួចប្រាប់ថា ៖

"នែ៎អូនសម្លាញ់ បងនឹងទៅកាន់មនុស្សលោក រឿនដេកលើក្បាលដំបូក នៅក្បែរដើមជ្រៃមួយ ដែលដុះទៀបឆ្នេរទន្លេយមុនា ហើយអធិដ្ឋានឧបោសថប្រកបដោយអង្គ ៨ ដេកធ្វើឧបោសថកម្ម ។ កាលខ្ញុំដេកធ្វើឧបោសថកម្មពេញមួយរាត្រីហើយ ដល់វេលា

អរុណរះឡើង ពួកនាងចូរនាំស្ត្រី ១០ នាក់ ៗ កាន់តូរ្យតន្ត្រី ថ្វាស់គ្នាទៅកាន់សម្នាក់របស់ខ្ញុំ បូជាខ្ញុំដោយគ្រឿងក្រអូបទាំងឡាយផង ដោយផ្កាទាំងឡាយផង ច្រៀងរាំ ហើយយកខ្ញុំមកកាន់ភពនាគវិញចុះ"

ផ្ដែផ្ដាំដូច្នេះហើយ ព្រះពោធិសត្វទៅទីនោះ រៀនដេកលើក្បាលដំបូកអធិដ្ឋានឧបោសថប្រកបដោយអង្គ ៤ ថា ៖

"ជនណាប្រាថ្នាត្រូវការនូវស្បែកក្ដី សរសៃក្ដី ឆ្អឹងក្ដី ឈាមក្ដី របស់អញ ជននោះចូរយកចុះ" ហើយនិម្មិតខ្លួនប៉ុនក្បាលនង្គ័ល (នង្គ័លសីសប្បមាណំ សរីរំ...) ដេករៀនធ្វើនូវឧបោសថកម្ម ។

នាកាលអរុណរះឡើង នាគមាណវិកាទាំងឡាយមកបដិបត្តិតាមពាក្យបណ្ដាំហើយ នាំព្រះពោធិសត្វទៅកាន់ភពនាគវិញ ។ កាលដែលព្រះពោធិសត្វធ្វើនូវឧបោសថតាមទំនងនេះ ពេលវេលាក៏ចេះតែកន្លងហួសទៅវែងឆ្ងាយ ។

ឧបោសថកណ្ឌ ចប់ ។

# ជំពូកទី៤

## គរុឡុកណ្ឌ

### ព្រាហ្មណ៍និងសោមទត្តដើរព្រៃ

គ្រានោះ ព្រាហ្មណ៍មួយនាក់មានលំនៅឋានជិតទ្វារនៃក្រុងពារាណសី គាត់តែងទៅក្នុងព្រៃជាមួយនឹងកូនឈ្មោះថាសោមទត្ត បង់សំណាញ់ ដាក់អន្ទាក់យន្ត បោះសូល សម្លាប់ម្រឹគទាំងឡាយ រែកសាច់ដោយសង្រែកយកទៅលក់ចិញ្ចឹមជីវិត ។ ក្នុងថ្ងៃមួយ ព្រាហ្មណ៍នោះរកមិនបានអ្វី ដោយហោចទៅសូម្បីតែទន្សោងមួយក្បាល គាត់បាននិយាយនឹងកូនថា ៖

> "នែ៎សោមទត្តកូន ប្រសិនបើយើងទៅទាំងដៃទទេបែបនេះ ម្ដាយឯងប្រាកដជាប្រឡោតខឹងមិនខានឡើយ ដូច្នេះយើងនឹងរកអ្វីឲ្យបានខ្លះសឹមទៅណាកូន"

និយាយដូច្នេះរួច គាត់បានដើរឈមមុខឆ្ពោះទៅចំដំបូក ដែលព្រះពោធិសត្វដេក ។ គាត់បានឃើញនូវស្នាមជើងរបស់ម្រឹគទាំងឡាយ ដែលដើរចុះទៅកាន់ទន្លេយមុនាដើម្បីផឹកទឹក ក៏ប្រាប់កូនថា ៖

"នែ៎សោមទត្តកូន នេះនែ៎ផ្លូវម្រឹគដើរទេតើ ឯងចូរថយទៅឈរនៅឲ្យស្ងៀម អញនឹងចាំបាញ់ម្រឹគដែលមកផឹកទឹក"

ដូច្នេះហើយ គាត់ក៏ទៅឈរពួននៅទីងគល់ឈើមួយដើមឃើតផ្ទ សម្ងឹងរកមើលម្រឹគ ។ គ្រានោះ ម្រឹគមួយដើរមករកផឹកទឹក ក្នុងវេលាល្ងាច ។ ព្រាហ្មណ៍ក៏បាញ់ម្រឹគនោះ ។ ម្រឹគមិនដួលនៅទីនោះតែម្តងទេ វាត្រូវកូនសរមុតជាប់ ក៏ស្ទុះរត់បោលទៅទាំងមានឈាមហូរសស្រាក់ ។ ឪពុកនិងកូនដេញតាមម្រឹគនោះ ចាប់បានហើយក៏ពន្លះយកសាច់នៅទីដែលម្រឹគដួល ។ ពួកគេចេញអំពីព្រៃ ដើរមកដល់ដើមជ្រៃនោះ ក្នុងវេលាសុរិយាអស្តង្គត គិតថា ៖

"ឥឡូវនេះ សុរិយាក៏អស្តង្គតទៅហើយ យើងមិនអាចធ្វើដំណើរទៅមុខទៀតបានទេ យើងនឹងស្នាក់នៅទីនេះ"

គិតដូច្នេះហើយ ក៏រៀបចំទុកដាក់សាច់ក្នុងទីសមគួរ រួចពួកគេឡើងដេកលើប្រគាបឈើ ។ ដល់វេលាអរុណរះឡើង ព្រាហ្មណ៍ភ្ញាក់ពីដំណេក ផ្ទៀងត្រចៀកស្តាប់សូរម្រឹគដើរ ។

## ព្រាហ្មណ៍ជួបភូរិទត្ត

ក្នុងខណៈនោះ នាគមាណវិកាទាំងឡាយ មកក្រាលបុប្ផាសនៈថ្វាយភូរិទត្ត ។ ព្រះពោធិសត្វភូរិទត្ត ប្ដូរភេទពីអត្តភាពពស់ទៅជាអត្តភាពទេវតា ដែលប្រដាប់ដោយអលង្ការទាំងពួង ឡើងប្រថាប់លើបុប្ផាសនៈ ដោយដំណើរកែក្រាយដូចជាសក្កទេវរាជ ។ ចំណែកនាគមាណវិកាទាំងឡាយ បានបូជាព្រះពោធិសត្វដោយគ្រឿងក្រអូបនិងផ្កាកម្រងជាដើម ហើយប្រគំតូរ្យតន្ត្រីជាទិព្វ និងការរាំច្រៀងយ៉ាងគគ្រឹកគគ្រេង ។ ព្រាហ្មណ៍ឮសូរសំឡេងនោះ គិតថា "នុ៎ះជាសំឡេងអ្វី, អញត្រូវដឹងសំឡេងនោះឲ្យបាន" ដូច្នេះគាត់ក៏ដាស់កូនដែលកំពុងដេកថា កូន ៗ តែកូនមិនភ្ញាក់សោះ គាត់គិតថា "វាមិនព្រមភ្ញាក់សោះ ប្រហែលជាវាហត់នឿយខ្លាំងហើយ ឲ្យវាដេកចុះ អញនឹងទៅតែម្នាក់ឯង" គាត់ចុះពីដើមឈើ ដើរតម្រង់ទៅកាន់សម្នាក់នៃព្រះពោធិសត្វ ។ នាគមាណវិកាទាំងឡាយ ឃើញព្រាហ្មណ៍នោះដើរមក ក៏នាំគ្នាមុជជ្រែកចូលទៅក្នុងដីព្រមទាំងនាំយកតូរ្យតន្ត្រីទៅជាមួយផងទៅកាន់កពនាគរបស់ខ្លួនវិញ នៅសល់តែព្រះពោធិសត្វមួយរូបប៉ុណ្ណោះ ។ ព្រាហ្មណ៍ ដើរទៅកាន់សម្នាក់របស់ព្រះពោធិសត្វសួរថា ៖

"អ្នកជាអ្វី មានភ្នែកក្រហម មានចន្លោះស្មាទូលាយ អង្គុយកណ្ដាលព្រៃ គួរជាទីបូជាដោយផ្កាឈើ ស្រីទាំង ១០ នាក់ ដែលទ្រទ្រង់នូវសង្វារ ជាវិការៈនៃមាស មានសំពត់ដ៏ល្អ កំពុងឈរសំពះ តើត្រូវជាអ្វីនឹងអ្នក ។ អ្នកជាអ្វី មានដៃធំ រុងរឿងនៅកណ្ដាលព្រៃ ដូចភ្លើងឆេះនូវថ្នាំងខ្លាញ់ អ្នកជាយក្សណាមួយដែលមានសក្តិធំ ឬអ្នកជានាគមានអានុភាពធំ ?"

ព្រូដូច្នោះ ភូរិទត្តគិតថា

"ប្រសិនបើអញប្រាប់គាត់ថាអញនេះជាទេវបុត្រមួយអង្គ បណ្ដាបណ្ដាទេវតាទាំងឡាយមានសក្កទេវរាជជាដើម ព្រាហ្មណ៍នេះនឹងជឿអញពុំខាន ប៉ុន្តែក្នុងថ្ងៃនេះ គួរណាស់តែអញនិយាយតែពាក្យសច្ចៈតែម្យ៉ាង"

ព្រះតម្រិះដូច្នេះហើយ ព្រះពោធិសត្វបានប្រាប់នូវអត្តភាពជានាគរាជរបស់ខ្លួនដល់ព្រាហ្មណ៍នោះថា ៖

"ខ្ញុំជានាគមានឫទ្ធិ មានតេជះដែលអ្នកផងទាំងពួកកន្លងមិនបាន ប្រសិនបើខ្ញុំក្រោធខឹង ខ្ញុំអាចចឹកមនុស្សច្រើនដល់ទៅមួយខេត្តបាន ខេត្តទាំងមូលព្រមទាំងផែនដី នឹងក្លាយជាផេះផង់ដោយ

តេជះគឺចង្កូមរបស់ខ្ញុំ ។ ឯមាតារបស់ខ្ញុំនាមសមុទ្ទជា បិតារបស់ខ្ញុំនាមធតរដ្ឋ ខ្ញុំជាប្អូននៃនាគរាជឈ្មោះសុទស្សនៈ ជនទាំងឡាយតែងហៅខ្ញុំថា ភូរិទត្ត ៗ យ៉ាងនេះ ក្នុងភពនាគដែលមានទំហំ ៥០០ យោជន៍" ។

## ភូរិទត្តនាំព្រាហ្មណ៍និងកូនទៅភពនាគ

លុះនិយាយយ៉ាងនេះហើយ ព្រះពោធិសត្វមានព្រះតម្រិះថា ៖

"ព្រាហ្មណ៍នេះកាចឃោរឃៅណាស់ គេនឹងប្រាប់ដល់អាលម្ពាយ ហើយធ្វើនូវសេចក្តីអន្តរាយដល់ឧបោសថកម្មរបស់អញ បើដូច្នោះ មានតែអញនាំនូវព្រាហ្មណ៍នេះទៅភពនាគ រួចហើយឲ្យយសដ៏ធំដល់គេ កាលបើយ៉ាងនេះ អញនឹងបានឱកាសធ្វើឧបោសថកម្មបានយូរអង្វែងតទៅ" ។

គ្រានោះ នាគរាជភូរិទត្តប្រាប់ព្រាហ្មណ៍ថា ៖

"ម្នាលព្រាហ្មណ៍ ខ្ញុំនឹងឲ្យយសដ៏ធំដល់អ្នក ភពនាគជា ទីរមណីយដ្ឋាន តោះពួកយើងទៅទីនោះ" ។

ព្រាហ្មណ៍តបថា ៖

"បពិត្រភូរិទត្ត ខ្ញុំមានកូនមួយឈ្មោះសោមទត្ត ខ្ញុំទៅសួរគេសិន បើគេព្រមទៅ ខ្ញុំនឹងត្រឡប់មកវិញ" ។

ព្រះពោធិសត្វប្រាប់ថា ៖

"ទៅចុះព្រាហ្មណ៍ ទៅនាំគេមក"

រួចព្រះពោធិសត្វប្រាប់អំពីលំនៅរបស់ខ្លួនថា ៖

"លោកគង់តែឃើញនូវអន្លង់ទឹកដ៏ជ្រៅ ដែលហូរគួចវិលសព្វ ៗ កាល ជាអន្លង់ទឹកគួរឲ្យខ្លាច អន្លង់ទឹកជាទិព្វនោះ គឺជាលំនៅរបស់ខ្ញុំ មានជម្រៅច្រើនរយនៃជួរបុរស ។ អ្នកកុំខ្លាច ចូរចូលទៅកាន់ស្ទឹងយមុនា មានទឹកខៀវ ដែលហូរមកអំពីកណ្តាលព្រៃ ជាកន្លែងដែលមានបក្សីក្ងោកនិងក្រៀល យំលើឆ្នេរទាំងសងខាង ជាស្ទឹងត្រជាក់ក្សេមក្សាន្ត ជាលំនៅរបស់ពួកអ្នកមានវត្ត មានអាចារៈ, ម្នាលព្រាហ្មណ៍ ចូរទៅនាំកូនអ្នកមក" ។

ព្រាហ្មណ៍បានទៅប្រាប់រឿងនោះដល់កូនរបស់ខ្លួន ហើយក៏នាំគេមកជួបព្រះពោធិសត្វ ។ បានយកឪពុកកូនពីរនាក់នោះ ទៅកាន់ឆ្នេរទន្លេយមុនា លុះទៅដល់ទៀបឆ្នេរព្រះពោធិសត្វប្រាប់ថា ៖

"ម្នាលព្រាហ្មណ៍ អ្នកព្រមទាំងកូនទៅដល់ភពនាគនោះហើយ នឹងបានប្រពន្ធ ម្នាលព្រាហ្មណ៍ យើងនឹងបូជាអ្នកដោយកាមទាំងឡាយរបស់យើង អ្នកចូររស់នៅក្នុងភពនាគនោះប្រកបដោយសេចក្ដីសុខចុះ" ។

និយាយយ៉ាងនេះហើយ ព្រះភូរិទត្តពោធិសត្វ បាននាំឪពុកកូនពីរនាក់នោះទៅកាន់ភពនាគ ដោយអានុភាពរបស់ខ្លួន ។ អត្តភាពជាទិព្វក្នុងភពនាគបានកើតប្រាកដដល់ជនទាំងពីរនាក់ឪពុកកូននោះ ។ គ្រានោះភូរិទត្តបានឲ្យនូវទិព្វសម្បត្តិដល់គេទាំងពីរនាក់ និងប្រទាននូវនាគកញ្ញាក្នុងមួយនាក់ចំនួន ៤០០ ។ ឪពុកកូនពីរនាក់នោះ បានសោយនូវមហាសម្បត្តិ ។ រីឯភូរិទត្តពោធិសត្វ បានធ្វើឧបោសថកម្មដោយសេចក្ដីមិនប្រមាទ ។ កន្លះខែក្រោយមក ភូរិទត្តបានទៅកាន់ទីឧបដ្ឋានរបស់មាតាបិតា សម្ដែងនូវធម្មកថា បន្ទាប់ពីនោះ ព្រះពោធិសត្វបន្តដំណើរទៅកាន់សម្នាក់របស់ព្រាហ្មណ៍ សាកសួរសុខទុក្ខហើយប្រាប់ថា ៖

"អ្នកត្រូវការរបស់ណា ចូរប្រាប់ខ្ញុំមកចុះ ចូររីករាយ កុំអផ្សុកអ្វីឡើយ"

ព្រះភូរិទត្តពោធិសត្វធ្វើនូវបដិសណ្ឋារៈចំពោះសោមទត្តហើយ បានត្រឡប់ទៅកាន់សម្នាក់របស់ខ្លួនវិញ ។ ព្រាហ្មណ៍នៅក្នុងភពនាគបាន

តែមួយឆ្នាំប៉ុណ្ណោះ ក៏កើតសេចក្ដីអផ្សុក ព្រោះហេតុតែខ្លួនមានបុណ្យតិចតួច ទើបមានប្រាថ្នាចង់ទៅមនុស្សលោកវិញ ។ ចំពោះគាត់ ភពនាគក្នុងពេលនោះ ប្រៀបដូចជាលោកន្តរនរក ប្រាសាទដែលតុបតែងយ៉ាងល្អវិចិត្រ ដូចពន្ធនាគារ នាគកញ្ញាដែលស្អិតស្អាងខ្លួនយ៉ាងស្អាត ៗ ប្រៀបបាននឹងជាយក្ខិនីទៅវិញ ។ ព្រាហ្មណ៍គិតថា "អញអផ្សុកអ្វីម្ល៉េះ តើសោមទត្តកូនអញគេអផ្សុកឬទេហ្ន៎ ?", គិតដូច្នេះហើយ ក៏ចូលទៅរកសោមទត្តហើយសួរថា ៖

"ហៃសោមទត្តកូន តើអ្នកអផ្សុកឬទេ ?"

កូន "អផ្សុកព្រោះហេតុអ្វីទៅ ខ្ញុំមិនអផ្សុកទេ ពុកអផ្សុកមែនទេ ?"

ឪពុក "អើ មែនហើយកូន" ។

កូន "ពុកអផ្សុកព្រោះហេតុអ្វី ?"

ឪពុក "អញអផ្សុក ព្រោះមិនបានឃើញម្ដាយឯង និងបងប្អូនប្រុស បងប្អូនស្រីរបស់ឯង តោះសោមទត្តកូន យើងទៅវិញ" ។

កូន  "ខ្ញុំមិនទៅវិញទេពុក"

ទោះជាសោមទត្តជាកូនឆ្លើយបដិសេធយ៉ាងនេះក៏ដោយ តែឪពុកបាន អង្វរគេរឿយ ៗ ជាហេតុធ្វើឲ្យគេប្រកែកមិនបាន ក៏យល់ព្រមថាទៅ ។

## ព្រាហ្មណ៍លាព្រះពោធិសត្វឋានទៅមនុស្សលោកវិញ

ព្រាហ្មណ៍គិតថា "អញបបួលកូនអញបានហើយ ប៉ុន្តែបើអញ ក្រាបទូលព្រះភូរិទត្តថាអញអផ្សុក ព្រះអង្គប្រាកដជាឲ្យនូវយសដ៏ធំ ក្រៃលែងដល់អញថែមទៀត កាលបើយ៉ាងនេះ ដំណើរវិលត្រឡប់ទៅ ឋានមនុស្សលោករបស់អញនឹងមិនបានសម្រេចឡើយ ។ បើដូច្នេះ អញនឹងប្រើឧបាយ[៣១]មួយ ដោយការពណ៌នាសម្បត្តិរបស់ព្រះភូរិទត្ត នោះហើយសួរព្រះអង្គថា ព្រះអង្គលះបង់រាជសម្បត្តិបែបនេះទៅកាន់ មនុស្សលោក ធ្វើឧបោសថកម្ម ព្រោះហេតុអ្វី កាលបើទ្រង់ឆ្លើយថា ដើម្បីកើតនៅឯឋានសួគ៌ អញនឹងក្រាបទូលព្រះអង្គថា ព្រះអង្គលះបង់

[៣១] (ន.) (សំ.),(បា.) (អ៊ុ--) ល្បិច, ល្បិចល្បង, កិច្ចកល; ផ្លូវគំនិត; កលមាយា : មាន ឧបាយល្អ, ប្រើឧបាយ ។ (ពាក្យកាព្យ) : ឧបាយកម្មាយប្រាប់ការណ៍ពិត ប៉ុន្តែគំនិត ស្លូតស្រាល់ជាង បើមានប្រាជ្ញាក្លាវៃវាង ច្រើនតែមិនឃ្លាងចាកប្រយោជន៍ ។ **ឧបាយកល** ឬ **កលឧបាយ** ល្បិចល្បងយ៉ាងល្អិត; ឧបាយបញ្ឆោត ។

នូវរាជសម្បត្តិបែបនេះធ្វើឧបោសថកម្មដើម្បីកើតក្នុងឋានសួគ៌ សូម្បីទូលព្រះបង្គំដែលចិញ្ចឹមជីវិតដោយទ្រព្យរបស់អ្នកដទៃ ក៏នឹងទៅឋានមនុស្សលោកវិញ ជួបជុំញាតិទាំងឡាយហើយចេញសាងផ្នួសធ្វើសមណធម៌ដែរ ។ កាលបើដូច្នេះ នាគភូរិទត្តប្រាកដជាអនុញ្ញាតឲ្យអញទៅមិនខាន" ។ ក្នុងថ្ងៃមួយ ព្រះពោធិសត្វមកសួរថា ៖

"ម្នាលព្រាហ្មណ៍ តើអ្នកអផ្សុកឬទេ ?"

ព្រាហ្មណ៍ក្រាបទូលថា ៖

"អ្វី ៗ ដែលព្រះអង្គប្រទានចំពោះទូលបង្គំ មិនមានខ្វះខាតបន្តិចបន្តួចឡើយ"

គាត់ឆ្លើយត្រឹមប៉ុណ្ណោះហើយ ក៏ផ្ដើមពោលពណ៌នានូវសម្បត្តិរបស់ព្រះពោធិសត្វ តាំងពីខាងដើម ដោយមិននិយាយអ្វីទាក់ទងនឹងដំណើរទៅឋានមនុស្សលោករបស់ខ្លួនឡើយ ។ គាត់និយាយដូច្នេះថា ៖

"ផែនដីក្នុងភពនាគរបស់ព្រះអង្គនេះ មានផ្ទៃរាបស្មើដោយជុំវិញគ្រប់ទិស ដេរដាសដោយគ្រាប់ខ្សាច់ជាមាសប្រាក់ កែវមណី កែវមុក្តា មានដើមក្រស្នាច្រើន ដេរដាសដោយមេភ្លៀងពណ៌មាស

និងមានស្មៅពណ៌ខៀវស្រងាត់ស្រស់ល្អ មានព្រៃគួរជាទីរីករាយ ស្រះបោក្ខរណីទាំងឡាយ ដែលបុញ្ញកម្មរបស់ព្រះអង្គនិម្មិតល្អ ហើយ វាជាទីរីករាយ មានសំឡេងបក្សីហង្សយំពីពោះវង់រណ្ដំ មានត្របកផ្កាឈូកដែលរីកស្គុសស្គាយ ត្រសាយត្រសុំ ល្អត្រសោល ហើយធ្លាក់ចុះអណ្ដែតដេរដាសលើផ្ទៃជលសា ។ សសរមានជ្រុង ៨ ដែលគេធ្វើល្អហើយ សោតសឹងតែធ្វើអំពីកែវពៃទូរ្យ ទាំងអស់នេះ មាននៅក្នុងប្រាសាទទាំងឡាយរបស់ព្រះអង្គ ដែលមានសសរ ១០០០ ដ៏ពេញដោយនាគកញ្ញាភ្លឺរុងរឿង ។ ព្រះអង្គបាននូវវិមានជាទិព្វបែបនេះ ដោយបុណ្យរបស់ព្រះអង្គ ជាវិមានមិនចង្អៀត ជាទីក្សេមក្សាន្ត គួរជាទីរីករាយ ប្រកបដោយសេចក្ដីសុខយ៉ាងក្រៃលែង ។ ទូលព្រះបង្គំកត់សម្គាល់ថា ការធ្វើឧបោសថកម្មរបស់ព្រះអង្គ មិនមែនព្រោះហេតុតែទ្រង់ប្រាថ្នានូវវេជយន្តប្រាសាទ ដែលជាវិមានរបស់ព្រះឥន្ទ្រាធិរាជជាស្ដេចនៃទេវតានោះទេ ព្រោះថាឫទ្ធិអំណាចរបស់ព្រះអង្គនេះ ជាឫទ្ធិអំណាចដ៏រុងរឿងទូលំទូលាយដែរ ព្រះអង្គប្រាកដជាប្រាថ្នានូវឋានៈផ្សេងធំលើសឋានៈរបស់ព្រះឥន្ទ្រនោះទៅទៀត” ។

ឮដូច្នោះ ព្រះភូរិទត្តពោធិសត្វត្រាស់ថា ៖

"កុំនិយាយយ៉ាងហ្នឹងឡើយព្រាហ្មណ៍ យសរបស់យើង បើប្រៀបនឹងយសរបស់សក្កទេវរាជ វាដូចជាគ្រាប់ស្ពៃនៅជិតភ្នំព្រះសុមេរុអ៊ីចឹង ! សូម្បីត្រឹមតែអ្នកបម្រើរបស់ស្តេចសក្កទេវរាជនោះ ក៏យើងមិនអាចវាយតម្លៃបានផង" ។

ព្រះពោធិសត្វមានព្រះបន្ទូលដូច្នេះបន្តទៀតថា ៖

"អានុភាពរបស់ព្រះឥន្ទ្រ យសរបស់ព្រះឥន្ទ្រ មិនអាចដឹងបានដោយការគិតត្រឹមមួយថ្ងៃ ពីរថ្ងៃ បីថ្ងៃ ឬបួនថ្ងៃ ហើយវាយតម្លៃថាមានប៉ុណ្ណេះ ប៉ុណ្ណោះបានឡើយ ។ សូម្បីតែស្តេចលោកបាលទាំង ៤ និងទេវរាជទាំងឡាយ ក៏ជាអ្នកបម្រើរបស់ព្រះឥន្ទ្រ យកព្រះឥន្ទ្រជាមេដឹកនាំដែរ ដូច្នេះ យសរបស់យើងមានកំណើតជាសត្វតិរច្ឆាន មានតម្លៃមិនដល់ត្រឹមតែមួយចំណែក បណ្តាចំណែកទាំង ១៦ នៃយសរបស់លោកបាលទាំង ៤ ដែលមានឋានៈត្រឹមតែជាអ្នកបម្រើក្រោមអំណាចព្រះឥន្ទ្រនោះផង" ។

ព្រះពោធិសត្វមានព្រះបន្ទូលបន្ថែមថា ៖

"ខ្ញុំឮពាក្យអ្នកថា វិមានរបស់យើងនេះប្រៀបបាននឹងវិមានរបស់ស្ដេចសក្កទេវរាជ ខ្ញុំក៏រឭកដល់វិមាននោះ ។ ពិតមែន ខ្ញុំប្រាថ្នាវេជយន្តប្រាសាទនោះ ទើបបានជាព្យាយាមធ្វើឧបោសថកម្ម" ។

រួចព្រះពោធិសត្វបានប្រាប់សេចក្ដីប្រាថ្នារបស់ខ្លួន ដល់ព្រាហ្មណ៍ថា ៖

"ខ្ញុំប្រាថ្នាវិមាននោះ របស់ទេវតាទាំងឡាយ អ្នកមានអាយុវែង អ្នកស្វែងរកសេចក្ដីសុខ ហើយឋិតនៅក្នុងសេចក្ដីសុខ យ៉ាងមាំ ដូច្នេះបានជាខ្ញុំរក្សាឧបោសថ ដេកលើក្បាលដំបូក" ។

ព្រាហ្មណ៍ឮដូច្នោះ មានសោមនស្សថា "ឥឡូវនេះអញបានឱកាសហើយតើ !" ក៏បានក្រាបទូលលាព្រះពោធិសត្វដោយពាក្យដូច្នេះ ៖

"ឯទូលបង្គំនិងកូនដើរស្វែងរកម្រឹគ បានចូលទៅកាន់ព្រៃ ញាតិទាំងឡាយរបស់ទូលបង្គំ ពួកគេមិនដឹងថា ទូលបង្គំស្លាប់ឬក៏រស់ទេ ។ ទូលបង្គំសូមក្រាបបង្គំលាព្រះអង្គ ជារាជបុត្រនៃព្រះរាជធីតាក្នុងដែនកាសី ព្រះអង្គដ៏មានយស បើទ្រង់ព្រមរាជានុញ្ញាត ទូលបង្គំទាំងពីរនាក់នឹងបានទៅជួបពួកញាតិក្រាបទូល" ។

គ្រានោះ ព្រះពោធិសត្វមានបន្ទូលតបថា ៖

"ឱ ! នុ៎ះពិតជាសេចក្តីពេញចិត្តរបស់ខ្ញុំហើយត្រង់ដែលអ្នកនៅក្នុងសម្នាក់របស់ខ្ញុំ ព្រោះថា កាមទាំងឡាយប្រាកដដូច្នេះ អ្នកមិនងាយនឹងបានទេ នៅក្នុងមនុស្សលោក ។ ខ្ញុំបូជាដោយកាមទាំងឡាយរបស់ខ្ញុំចំពោះអ្នក បើអ្នកមិនចង់នៅទេ ខ្ញុំនឹងអនុញ្ញាតឲ្យអ្នកទៅជួបជុំពួកញាតិដោយសួស្តីចុះ" ។

ព្រះពោធិសត្វមានបន្ទូលដូច្នេះហើយ មានរាជតម្រិះដូច្នេះថា ៖

"ព្រាហ្មណ៍នេះអាស្រ័យកែវមណីហើយ នឹងរស់នៅដោយស្រួល
នឹងមិនប្រាប់ដល់នរណាម្នាក់ឡើយ អញ
នឹងឲ្យកែវមណីដែលឲ្យសេចក្តីប្រាថ្នាគ្រប់យ៉ាង
ដល់ព្រាហ្មណ៍នុ៎ះ"គិត ដូច្នេះរួច
បានឲ្យកែវមណីនោះដល់ព្រាហ្មណ៍ដោយពោលថា ៖

"អ្នកកាលទ្រទ្រង់កែវមណីជាទិព្វនេះ រមែងបានតាមតម្រូវការនូវសត្វចិញ្ចឹមផង បុត្រទាំងឡាយផង អ្វីផ្សេង ៗ ផង ដោយអានុភាពនៃកែវមណីនេះ អ្នកចូរមិនមានរោគ បានសេចក្តីសុខម្នាលព្រាហ្មណ៍ អ្នកចូរយកនូវកែវមណីនេះ ហើយទៅចុះ" ។

គ្រានោះ ព្រាហ្មណ៍តបថា ៖

"បពិត្រព្រះភូរិទត្ត ស្រួលហើយ ពាក្យរបស់អ្នក ជាកុសលមិនមានទោស ខ្ញុំត្រេកអរនឹងព្រះបន្ទូលរបស់ព្រះអង្គ ខ្ញុំមិនជំទាស់ទេ ប៉ុន្តែ ខ្ញុំមានវ័យចាស់ហើយ ដូច្នោះខ្ញុំនឹងបួស ខ្ញុំមិនប្រាថ្នាកាមទេ កែវមណី មានប្រយោជន៍អ្វីដល់ខ្ញុំទៅ" ។

ភូរិទត្តពោធិសត្វថា ៖

"ការនៅក្នុងព្រហ្មចរិយៈ គឺជាការធ្វើបានដោយកម្រ ប្រសិនបើមានការបែកធ្លាយព្រហ្មចរិយៈ ចំពោះអ្នកដែលមិនត្រេកអរនឹងផ្នួស កិច្ចការដែលត្រូវធ្វើដោយភោគៈទាំងឡាយ រមែងមានដល់អ្នកកាលសឹកទៅជាគ្រហស្ថ អ្នកកុំមានសេចក្តីវង្វេងសឡើយ គប្បីមករកយើង យើងនឹងឲ្យទ្រព្យដ៏ច្រើនដល់អ្នក" ។

ព្រាហ្មណ៍ថា ៖

"បពិត្រព្រះភូរិទត្ត ស្រួលហើយ ខ្ញុំត្រេកអរនឹងព្រះបន្ទូលរបស់ព្រះអង្គ ប្រសិនបើមានសេចក្តីត្រូវការ ខ្ញុំនឹងមកម្តងទៀត" ។

គ្រានោះ ភូរិទត្តដឹងថាព្រាហ្មណ៍មិនចង់នៅទីនោះ ក៏បង្គាប់នាគមាណព ៤ នាក់ឲ្យនាំយកព្រាហ្មណ៍ឡើងពីទន្លេយមុនា ដាក់លើផ្លូវជាទីទៅកាន់ក្រុងពារាណសី ក្នុងឋានមនុស្សលោកវិញ យ៉ាងប្រញាប់ ។

នាគទាំង ៤ កាលត្រូវភូរិទត្តប្រើទៅ ទទួលស្តាប់ពាក្យនោះ នាំគ្នាមុជចុះក្រោក នាំដំណើរព្រាហ្មណ៍ឲ្យដល់ផ្លូវក្រុងពារាណសី យ៉ាងលឿន ។

## ព្រាហ្មណ៍ដេញទាយតាព្រាហ្មណ៍

ចំណែកព្រាហ្មណ៍ធ្វើដំណើរប្រាប់កូនបណ្តើរថា "នែ៎សោមទត្តកូន នេះជាកន្លែងដែលយើងធ្លាប់បាញ់បានម្រឹគមួយ កន្លែងនេះ យើងធ្លាប់បាញ់បានជ្រូកព្រៃមួយ" គាត់ដើរទៅមុខ បានជួបស្រះបោក្ខរណី ក្នុងចន្លោះផ្លូវ និយាយនឹងកូនថា ៖

"នែ៎សោមទត្តកូន តោះយើងងូតទឹក" ។

"បាទ ពុក" សោមទត្តនិយាយតប ។

អ្នកទាំងពីរដោះនូវអាភរណៈនិងសម្លៀកបំពាក់ជាទិព្វ ចងជាបង្វិចដាក់ទុកក្បែរឆ្នេរស្រះបោក្ខរណី ហើយចុះងូតទឹក ។ រំពេចនោះឯងអាភរណៈនិងសម្លៀកបំពាក់ជាទិព្វទាំងឡាយ បានអន្តរធានបាត់ ទៅកាន់ភពនាគវិញ ។ សំពត់ស្លៀកកញ្ចាស់ពីមុន បានមកប្រាកដពាក់ខ្លួនប្រាណរបស់ឪពុកនិងកូនពីរនាក់នោះ បន្ទាប់មក ធ្នូ សរ និងលំពែងក៏ពាក់សៀតជាប់នឹងខ្លួនដូចដើម។ ចំណែកសោមទត្ត ខ្សឹកខ្សួលថា ៖

"បពិត្រឪពុក ឪពុកធ្វើឲ្យយើងហិនហោចអស់ហើយ" ។

គ្រានោះ ព្រាហ្មណ៍លួងលោមកូនថា ៖

"កុំព្រួយ អ្វីឡើយ កូន ! កាលបើម្រឹគទាំងឡាយមាន យើងនឹងសម្លាប់ម្រឹគទាំងឡាយនោះក្នុងព្រៃចិញ្ចឹមជីវិត" ។

រីឯម្តាយរបស់សោមទត្ត ឮដំណឹងនៃដំណើរមកដល់របស់ប្តីនិងកូន គាត់បានមកទទួលនាំទៅផ្ទះ រៀបបាយទឹកឲ្យពិសាស្កប់ស្កល់ ។ រីឯព្រាហ្មណ៍ពិសាហើយ ដេកលក់ទៅ ។ ចំណែកខាងម្តាយសួរកូនថា ៖

"នែ៎កូន មួយរយៈកាលនេះ កូនឯងនិងឪពុកឯងទៅឯណា ?" ។ កូនប្រាប់ថា ៖

"បពិត្រអ្នកម៉ែ មាននាគរាជមួយឈ្មោះ **ភូរិទត្ត** នាំឪពុកនិងខ្ញុំទៅកាន់ភពនាគ, នៅទីនោះ យើងអផ្សុកពេក ទើបបានត្រឡប់មកវិញឥឡូវនេះ" ។

"ចុះឯងបានយកកែវកងថ្លៃ ៗ មកខ្លះទេ" ម្តាយសួរ ។

"មិនយកមកទេ ម៉ែ" កូនឆ្លើយ។

"ចុះនាគរាជនោះ មិនឲ្យអ្វីដល់ឯងនិងឪពុកឯងខ្លះទេឬ?"

ម្ដាយសួរ ។

"ម៉ែ ភូរិទត្តនាគរាជ បានឲ្យកែវមណីដែលអាចឲ្យសម្រេចក្ដីប្រាថ្នាគ្រប់យ៉ាង ដល់ឪពុកដែរ ប៉ុន្តែឪពុកគាត់មិនយកទេ" កូនឆ្លើយ ។

"ព្រោះហេតុអ្វី?" ម្ដាយសួរ ។

"ឮថា គាត់នឹងបួសទៀតផង ណាម៉ែ" កូនឆ្លើយ ។

ម្ដាយខឹងថា "មួយរយៈកាលប៉ុណ្ណោះ ឪឯងផ្ទុកកូនឲ្យជាភាររបស់អញនៅដំអក់ឯកពនាគ ឥឡូវនេះឮថានឹងបួសផងអ្ហែ" គាត់ទាញវែកបាយវាយខ្នងព្រាហ្មណ៍ជាប្ដីដែលកំពុងដេកលក់យ៉ាងស្រួល និងគំរាមថា ៖

"នែ៎អាព្រាហ្មណ៍កញ្ចាស់ចង្រៃ ឮថាឯងមិនយកកែវមណីទេ ដោយឯងបំណងថានឹងបួស កាលបើដូច្នេះ ម្ដេចក៏ឯងមិនបួសឲ្យបាត់ ៗ ទៅ ចាំបាច់មកទីនេះធ្វើអ្វីទៀតហ៎ះ? ទៅ ៗ ចេញពីផ្ទះអញឲ្យឆាប់" ។

គ្រានោះ ព្រាហ្មណ៍តបនឹងប្រពន្ធថា ៖

"ហៃអូនសម្លាញ់ កុំខឹងនឹងបងអី ឲ្យតែក្នុងព្រៃមានម្រឹគ គង់តែបងអាចចិញ្ចឹមអូនបាន"

និយាយដូច្នេះហើយ ព្រាហ្មណ៍នោះដើរទៅព្រៃជាមួយនឹងកូន បរបាញ់ចិញ្ចឹមជីវិត ដោយទំនងដូចមុនដដែល ។

## គ្រុឌពាំនាគកាត់ព្រៃ

គ្រានោះ គ្រុឌមួយមានប្រក្រតីនៅក្នុងព្រៃសិម្ពលី ក្នុងទិសភាគនៃមហាសមុទ្រខាងត្បូង វាតែងយកស្លាបបក់ទឹកសមុទ្រឲ្យខ្ចាយហើយខាំក្បាលនាគរាជមួយ ។ មែនពិត គ្រានោះ គ្រុឌទាំងឡាយ ជាសត្វមិនដឹងវិធីសាស្ត្រក្នុងការចាប់នាគទេ, អ្នកសិក្សា នឹងបានជ្រាប ក្នុងបណ្ឌរជាតក តាមក្រោយ ។ ចំណែកគ្រុឌនោះ ចាប់ក្បាលនាគនោះហើយ កាលបើទឹកមិនទាន់ហូរជាប់ជិតដូចដែល វាក៏ពាំក្បាលនាគលើកផុតពីទឹក អូសសំយុងកាត់តាមចុងឈើព្រៃហិមពាន្ត ។ គ្រានោះ មានព្រាហ្មណ៍ម្នាក់ ជាប្រក្រតីគាត់មានលំនៅក្នុងដែនកាសី គាត់បានចេញបួសជាឥសី សាងបណ្ណសាលានៅក្នុងតំបន់ព្រៃហិមពាន្ត ។ នៅចុងទីចង្ក្រមរបស់គាត់ មានដើមជ្រៃដ៏ធំមួយដើម ។ ឥសីនោះ តែងទៅ

សម្រាកពេលថ្ងៃ ទៀបគល់ដើមជ្រៃនោះ ។ រីឯគ្រុឌ ហើរពាំនាគកាត់តាមចុងដើមជ្រៃនោះ ។ នាគសំយុងខ្លួនយកកន្ទុយរុំប្រគាបដើមជ្រៃ ដើម្បីរួចខ្លួនជាចំណីរបស់នាគ ។ គ្រុឌមិនដឹងនាគរុំដើមឈើអ៊ីចឹងទេ គិតតែពីស្ទុះហោះទៅឮដ៏អាកាស ព្រោះហេតុតែខ្លួនមានកម្លាំងខ្លាំង ។ ដើមជ្រៃបានរលើងសណ្ដូកទៅទាំងឫស ។ គ្រុឌបាននាំនាគទៅព្រៃសិម្ពលី ប្រហារដោយចំពុះ ធូតវះពោះរួចស៊ីខ្លាញ់នាគ ហើយចោលសពនាគ ក្នុងផ្ទៃសមុទ្រវិញ ។ ដើមជ្រៃធ្លាក់អំពីកន្ទុយនាគ បានលាន់ឮស្នូរយ៉ាងខ្លាំង ។ គ្រុឌក្រឡេកមើលក្រោមគិតថា "នុ៎ជាះសំឡេងអ្វី" ស្រាប់តែឃើញដើមជ្រៃធ្ងល់ថា "ដើមជ្រៃនុ៎គឺះអញឲ្យវារលើងពីកន្លែងណា" គិតទៅ ៗ ដឹងតាមពិតថា "វាជាដើមជ្រៃដែលដុះនៅចុងទីចង្ក្រមរបស់តាបស" ភ័យខ្លាចក្នុងចិត្តថា "ដើមជ្រៃនេះមានឧបការៈច្រើនដល់តាបសនោះ អញនឹងសួរតាបសនោះមើល ថាតើខ្លួនអញមានបាបឬក៏អត់" គិតដូច្នេះហើយ គ្រុឌប្លែងខ្លួនជាមនុស្សកំលោះម្នាក់ ដើរទៅកាន់សម្នាក់របស់តាបស ។

ក្នុងខណៈនោះ តាបសកំពុងតែពង្រាបទីនោះឲ្យរាបស្មើ ។ ស្ដេចគ្រុឌថ្វាយបង្គំតាបសរួចអង្គុយក្នុងទីសមគួរ សួរធ្វើដូចជាមិនដឹងថា "បពិត្រលោកម្ចាស់ ទីនេះកើតរឿងអ្វីបានជាខូងខ្លាយដីអ៊ីចឹង ?" ។

តាបសថា "ម្នាលឧបាសក មានគ្រុឌមួយចាប់នាគអូសទៅស៊ី នាគស្រវេស្រវារុំប្រគាបដើមជ្រៃដោយកន្ទុយ ដើម្បីរួចខ្លួនជាចំណីគេ ទោះជាយ៉ាងនេះក៏ដោយ គ្រុឌបេះតែស្ទុះហើរទៅ ព្រោះខ្លួនមានកម្លាំងខ្លាំង កាលបើដូច្នេះ ដើមជ្រៃក៏រលើងសណ្ដកទៅតាម នេះឯងជាកន្លែងរលើងនៃដើមជ្រៃនោះ" ។ មាណពសួរថា "បពិត្រលោកម្ចាស់ បាបអកុសល មានដល់គ្រុឌនោះ ឬក៏អត់ទេ" ។ តាបសថា "ប្រសិនបើគេមិនដឹងទេ នោះហៅថាកម្មឥតចេតនា មិនជាអកុសលបាបអ្វីទេ" ។ គ្រុឌសួរ "ចុះបាបនឹងមានដល់នាគឬទេ ?" ។ តាបសថា "នាគនោះគេមិនមែនចាប់ដើមជ្រៃនេះដើម្បីឲ្យវិនាសទេ គេចាប់ដើម្បីរើយករួចខ្លួនប៉ុណ្ណោះ ព្រោះហេតុដូច្នោះ នាគក៏គេមិនមានបាបដូចគ្នា" ។ គ្រុឌត្រេកអរចំពោះតាបស ហើយពោលថា "បពិត្រលោកម្ចាស់ ខ្ញុំនេះជាស្ដេចគ្រុឌដែលចាប់នាគនោះឯង ខ្ញុំត្រេកអរ ចំពោះការដោះស្រាយនូវបញ្ហារបស់លោកម្ចាស់ណាស់ លោកម្ចាស់នៅក្នុងព្រៃ ចំណែកខ្ញុំព្រះករុណាចេះមន្តអាលម្ពាយន៍ (សិល្បវិទ្យាចាប់ពស់) មួយមេ វាជាមន្តកាត់ថ្លៃមិនបានទេ ខ្ញុំព្រះករុណានឹងថ្វាយមន្តនោះជាតម្លៃគ្រូដល់លោកម្ចាស់ សូមលោកម្ចាស់ ទទួលមន្តវិជ្ជានោះចុះ" ។ តាបសថា "អាត្មាជាអ្នកបួស ត្រូវការមន្តអាគមធ្វើអ្វី អញ្ជើញទៅចុះ អ្នកកំលោះ" ។ ស្ដេច គ្រុឌអង្វរតាបសនោះម្ដងហើយម្ដងទៀត ត្រាតែញុំាងតាបសយល់

ព្រមរៀន លុះបង្រៀនមន្តនិងប្រាប់ឱសថពូកែ ៗ ដល់តាបសហើយ គ្រុឌ ក៏លាចៀសចេញទៅ ។

គរុឡកណ្ឌ ចប់ ។

# ជំពូកទី៥

## នាគរាជភូរិទត្តសម្ដែងបង្ហាំ

## តាបសបង្រៀនមន្តចាប់ពស់ដល់ព្រាហ្មណ៍ទុគ៌ត

ក្នុងកាលនោះ ព្រាហ្មណ៍ក្រីក្រម្នាក់ក្នុងក្រុងពារាណសី ជំពាក់បំណុលគេច្រើន ត្រូវពួកម្ចាស់បំណុលទាមទារឲ្យសង គាត់គិតថា "ប្រយោជន៍អ្វីដល់អញ ដោយការរស់នៅទីនេះ ការដែលអញចូលទៅព្រៃហើយស្លាប់ ល្អជាង" គិតរួច គាត់ក៏ចេញអំពីស្រុកចូលទៅព្រៃដើរតាមលំដាប់ ដល់អាស្រមបទនោះ បានញុំាងតាបសឲ្យមានសេចក្ដីត្រេកអរ ដោយវត្តប្រណិប័តន៍ ។ រីឯតាបសគិតថា "ព្រាហ្មណ៍នេះមានឧបការៈច្រើនខ្លាំងណាស់ ដល់អញ អញនឹងឲ្យមន្តទិព្វដែលស្ដេចគ្រុឌថ្វាយ ដល់ព្រាហ្មណ៍នោះ" រួចនិយាយនឹងព្រាហ្មណ៍ថា ៖

"ម្នាលព្រាហ្មណ៍ ខ្ញុំចេះមន្តចាប់ពស់ ខ្ញុំនឹងឲ្យមន្តនោះដល់អ្នក ចូរអ្នករៀនមន្តនោះចុះ" ។

ព្រាហ្មណ៍ថា ៖

"បពិត្រលោកម្ចាស់ កុំឡើយ, ខ្ញុំព្រះករុណាមិនត្រូវការនូវមន្ត ទេ" ។

បើទោះជាយ៉ាងនេះក៏ដោយ តាបស បាននិយាយម្ដងហើយម្ដងទៀត និងសង្កត់សង្កិនញ៉ាំងព្រាហ្មណ៍នោះ ត្រាតែគាត់យល់ព្រមរៀន ហើយ តាបសក៏បានឲ្យមន្តនោះទៅទាំងបាន ប្រាប់នូវឱសថទាំងឡាយដ៏សម គួរដល់មន្តនោះផង និងប្រាប់នូវសព្វ កិច្ចដែលត្រូវធ្វើផ្សេងៗមុននឹង សូធ្យមន្តអាគមនោះផង ។ ព្រាហ្មណ៍គិត ថា "អញបានឧបាយចិញ្ចឹម ជីវិតហើយតើ" ដូច្នេះ នៅតែពីរបីថ្ងៃគាត់ក៏ធ្វើលេសប្រាប់តាបសថា "បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណាកើតរោគ ខ្យល់" តាបសក៏លែង គាត់ ថ្វាយបង្គំតាបស ញ៉ាំងឲ្យតាបសអត់នូវទោសហើយ ធ្វើដំណើរចេញ ចាកព្រៃតាមលំដាប់ រហូតដល់ឆ្នេរទន្លេយមុនា ដើរបណ្ដើរផ្ដើម ស្វាធ្យាយមន្តនោះបណ្ដើរឆ្ពោះទៅកាន់ផ្លូវធំ ។

ក្នុងកាលណោះ នាគមាណវិកាត្រូវជាបម្រើរបស់ភូរិទត្តចំនួន ១.០០០ នាក់ បានយកកែវមណីជាគ្រឿងសម្រេចនូវក្ដីប្រាថ្នាគ្រប់យ៉ាង នោះ ចេញចាកពីភពនាគ បានដាក់លើគំនរខ្សាច់ទៀបឆ្នេរទន្លេយមុនា ហើយនាំគ្នាចុះលេងទឹកពេញមួយរាត្រី ដោយពន្លឺកែវមណីនោះ លុះ ដល់អរុណរះឡើង ពួកនាងបានប្រដាប់ដោយអលង្ការទាំងពួង ហើយ

*អង្គុយចោមរោមកែវមណី ស្រូបយកស្រីសួស្ដី ។ ចំណែកព្រាហ្មណ៍ដើរសូត្រាយធ្យាយមន្ត ក៏ទៅដល់ទីនោះ ។ នាគមាណវិកាទាំងឡាយគ្រាន់តែឮនូវសូរមន្តភ្លាម ភ័យខ្លាចស្លាប់ថា "នេះគ្រុឌមកហើយ !" ស្ទន់ស្ទោចាប់កែវមណីមិនទាន់ ក៏នាំគ្នាមុជជ្រែកដីទៅភពនាគវិញអស់។ ឯព្រាហ្មណ៍ឃើញកែវមណី ចោលភ្នែកទៅឃើញយល់ជាក់កែវមណី គាត់មានចិត្តត្រេកអរថា "ឥឡូវនេះ មន្តរបស់អញសម្រេចផលហើយ" ចាប់កែវមណីធ្វើដំណើរទៅមុខទៀត ។*

## នេសាទព្រាហ្មណ៍ជួបអាលម្ពាយ

*ក្នុងខណៈនោះដែរ នេសាទព្រាហ្មណ៍ ព្រមទាំងកូនសោមទត្តចូលទៅព្រៃដើម្បីបាញ់ម្រឹគ ឃើញកែវមណីនោះក្នុងដៃព្រាហ្មណ៍បាននិយាយនឹងកូនថា ៖*

*"នែ៎កូន ក្រែលោនុ៎ះ ជាកែវមណីដែលភូរិទត្តឲ្យយើង" ។*

*សោមទត្តថា ៖*

*"បាទពុក កែវមណីនុ៎ះឯង" ។*

*នេសាទព្រាហ្មណ៍ថា ៖*

"បើដូច្នោះ មានតែយើងប្រើ ល្បិចពោលទោសកែវមណី បញ្ឆោតព្រាហ្មណ៍នេះ យកកែវមណីនោះ វិញឲ្យបាន" ។

សោមទត្តថា ៖

"ពុក! ដើមឡើយ ពុកមិនយកវាទេ កាលដែលភូរិទត្តឲ្យ ប៉ុន្តែឥឡូវនេះខ្លាច លោតែព្រាហ្មណ៍នុ៎ះវិញទេ បញ្ឆោតពុក ពុកនៅស្ងៀមវិញ ល្អជាង" ។

នេសាទព្រាហ្មណ៍ថា ៖

"មិន អីទេ ឯងចាំមើលចុះ តើព្រាហ្មណ៍នុ៎ះ បញ្ឆោតអញ ឬអញបញ្ឆោតព្រាហ្មណ៍"

ដូច្នេះ កាលនឹងចរចាជាមួយ នឹងព្រាហ្មណ៍អាលម្ពាយ នេសាទព្រាហ្មណ៍បានពោលថា ៖

"អ្នកកាន់យកនូវកែវមណី ដែលសន្មតថាជាមង្គល ជាគ្រឿងឲ្យសម្រេចនូវក្តីប្រាថ្នាគ្រប់យ៉ាង ជាទ្រព្យដ៏ប្រសើរ ជាទីរីករាយនៃចិត្ត ជាថ្មបរិបូណ៌ដោយទ្រង់ទ្រាយ តើអ្នកបានកែវមណីនេះអំពីទីណា ?" ។

គ្រានោះ ព្រាហ្មណ៍អាលម្ពាយឆ្លើយថា ៖

"កាលពីព្រឹកមិញ នាគមាណវិកាប្រមាណ១០០០នាក់មានភ្នែកក្រហម ៗ ចោមរោមជុំវិញកែវមណីនេះ លោតែឃើញខ្ញុំដើរតាមផ្លូវ នាំគ្នាភ័យស្ទន់ស្លោ រត់អស់រលីងចោលកែវមណីនេះ ខ្ញុំក៏រើសវាមក" ។

នេសាទព្រាហ្មណ៍ មានបំណងបញ្ឆោតព្រាហ្មណ៍អាលម្ពាយនោះ ចង់យកកែវមណីដោយខ្លួនឯង ក៏បាននិយាយទោសកែវមណីថា ៖

"កែវមណីនេះ បើបុគ្គលសន្សំទុកល្អ ថែទាំបូជាគ្រប់គ្រងល្អ ទុកដាក់ល្អសព្វកាល គប្បីញ៉ាំងប្រយោជន៍ទាំងពួងឲ្យសម្រេចបាន។ តែកាលបើបុគ្គលជាអ្នកប្រាសចាកការថែទាំ ក្នុងការទុកដាក់ ឬក្នុងការប្រើប្រាស់វិញ កែវមណីនេះ ដែលគេសន្សំទុកដោយមិនត្រូវទំនង នឹងដល់នូវសេចក្តីវិនាស ។ អ្នកជាបុគ្គលមិនឈ្លាសមិនគួរគ្រប់គ្រងកែវមណីជាទិព្វនេះទេ ។ នៅឯផ្ទះរបស់ខ្ញុំ មានច្រើនណាស់ កែវមណីខ្ញុំ ចេះចាប់កែវមណីនោះ ខ្ញុំនឹងឲ្យមាសឆ្តោរ ១០០ ដល់អ្នក អ្នកចូរគ្រប់គ្រងមាសឆ្តោរ ១០០ ចុះ ចូរឲ្យកែវមណីនេះដល់ខ្ញុំមក" ។

សេចក្ដីពិតថា នៅឯផ្ទះនេសាទព្រាហ្មណ៍នោះ សូម្បីតែមាស មួយហ៊ុន ក៏រកមិនបានផង ។ ប៉ុន្តែគាត់អួតថាឲ្យមាសផ្ដោរ ១០០ អ៊ីចឹង ពីព្រោះគាត់បានដឹងហើយថា កែវមណីនោះមានអានុភាពឲ្យសម្រេច សេចក្ដីប្រាថ្នាគ្រប់យ៉ាង ហេតុនោះ គាត់មានគំនិតថា "អញងូតផ្សើម ក្បាល ហើយប្រោះព្រំកែវមណីដោយទឹក ពោលផ្សងថា សូមកែវមណី ឲ្យមាសផ្ដោរ ១០០ ដល់ខ្ញុំ កាលបើដូច្នេះ កែវមណីនុ៎ះនឹងឲ្យដល់អញ តាមប្រាថ្នា អញនឹងឲ្យមាសផ្ដោរ ១០០ នោះ ដល់ព្រាហ្មណ៍" គាត់គិត ឃើញយ៉ាងនេះ ហេតុនោះ បានជាគេក្លៀវក្លាហ៊ានហាមាត់ថាឲ្យមាស ផ្ដោរ ១០០ ។

គ្រានោះ ព្រាហ្មណ៍អាលម្ពាយតបថា ៖

> "កែវមណីនេះ វាជារបស់ខ្ញុំ ខ្ញុំមិនគប្បីលក់ដោយគោ ឬដោយ រតនៈទាំងឡាយ ឬដោយអ្វីណានីយមួយទេ ។ កែវមណីរបស់ខ្ញុំ ដែលកើតអំពីថ្ម បរិបូណ៌ដោយទ្រង់ទ្រាយ ហេតុនោះ ខ្ញុំមិនត្រូវ លក់វាទេ កិច្ចលក់ទោះដោយវត្ថុអ្វីក៏ដោយ មិនមានឡើយ" ។

នេសាទព្រាហ្មណ៍ថា ៖

"បើកែវមណីអ្នកមិនលក់ដោយគោ ឬដោយរតនៈទាំងឡាយទេ ចុះកែវមណីអ្នកនឹងលក់ដោយអ្វី ខ្ញុំសួរអ្នក អ្នកចូរប្រាប់សេចក្តីនោះដល់ខ្ញុំ" ។

ព្រាហ្មណ៍អាម្ពាយថា ៖

"បុគ្គលណាគប្បីបង្ហាញនាគដ៏ធំមានតេជះ ដែលគេកន្ទ្រងបានដោយក្រ ដល់ខ្ញុំ ខ្ញុំនឹងឲ្យកែវមណីដ៏រុងរឿងដោយតេជះដល់បុគ្គលនោះ" ។

នេសាទព្រាហ្មណ៍ថា ៖

"អ្នកជាអ្វី ជាគ្រុឌដ៏ប្រសើរជាងសត្វស្លាបទាំងឡាយ កាលស្វែងរកចំណីដើម្បីខ្លួន ទើបចាប់យកនាគដោយភេទជាព្រាហ្មណ៍នេះឬ ?" ។

អាលម្ពាយ និយាយយ៉ាងនេះថា ៖

"ខ្ញុំមិនមែនជាស្តេចសត្វស្លាបទេ គ្រុឌខ្ញុំមិនដែលឃើញទេ ខ្ញុំជាអ្នកត្រេកអរដោយអាសិរ្ពិស ម្នាលព្រាហ្មណ៍ ជនទាំងឡាយដឹងថា ខ្ញុំ ជាហ្មពស់" ។

នេសាទព្រាហ្មណ៍ថា ៖

"កម្លាំងរបស់អ្នកដូចម្ដេច ? សិល្បៈរបស់អ្នកដូចម្ដេច ? ទាំងអ្នករឹងប៉ឹងព្រោះហេតុអ្វី បានជាមិនកោតខ្លាចនាគ ?" ។

ព្រាហ្មណ៍អាលម្ពាយ បំភ្លឺកម្លាំងអំណាចរបស់ខ្លួនថា ៖

"គ្រូឱបានប្រាប់វិជ្ជាពិសដ៏ប្រសើរដល់ឥសីមួយអង្គ ជាកោសិយគោត្រនៅក្នុងព្រៃ ប្រព្រឹត្តតបធម៌ អស់រាត្រីយូរ ។ ខ្ញុំជាអ្នកមិនខ្ជិលច្រអូសទាំងយប់ទាំងថ្ងៃ បានបម្រើឥសីមួយអង្គនោះ ដែលមានខ្លួនចម្រើនហើយ កាលគង់នៅក្នុងចន្លោះភ្នំ ដោយសេចក្ដីគោរព ។ ឥសីនោះដែលខ្ញុំបានបម្រើហើយក្នុងកាលនោះ វត្តក្ដីព្រហ្មចរិយៈក្ដី ឥសីនោះបានប្រព្រឹត្តហើយ ឥសីមានជោគនោះក៏បង្រៀនមន្តទិព្វដល់ខ្ញុំតាមសេចក្ដីប្រាថ្នា ។ ខ្ញុំជាអ្នករឹងប៉ឹង ព្រោះមន្តនោះ បានជាមិនខ្លាចនាគទាំងឡាយ ខ្ញុំជាអាចារ្យរបស់ពួកអ្នកសម្លាប់សត្វមានពិសទាំងឡាយ ជនទាំងឡាយស្គាល់ខ្ញុំថាអាលម្ពាយ" ។

## សោមទត្តខឹងឪពុករត់ទៅបួស

*លុះព្រឹកឡើង នេសាទព្រាហ្មណ៍គិតថា "បុគ្គលនេះជាអាលម្ពាយ ជនណាបង្ហាញនាគដល់គេ គេនឹងឲ្យកែវមណីដល់ជននោះ អញនឹងបង្ហាញភូរិទត្តដល់គេ ហើយយកកែវមណី" ។ គ្រានោះឯង នេសាទព្រាហ្មណ៍ ប្រឹក្សាជាមួយនឹងកូនថា ៖*

> *"ម្នាលសោមទត្តកូន យើងនឹងយកកែវមណី ចូរអ្នកដឹងចុះ ។ យើងកុំយកដំបងទាត់ចោលសិរីដែលមកដល់ តាមសេចក្តីប្រាថ្នាឡើយ" ។*

*សោមទត្តថា ៖*

> *"បពិត្រព្រាហ្មណ៍ ព្រះភូរិទត្ត អ្នកបានបូជាលោកដែលដល់នូវនិវេសន៍របស់ខ្លួន ដោយកាមទិព្វទាំងឡាយ លោកប្រាថ្នានឹងប្រទូស្ត ចំពោះព្រះភូរិទត្តដែលជាមិត្រធ្វើអំពើល្អយ៉ាងនេះនោះ ព្រោះសេចក្តីវង្វេងធ្វើអ្វី ? ។ បើលោកឪពុកចង់បានទ្រព្យ ព្រះភូរិទត្តនឹងប្រទាន ចូរលោកឪពុកទៅសូមភូរិទត្តវិញចុះ ព្រះអង្គនឹងប្រទានទ្រព្យច្រើនដល់លោកឪពុក" ។*

*នេសាទព្រាហ្មណ៍ថា ៖*

"ម្នាលសោមទត្ត កូនឯងនៅក្មេងពេកណាស់ មិនចេះមិនដឹងដំណើរប្រព្រឹត្តទៅរបស់លោកសោះ យើងគួរស៊ីរបស់ឆ្អិនដែលមកដល់ដៃ ឬដល់ភាជន៍ ឬក៏មកដល់ពីមុខ ប្រសើរជាង ។ កុំឲ្យប្រយោជន៍ឃើញច្បាស់នឹងភ្នែក កន្លងផុតពីយើងទៅបាន" ។

សោមទត្តថា ៖

"បុគ្គលជាអ្នកប្រទុស្តមិត្រ ជាអ្នកលះបង់ប្រយោជន៍ រមែងឆេះក្នុងនរកដ៏គួរខ្លាច ផែនដីក៏ស្រូបបុគ្គលទ្រុស្តមិត្រនោះ បុគ្គលទ្រុស្តមិត្រ សូម្បីរស់នៅក៏រីងស្ងួតដូចជាប្រេត បើឪពុកចង់បានទ្រព្យ ព្រះភូរិទត្តនឹងប្រទានមិនខាន ខ្ញុំសម្គាល់ថា មិនយូរប៉ុន្មានឪពុកនឹងដឹងច្បាស់នូវពៀរដែលខ្លួនធ្វើហើយ" ។

នេសាទព្រាហ្មណ៍តបថា ៖

"នែ៎សោមទត្តកូន អ្នកនៅក្មេងខ្ចីណាស់ មិនចេះដឹងអ្វី ៗ ទេ ដែលហៅថាព្រាហ្មណ៍ ៗ ធ្វើបាបណានីមួយហើយ រមែងបរិសុទ្ធដោយយញ្ញ ព្រាហ្មណ៍ទាំងឡាយ បូជាមហាយញ្ញហើយ រមែងបរិសុទ្ធ យ៉ាងនេះ យើងនឹងបូជាមហាយញ្ញ គង់នឹងរួចចាកបាបដោយ អាការយ៉ាងនេះ" ។

សោមទត្តថា ៖

"ណ្ហើយចុះឥឡូវនេះ ខ្ញុំនឹងគេចចេញ ថ្ងៃនេះខ្ញុំមិននៅជាមួយនឹងឪពុកទេ ខ្ញុំមិនដើរជាមួយនឹងឪពុកដែលធ្វើអំពើអាក្រក់យ៉ាងនេះអស់មួយជំហានទេ" ។

លុះពោលយ៉ាងនេះហើយ មាណពបណ្ឌិត មិនអាចណែនាំឪពុកឲ្យជឿនូវសម្ដីរបស់ខ្លួនបាន ក៏ស្រែកប្រកាសដល់ទេវតាទាំងឡាយយ៉ាងខ្លាំង ៗ ថា ៖

"ខ្ញុំមិនដើរជាមួយនឹងមនុស្សអ្នកធ្វើបាបបែបនេះទេ" កាលឪពុកកំពុងតែមើលឃើញនៅឡើយ សោមទត្តរត់ចូលទៅព្រៃហិមពាន្ត បួសជាតាបស
ញុំាងអភិញ្ញានិងសមាបត្តិឲ្យកើតក្នុងសន្ដាន
រស់នៅមិនបានសាបសូន្យចាកឈាន លុះដល់ទីបំផុតនៃជីវិត គេបានកើតនៅឯព្រហ្មលោក ។

រីឯនេសាទព្រាហ្មណ៍គិតថា "សោមទត្ត វានឹងទៅឯណាក្រៅតែពីផ្ទះរបស់ខ្លួន" ងាកមើលទៅអាលម្ពាយ ឃើញគេមិនសប្បាយចិត្តបន្តិច ក៏លួងលោមគេថា ៖

"បពិត្រព្រាហ្មណ៍អាលម្ពាយ កុំគិតព្រួយបារម្ភអ្វីឡើយ ខ្ញុំនឹងបង្ហាញឲ្យអ្នកបានឃើញភូរិទត្ត"

ហើយគាត់នាំ ព្រាហ្មណ៍អាលម្ពាយនោះទៅកាន់ទីធ្វើឧបោសថរបស់នាគរាជ ឃើញនូវនាគរាជកំពុងវៀនដេកលើភោគៈលើក្បាលដំបូក គាត់ឈរនៅទីមិន ឆ្ងាយប៉ុន្មាន បានលាដៃចង្អុលប្រាប់ដូច្នេះថា ៖

"នាគដែលមានពន្លឺដូចជាសម្បុរនៃសត្វមេភ្លៀង មានក្បាលក្រហម អ្នកចូរចាប់នាគធំនុ៎ះចុះ ចូរនាំកែវមណីនុ៎ះដល់ខ្ញុំ ។ កាយរបស់នាគនុ៎ះ រមែងប្រាកដដូចជាគំនរប៉ុយកប្បាសដែលគេថ្លៃចល្អហើយ នាគនេះដេកលើដំបូក ម្នាលព្រាហ្មណ៍ អ្នកចូរចាប់យកនាគនោះចុះ" ។

គ្រានោះ ព្រះមហាសត្តភូរិទត្ត បើកភ្នែកទាំងគូ មើលទៅឃើញនេសាទព្រាហ្មណ៍ ព្រះអង្គយល់ក្នុងចិត្តថា ៖

"អញគិតថាតាព្រាហ្មណ៍ នេះគប្បីធ្វើនូវសេចក្ដីអន្តរាយ ចំពោះឧបោសថរបស់អញ ទើបបាន អញនាំគាត់ទៅកពនាគ តែងតាំងគាត់ក្នុងមហាសម្បត្តិ ។ គាត់មិនយក កែវមណីដែលអញឲ្យទេ ប៉ុន្តែឥឡូវនេះនាំហ្មចាប់ពស់មក ។ ប្រសិនបើអញក្រោធ

ចំពោះមនុស្សទ្រុស្តមិត្រនេះ សីលរបស់អញនឹងដាច់ មែនពិត អញបានអធិដ្ឋានឧបោសថប្រកបដោយអង្គ ៤ ជាមុនរួចស្រេចទៅហើយ ឧបោសថនោះចូរឋិតនៅតាមការអធិដ្ឋានដដែល ទោះ យោបីអាលម្ពាយ កាត់អញក្តី ចម្អិនក្តី ដោតដោយដែក សូលក្តី អញ នឹងមិនក្រោធចំពោះអាលម្ពាយនោះជាដាច់ខាត"

គិតដូច្នេះ នាគរាជភូរិទត្ត បិទភ្នែកដោយនឹកថា ៖

"ប៉ុន្តែបើអញសម្លឹងមើលគេពីរនាក់នេះ ពួកគេនឹងល្អិតហ្មត់ទៅជាផេះ ដូច្នេះ ទោះបីគេសំពងអញក្តី អញនឹងមិនក្រោធ មិនក្រឡេកមើលឡើយ"

ហើយតាំងអធិដ្ឋានបារមីជា ប្រធាន ដាក់ក្បាលក្នុងចន្លោះភោគៈ ដេកនឹងថ្កល់ឥតកក្រើកឡើយ ។ ចំណែកឯនេសាទព្រាហ្មណ៍ពោលថា ៖

"នែ៎អាលម្ពាយ ចូរចាប់នាគនេះចុះ ចូរឲ្យកែវមណីដល់ខ្ញុំ" ។ ព្រាហ្មណ៍អាលម្ពាយ ឃើញនាគ គាត់មានអំណរអរត្រេកជាខ្លាំង មិនពិចារណាកែវមណីជាអ្វីទេ បោះ ទៅដៃព្រាហ្មណ៍នេសាទនោះថា

"យកចុះ ព្រាហ្មណ៍" ។

កែវមណី រអិលពីដៃព្រាហ្មណ៍ធ្លាក់លើដី ។ គ្រាន់តែធ្លាក់ដល់ដីភ្លាម កែវមណី នោះលិចចូលទៅក្នុងដី ត្រឡប់ទៅកាន់ភពនាគវិញ ។

## អាលម្ពាយចាប់ភូរិទត្ត

នេសាទព្រាហ្មណ៍មានសេចក្តីសាបសូន្យ ៣ យ៉ាងគឺ កែវមណី១ មិត្រភាពនឹងភូរិទត្ត១ កូន១ ។ ព្រាហ្មណ៍ខ្សឹកខ្សួលដើរទៅផ្ទះថា "អញលែងមានអ្វីទីពឹង អញមិនបានធ្វើតាមពាក្យកូន"។ ចំណែកអាលម្ពាយវិញ លាបសរីរៈរបស់ខ្លួនដោយឱសថទិព្វ ខាំទំពាបន្តិច ផ្លុំព្រួសស្តោះប្រោះព្រំកាយរបស់ខ្លួន សូធ្យទិព្វមន្តខ្សឹប ៗ ដើរចូលទៅរកពោធិសត្វ ចាប់កន្ទុយទាញ រួចចាប់ក្បាលយ៉ាងមាំ បង្ហាមាត់ដាក់ឱសថ ស្តោះព្រួសទឹកមាត់ត្រង់មុខពោធិសត្វ ។ នាគរាជដែលល្អដោយធម្មជាតិពុំក្រោធដោយខ្លាចបែកធ្លាយសីល និងពុំបានបើកភ្នែកមើលឡើយ ។ គ្រានោះ អាលម្ពាយសូធ្យមន្តឱសថនោះ ចាប់កន្ទុយនាគរាជភូរិទត្ត បញ្ចោតក្បាលទៅក្រោម ច្បូតរឹតខ្លួនឲ្យភូរិទត្តខ្ជាក់ចំណី ភោជនចេញពីពោះ រួចដាក់ឲ្យដេកសន្ធឹងលើដី រួចជាន់ដោយជើងទាំងពីរសាចុះសាឡើង ដូចជាន់មសូករ ។ ឆ្អឹងទាំងឡាយរបស់ភូទិត្ត ស្ទើរតែខ្ទេចល្អិតដូចចុណ្ណ ។ អាលម្ពាយចាប់កន្ទុយម្តងទៀត សំពងដូចគេវាយសំពត់ ។ ព្រះមហាសត្ត បើទោះបីរងនូវទុក្ខលំបាកបែបនេះ ក៏ទ្រង់ឥតខឹងក្រោធ

អ្វីឡើយ ។ ព្រាហ្មណ៍អាលម្ពាយ ចាប់នាគរាជភូរិទត្តបាន ដោយវិធីជប់បទនៃមន្តទាំងឡាយ និងវិធីស្តោះផ្លុំឱសថទិព្វដែលជាគ្រឿងការពារខ្លួនយ៉ាងនេះ ។

## ភូរិទត្តនាគរាជសម្តែងរបាំ

ដោយប្រការដូចដែលពោលមកនេះ ព្រាហ្មណ៍អាលម្ពាយនោះបានធ្វើព្រះមហាសត្តឲ្យមានកម្លាំងខ្សោយ ហើយត្បាញវល្លិធ្វើជាហិបដាក់ព្រះមហាសត្តក្នុងនោះ ព្រះមហាសត្តចូលទៅក្នុងនោះមិនរួចព្រោះសរីរៈធំជាងរន្ធដែលត្រូវចូល ។ គ្រានោះ អាលម្ពាយវាយព្រះអង្គបញ្ចូលទៅដោយខ្សែទៃ ហើយគាត់យកហិបនោះស្ពាយដើរទៅកាន់ស្រុកមួយ លុះដើរទៅដល់ពាក់កណ្តាលស្រុក បានប្រកាសថា "សូមអញ្ជើញមហាជនមកទស្សនានូវរបាំរបស់នាគ" ។ អ្នកស្រុកទាំងមូលបានមកជួបជុំគ្នាយ៉ាងច្រើនកុះករ ។ ក្នុងខណៈនោះ អាលម្ពាយពោលថា "ចូរចេញទៅ មហានាគ" ។ ព្រះមហាសត្តគិតថា "ថ្ងៃនេះ ការដែលលេងកីឡាញុំាងបរិស័ទឲ្យត្រេកស្គុត ទើបគួរ, កាលបើយ៉ាងនេះ អាលម្ពាយនឹងបានទ្រព្យច្រើន គង់តែគាត់ត្រេកអរហើយលែងអញឲ្យទៅវិញ អាលម្ពាយឲ្យអញធ្វើកិច្ចណា ៗ អញនឹងធ្វើនូវកិច្ចនោះ ៗ " ។ គ្រានោះ អាលម្ពាយ នាំភូរិទត្តនាគរាជចេញអំពីហិប ហើយបញ្ជាថា

"ចូរធំ" ។ នាគរាជភូរិទត្ត ក៏ពង្រីកខ្លួនឲ្យធំ ។ អាលម្ពាយបញ្ជាថា "ចូរតូច, ចូរពែនពង់, ចូរពាក់ក្រោះចូរដកពពារ១, ពពារ២, ពពារ៣, ពពារ៤ ពពារ៥, ពពារ៦, ពពារ៧, ពពារ៨, ពពារ៩, ពពារ១០, ពពារ២០, ពពារ៣០, ពពារ៤០, ពពារ៥០, ពពារ១០០, ចូរខ្ពស់, ចូរទាប, ចូរបង្ហាញកាយ, ចូរបំបាំងកាយ, ចូរបង្ហាញកាយពាក់កណ្ដាល, ចូរពណ៌ខៀវ ចូរពណ៌លឿង, ចូរពណ៌ក្រហម, ចូរពណ៌ស, ចូរចម្រុះពណ៌ចូរបញ្ចេញអណ្ដាតភ្លើង, ចូរបញ្ចេញទឹក,ចូរបញ្ចេញផ្សែង" ។ ព្រះមហាសត្តបាននិម្មិតអត្តភាព តាមសេចក្ដីបង្គាប់របស់ អាលម្ពាយទាំងអស់ និងបានសម្ដែងនូវរបាំរាំរែក ។ និយាយពីមហាជនដែលទស្សនានោះវិញ ឃើញដូច្នោះហើយ ម្នាក់ ៗ មិនអាចទប់ទឹកភ្នែក មិនឲ្យស្រក់បាន ។

មនុស្សទាំងឡាយ បានឲ្យប្រាក់ មាស ពស្ត្រាលង្ការជាដើមដ៏ច្រើន ។ រួមមក ព្រាហ្មណ៍អាលម្ពាយនោះ បានប្រាក់ចំនួន ១.០០០ កហាបណៈ ក្នុងស្រុកតែមួយនោះ ។ អាលម្ពាយនោះកាលចាប់ព្រះមហាសត្ត គេបាននិយាយថា គេបានប្រាក់ ១.០០០ កហាបណៈហើយ គេនឹងដោះលែងព្រះអង្គ ដូច្នេះក៏ពិតមែន ប៉ុន្តែលុះបានទ្រព្យចំនួនប៉ុណ្ណោះ មិនព្រមដោះលែងព្រះអង្គទេ ព្រោះសេចក្ដីល្មោភក្នុងទ្រព្យ

ថា "ក្នុងស្រុកតែមួយ អញរកទ្រព្យបានប៉ុណ្ណោះ ចុះចំណង់បើដល់រាជធានី អញនឹងបានទ្រព្យច្រើនពុំខាន" ។ អាលម្ពាយបានទុកដាក់ទ្រព្យក្នុងស្រុកនោះ ជួលជាងឲ្យធ្វើហិបវិចិត្រដោយរតនៈ ដាក់ព្រះមហាសត្តក្នុងហិបនោះ គាត់ឡើងជិះយានដែលមានផាសុកភាព ចេញដំណើរទៅដោយមានបរិវារជាច្រើន គាត់បានឲ្យព្រះអង្គលេងរបាំក្នុងស្រុក និគមផ្សេង ៗ ជាដើម តាមលំដាប់ រហូតដល់ក្រុងពារាណសី ។ ទោះជាយ៉ាងណាក៏ដោយ អាលម្ពាយបានឲ្យលាជប្រឡាក់ទឹកឃ្មុំដល់នាគរាជ និងសម្លាប់កង្កែបទាំងឡាយ រួចឲ្យ ។ ភូរិទត្តនោះ មិនទទួលចំណីទេ ដោយខ្លាចការមិនដោះលែង ។ អាលម្ពាយ បានញ៉ាំងព្រះមហាសត្តឲ្យលេងរបាំ ទាំងដែលព្រះអង្គមិនមានចំណីចូលពោះមួយម៉ាត់ តាំងអំពីស្រុកទៀបទ្វារនគរទាំង ៤ ជាដើម អស់កាលមួយខែក្នុងទីនោះ ៗ ។ លុះដល់ថ្ងៃ ឧបោសថពេញបូណ៌មី អាលម្ពាយបានឲ្យគេចូលទៅរាយការណ៍ដល់ព្រះមហាក្សត្រស្ដេចផែនដីថា "ថ្ងៃនេះទូលបង្គំជាខ្ញុំនឹងឲ្យគេលេងរបាំ ក្នុងសម្នាក់របស់ព្រះអង្គ" ។ ព្រះរាជាបានចេញបញ្ជាឲ្យគេដើរទូងស្គរ ក្នុងក្រុង ប្រកាសឲ្យមហាជនមកជួបជុំគ្នា ។ ជនទាំងឡាយបានចងគ្រែ ទាបខ្ពស់តាមលំដាប់គ្នា ក្នុងព្រះលានហ្លួង ត្រៀមមើលរបាំនាគ ។

កីឡនកណ្ឌ ចប់ ។

# ជំពូកទី៦

## កូរិទត្តនិងបងប្អូនជួបព្រះមាតុលានៅរាជធានី

### ទំនួញរបស់ព្រះនាងសមុទ្ទជា

*ប៉ុន្តែក្នុងថ្ងៃនៃព្រះពោធិសត្វត្រូវអាលម្ពាយចាប់នោះ ព្រះមាតារបស់ព្រះមហាសត្វ បានយល់សុបិនថា "មានបុរសភ្នែកក្រហមឃោរឃៅម្នាក់ កាត់ដើមព្រះហស្តខាងស្តាំរបស់ព្រះនាងដោយដាវ ហើយយកចេញទៅ ទាំងមានឈាមហូរសស្រាក់" ។ ព្រះនាងភ័យតក់ស្លុតតើនឡើងស្ទាបដើមព្រះហស្តស្តាំ ដឹងថាទ្រង់យល់សុបិន។ គ្រានោះព្រះនាង មានសេចក្តីត្រិះរិះថា "អញយល់សុបិនអាក្រក់ចង្រៃអ៊ីចឹងប្រាកដជាសេចក្តីអន្តរាយមានដល់កូនអញទាំង៤ ឬដល់ស្តេចធតរដ្ឋស្វាមីរបស់អញ ពុំនោះទេដល់ខ្លួនអញ" ។ ប្រការមួយវិញទៀត ព្រះនាងគិតខ្វល់ខ្វាយជាខ្លាំង ប្រារព្ធទៅនឹងព្រះមហាសត្តមួយអង្គគត់ថា "ព្រោះហេតុអ្វី កូនផ្សេង ៗ នៅក្នុងភពនាគរបស់ខ្លួន ឯកូរិទត្តដែលមានអធ្យាស្រ័យក្នុងសីល ទៅកាន់មនុស្សលោក ធ្វើឧបោសថកម្មទេដឹង បើអ៊ីចឹងមែន កូនអញត្រូវអាលម្ពាយឬគ្រុឌចាប់ហើយទេដឹង" ព្រះនាងចេះតែគិតខ្វល់ខ្វាយខ្លាំងយ៉ាងនេះ ដល់ព្រះមហាសត្តមួយអង្គ ។ បន្ទាប់ពីនោះ កន្លងទៅកន្លះខែព្រះនាងមានទោមនស្សថា "កូនអញមិន*

ដែលទៅណាចោលអញ ហួសពីកន្ទះខែទេ ប្រាកដជាភ័យធំណាមួយកើតឡើង ដល់គេពុំខាន" ។ លុះកន្លងទៅ ១ ខែ មិនឃើញទៀត ព្រះនាង មានសេចក្តីសោកស្តាយ ទឹកព្រះនេត្រាហូរឥតឈប់ បេះដូងស្ងួតខ្សោះ ព្រះនេត្រឡើងក្តៅហើមឈឺផ្សា ។ ព្រះនាងគង់ប្រថាប់សម្លឹងមើលទៅផ្លូវមករបស់ពោធិសត្វ គិតថា "កូនអញមកឥឡូវនេះ កូនអញមកឥឡូវនេះ" ។ គ្រានោះ រាជបុត្រច្បងរបស់ព្រះនាង នាមថា សុទស្សនៈ ដោយកន្លងទៅមួយខែ គេក៏បានមកដើម្បីគាល់ព្រះមាតាបិតា ជាមួយនឹងបរិស័ទជាច្រើន, ទុកបរិស័ទនៅឯក្រៅ ខ្លួនឯងឡើងកាន់ប្រាសាទ ថ្វាយបង្គំព្រះមាតា រួចឈរក្នុងទីសមគួរ ។ ព្រះនាងសមុទ្ទជា អាល័យសោកស្តាយដល់ភូរិទត្ត មិនបានចរចាអ្វីមួយម៉ាត់ជាមួយនឹងបុត្រច្បងសុទស្សនៈនោះឡើយ ។ សុទស្សនៈគិតថា "ព្រះមាតារបស់អញ កាលដែលអញមកពីមុន ៗ ទ្រង់តែត្រេកអរ ធ្វើនូវបដិសណ្ឋារៈ ប្លែកអ្វីថ្ងៃនេះ ទ្រង់មានទោមនស្ស តើព្រោះហេតុអ្វី" រួចក៏សួរព្រះមាតាថា ៖

"ឥន្ទ្រិយរបស់លោកមិនស្រស់បស់ ព្រះភក្ត្ររបស់លោកដែលធ្លាប់តែមានពណ៌ដូចកញ្ចក់មាស ឥឡូវប្រែក្លាយជាលឿងស្លេកស្លាំងខ្មៅ ព្រោះឃើញខ្ញុំដែលសម្រេចសេចក្តីប្រាថ្នាទាំងពួងកំពុងមកគាល់ ដោយសម្បត្តិដ៏លើសលប់បែបនេះឬ ? ។ ព្រះ

កក្រួរបស់លោកខ្មៅ ដូចជាផ្កាដែលបិតនៅក្នុងដៃដែលគេច្របាច់ដោយដៃ ព្រោះតែឃើញខ្ញុំប្រាកដដូច្នេះឬ?"

ព្រះនាងសមុទ្ទជា ទោះបីបុត្រសួរយ៉ាងនេះ ក៏មិនបានឆ្លើយតបអ្វីឡើយ ។ សុទស្សនៈគិតថា "ព្រះមាតាទ្រង់ខ្វាល់ ឬទ្រង់គុំនឹងនរណាមួយទេដឹង?" ក៏សួរព្រះមាតាម្តងទៀតថា ៖

"ក្រែងបុគ្គលណាមួយ មិនរាប់អានលោកខ្វះឬ? វេទនារបស់លោកមានខ្វះឬ? ថ្ងៃនេះព្រះភក្ត្ររបស់លោក ប្រែជាខ្មៅអាប់ព្រោះឃើញខ្ញុំមក ដោយហេតុណា? សូមលោកប្រាប់នូវហេតុនោះដល់ខ្ញុំ" ។

គ្រានោះ ទើបព្រះនាងសមុទ្ទជា បានប្រាប់បុត្រថា ៖

"ម្នាលកូន មកទាល់ថ្ងៃនេះ មួយខែហើយ យើងបានឃើញសុបិនថាហាក់ដូចជាបុរសកាត់ដៃខាងស្តាំរបស់យើង ហើយនាំយកដៃដែលប្រឡាក់ដោយឈាម ដើរចេញទៅ ក្នុងកាលដែលយើងកំពុងយំ ។ ម្នាលសុទស្សនៈ កាលណាយើងបានឃើញសុបិនអ្នកចូរដឹងចុះថា កាលណោះ យើងមិនបានសេចក្តីសុខទាំងថ្ងៃទាំងយប់" ។

លុះពោលយ៉ាងនេះហើយ ព្រះនាងខ្សឹកខ្សួលថា ៖

"ហៃកូន កូនតូចជាទីស្រឡាញ់របស់យើង ដែលជាប្អូនរបស់ឯង មិនឃើញទេ ជាក់ជាភ័យកើតឡើងដល់គេហើយ"

រួចព្រះនាងពោលជាបន្តថា ៖

"នាងកញ្ញាទាំងឡាយ មានរាងកាយដ៏រុងរឿង ពាក់បណ្ដាញមាស បានចោមរោមភូរិទត្តណា ពីក្នុងកាលមុន ឥឡូវនេះ ភូរិទត្ត នោះ យើងមិនឃើញទេ ។
នាគទាំងឡាយដែលកាន់ព្រះខ័នដ៏ ប្រសើរ ដូចជាផ្កាកណិការរីក ចោមរោមភូរិទត្តណា ពីក្នុងកាល មុន ឥឡូវនេះ ភូរិទត្តនោះ យើងមិនឃើញទេ ។ ណ្ហើយចុះ ឥឡូវ នេះ យើងនឹងទៅកាន់លំនៅរបស់ភូរិទត្ត យើងគង់នឹងឃើញប្អូនរបស់អ្នកដែលតាំងនៅក្នុងធម៌បរិបូណ៌ដោយសីល" ។

លុះពោលយ៉ាងនេះហើយ ព្រះនាងសមុទ្ទជា មួយអន្លើដោយបរិស័ទរបស់សុទស្សនៈនិងរបស់ខ្លួន បានទៅក្នុងទីនោះ ។ ចំណែកភរិយាទាំងឡាយ របស់ភូរិទត្តវិញ កាលមិនឃើញភូរិទត្តនៅលើដំបូកមានកង្វល់ដែរថា "ភូរិទត្តនឹងនៅក្នុងនិវេសន៍របស់ព្រះមាតា" លុះឮនូវ

ដំណឹងថា ម្ដាយក្មេករបស់ពួកព្រះនាងមិនឃើញបុត្រដូចគ្នា ហើយកំពុងធ្វើដំណើរមក ពួកនាងក៏ទៅទទួល ហើយដួលទៀបបាទមូលរបស់ព្រះនាង ស្រែកយំខ្សឹកខ្សួលយ៉ាងខ្លាំង ផ្គងដៃឡើងកន្ទក់កន្ទេញថា ៖

"បពិត្រព្រះម៉ែម្ចាស់ បុត្ររបស់ព្រះនាង មិនឃើញទេ គិតមកដល់ថ្ងៃនេះកន្លងទៅមួយខែហើយ យើងខ្ញុំមិនដឹងភូរិទត្តដ៏មានយសជាបុត្ររបស់ព្រះនាង ស្លាប់ឬរស់នៅទេ ?" ។

ព្រះមាតារបស់ភូរិទត្ត បានខ្សឹកខ្សួល ក្នុងចន្លោះវិថីជាមួយនឹងព្រះសុណិសាទាំងឡាយ ហើយយកពួកនាងឡើងទៅកាន់ប្រាសាទរបស់ភូរិទត្តនោះ គយគន់មើលទីផ្ទំ ទីអង្គុយរបស់បុត្រ ទាំងខ្សឹកខ្សួលថា ៖

"យើងកាលមិនឃើញភូរិទត្តទេ នឹងឆេះដោយសេចក្ដីទុក្ខអស់កាលដ៏យូរ ដូចជាមេសត្វស្លាបបាត់កូន ឃើញតែសំបុកទទេដូច្នោះ ។ យើងកាលមិនឃើញភូរិទត្ត នឹងឆេះដោយសេចក្ដីទុក្ខអស់កាលដ៏យូរ ដូចជាមេអកបាត់កូន ឃើញតែសំបុកទទេដូច្នោះ ។ យើងកាលមិនឃើញភូរិទត្តទេ នឹងឆេះដោយសេចក្ដីទុក្ខ អស់កាលយូរ ដូចជាមេ សត្វចាក្រពាកនោះ នៅលើភក់ដែលមិន

មានទឹកដោយពិត ។ ដើងក្រានៃពួកជាងមាស ឆេះតែខាងក្នុង មិនឆេះខាងក្រៅ យ៉ាងណា យើងកាលមិនឃើញភូរិទត្ត នឹងឆេះដោយសេចក្ដីសោក យ៉ាងនោះដែរ" ។

នាកាលព្រះមាតារបស់ភូរិទត្ត កំពុងតែពិលាបយ៉ាងនេះ និវេសន៍របស់ភូរិទត្ត មានសំឡេងមួយហាក់ដូចផ្ទៃរបស់មហាសមុទ្រ ។ គ្មានបុគ្គលសូម្បីតែមួយនាក់ ដែលអាចទប់លំនឹងខ្លួនបាន ។ និវេសន៍ទាំងមូលហាក់ដូចព្រៃសាលរនៃត្រូវខ្យល់យុគន្ធរបក់បោក ។ កូននិងប្រពន្ធទាំងឡាយ របស់ភូរិទត្ត ដួលដេកក្នុងនិវេសន៍របស់ព្រះភូរិទត្ត ដូចជាដើមឈើដែលត្រូវខ្យល់បក់បោកបំបាក់ដូច្នោះ ។

បងប្អូនប្រុស ២ នាក់ គឺអរិដ្ឋៈ១ សុភោគៈ១ ចូលទៅទីឧបដ្ឋានរបស់ព្រះមាតាបិតា ក៏ឮសំឡេងគឹកកងនោះ នាំគ្នាស្ទុះចូលទៅតាមលំដាប់រហូតនិវេសន៍របស់ភូរិទត្ត លួងលោមព្រះមាតាថា ៖

"បពិត្រព្រះមាតា សូមលោកដកដង្ហើមស្រួលចុះ កុំសោយសោកឡើយ ព្រោះថាសត្វទាំងឡាយ មានសភាពយ៉ាងនេះជាធម្មតា តែងច្យុត តែងកើតឡើងវិញ នេះជាការប្រែប្រួលនៃលោក លោកនោះតែងប្រែប្រួលយ៉ាងនេះឯង ដែលហៅអ្នករួចចាកអង្គពីរនោះ មិនមាន" ។

សមុទ្ទជាថា ៖

"ម្នាលកូន យើងក៏ដឹងថាសត្វទាំងឡាយ មានសភាពយ៉ាងនេះជាធម្មតាដែរ តែថាយើងកាលមិនឃើញភូរិទត្តទេ ត្រូវសេចក្ដីសោកគ្របសង្កត់ ប្រសិនបើភូរិទត្តមិនបានមកជួប នឹងយើងក្នុងថ្ងៃនេះយប់នេះទេ ម្នាលសុទស្សនៈ អ្នកចូរដឹងចុះ យើងកាលមិនឃើញភូរិទត្តទេ យើងសម្គាល់ថាយើងមុខជានឹងលះបង់ជីវិតពុំខាន" ។

បុត្រទាំងឡាយថា ៖

"បពិត្រព្រះមាតា សូមលោកដកដង្ហើមស្រួលចុះ កុំសោយសោកអ្វីឡើយ ។ យើងទាំងឡាយ នឹងនាំបងមកវិញពុំខាន យើងទាំងឡាយត្រាច់ទៅកាន់ទីស្វែងរកបង នឹងទៅកាន់ទិសតូចធំលើភ្នំជ្រោះភ្នំ ក្នុងស្រុក និងនិគមទាំងឡាយ លោកចូរឃើញបងដែលមកក្នុងរវាង ៧ រាត្រី" ។

## បងប្អូនចែកផ្លូវគ្នាដើររកភូរិទត្ត

គ្រានោះ សុទស្សនៈគិតថា "ប្រសិនបើយើងទៅកាន់ទិសមួយទាំង ៣ នាក់តែម្តង ប្រាកដជាមានការយឺតយូរ យើងទាំង៣នាក់បែកគ្នាទៅទីនីមួយ ៗ ទើបគួរ, គួរម្នាក់ទៅទេវលោក, ម្នាក់ទៅព្រៃហិមពាន្ត, ម្នាក់ទៅមនុស្សលោក ។ ប៉ុន្តែបើកាណារិដ្ឋៈទៅកាន់មនុស្សលោកឃើញភូរិទត្តកន្លែងណា គេនឹងញុាំងស្រុកឬនិគមនោះឲ្យឆេះ មកវិញ នុំះឃោរឃៅ ព្រៃផ្សៃណាស់ យើងមិនអាចបញ្ជូនគេទៅមនុស្សលោកបានទេ" ។ លុះគិតដូច្នេះហើយ សុទស្សនៈបញ្ជូនកាណារិដ្ឋទៅទេវលោក ដោយផ្តាំថា ៖

> "នែ៎អរិដ្ឋ អ្នកចូរទៅទេវលោក ប្រសិនបើភូរិទត្តត្រូវ ទេវតាទាំងឡាយអ្នកប៉ងស្តាប់ធម៌ នាំទៅកាន់ទេវលោក ចូរឯងនាំគេមកពីទីនោះវិញ",

រួចប្រើសុភោគៈឲ្យទៅព្រៃហិមពាន្ត ដោយផ្តាំថា ៖

> "សុភោគៈ ឯងទៅព្រៃហិមពាន្ត ពិនិត្យមើលភូរិទត្ត ក្នុងមហានទីទាំង ៥ រួចមកវិញចុះ" ។

លុះបង្គាប់ប្អូន ៗ ដូច្នេះហើយ សុទស្សនៈខ្លួនឯងមាន បំណងទៅកាន់មនុស្សលោក ទើបគិតថា "ប្រសិនបើអញទៅដោយ ភេទជាមាណពមនុស្សទាំងឡាយនឹងមិនស្រឡាញ់អញទេ គួរណាស់តែអញទៅដោយប្លែងភេទជាតាបសវិញ ដ្បិតថាបព្វជិតទាំងឡាយ តែងជាទីស្រឡាញ់របស់មនុស្សទាំងឡាយ" ។ សុទស្សនៈនោះ បានប្លែងភេទជាតាបស ថ្វាយបង្គំព្រះមាតា ហើយចេញដំណើរទៅ ។

មានប្អូនស្រីម្តាយទីទៃរបស់ពោធិសត្វមួយរូប ឈ្មោះ អជមុខី ។ នាងមានសេចក្តីស្នេហាយ៉ាងខ្លាំង ចំពោះពោធិសត្ត ។ នាងអជមុខីឃើញសុទស្សនៈចេញទៅ នាងពោលថា ៖

"បងប្រុស នាងខ្ញុំលំបាកខ្លាំងណាស់ ខ្ញុំក៏នឹងទៅជាមួយនឹងបងដែរ" ។

សុទស្សនៈថា ៖

"ហៃប្អូនស្រី នាងមិនអាចនឹងទៅបានទេ ដ្បិតខ្ញុំទៅដោយភេទជាបព្វជិត" ។

នាងអជមុខីថា

"ប៉ុន្តែខ្ញុំនឹងនិម្មិតខ្លួនជាកង្កែបតូច ដេកក្នុងចន្លោះផ្នួងសក់របស់បង ទៅដែរ" ។

សុទស្សនៈថា

"បើអ៊ីចឹង តោះទៅ" ។

អជមុខី បាននិម្មិតខ្លួនជាកង្កែបតូច ដេកក្នុងចន្លោះជដារបស់តាបស ។ សុទស្សនៈគិតថា "អញនឹងតាមដានមើលតាំងពីដើមទី រួចសឹមទៅ" លុះបានសួរ នូវកន្លែងធ្វើឧបោសថរបស់ភូរិទត្តនោះ នឹងកិរិយាទាំងឡាយរបស់ពោធិសត្វហើយ បានទៅកន្លែងនោះមុន បានឃើញឈាម និងឃើញកន្លែងត្បាញវល្លិធ្វើហិប ក្នុងតំបន់ដែលអាលម្ពាយចាប់ព្រះមហាសត្វ សុទស្សនៈក៏ដឹងច្បាស់ថា "ភូរិទត្តប្រាកដជាត្រូវហ្មពស់ចាប់យកទៅបាត់ហើយ" ដូច្នេះ សុទស្សនៈកើតក្តីសោក នេត្រាពេញដោយទឹកអស្សុ រួចចេញដំណើរទៅកាន់ស្រុកដែលអាលម្ពាយឲ្យពោធិសត្វលេងរបាំដំបូង តាមផ្លូវដែលអាលម្ពាយដើរទៅនោះឯង សួរមនុស្សម្នាថា ៖

"នាគបែបនេះ អាលម្ពាយម្នាក់ឲ្យលេងរបាំនៅទីនេះឬ?" ។

មនុស្ស ទាំងឡាយប្រាប់ថា ៖

"បាទ អាលម្ពាយទើបតែឲ្យនាគលេងរបាំនៅចុងខែនេះឯង" ។

សុទស្សនៈសួរ ៖

"តើគេបានទ្រព្យអ្វីខ្លះឬទេ ?" ។

ពួកមនុស្សឆ្លើយ ៖

"បាទ គេបានទ្រព្យ ១.០០០ កហាបណៈ ក្នុងទីនេះ" ។

សុទស្សនៈសួរ ៖

"ឥឡូវនេះ គេទៅទីណា ?" ។

"ទៅស្រុកឯណោះហើយ" ពួកមនុស្សឆ្លើយ ។

សុទស្សនៈនោះ បានដើរសួរតាំងពីទីនោះរៀងរាប ដរាបដល់ទ្វារព្រះរាជវាំង ។

## អាលម្ពាយនិងសុទស្សនៈបង្ហួតឫទ្ធិគ្នា

ក្នុងខណៈនោះ ព្រាហ្មណ៍អាលម្ពាយ ងូតទឹកក្រអូបលាបគ្រឿងក្រអូប ហើយស្លៀកសំពត់សាជកសាច់ម៉ដ្ឋ ប្រើឲ្យបម្រើកាន់ហិបកែវ

រួចទៅកាន់ទ្វារព្រះបរមរាជវាំង ។ មហាជនប្រជុំគ្នា អាសនៈត្រូវបានគេក្រាលថ្វាយព្រះមហាក្សត្រ ។ ស្តេចអង្គនោះ កាលប្រថាប់នៅខាងក្នុងរាជនិវេសន៍នៅឡើយ ទ្រង់បានបញ្ជូនដំណឹងទៅថា ៖

"យើងនឹងមកទស្សនា ចូរអាលម្ពាយឲ្យនាគរាជលេងរបាំចុះ" ។ អាលម្ពាយ ដាក់ហិបកែវលើកម្រាលដ៏វិចិត្រ ហើយបើកហិបឲ្យសញ្ញាថា ៖

"ចូរចេញមក មហានាគ"

គ្រានោះ ព្រះមហាសត្តចេញក្បាល ក្រឡេកមើលបរិស័ទនោះជុំវិញទាំងអស់ ។ មែនពិត នាគទាំងឡាយ តែងក្រឡេកមើលនូវបរិស័ទដោយហេតុការណ៍ពីរយ៉ាង គឺដើម្បីឃើញនូវសេចក្តីអន្តរាយពីគ្រុឌ ១ នូវញាតិទាំងឡាយ ១ ។ នាគទាំងឡាយនោះ ឃើញគ្រុឌហើយ ខ្លាចមិនហ៊ានរាំទេ ឬឃើញញាតិទាំងឡាយហើយ អៀនខ្មាស ក៏មិនហ៊ានរាំដែរ ។ ប៉ុន្តែព្រះមហាសត្ត កាលដែលក្រឡេកមើលទៅ ក៏ឃើញនូវបងប្រុស ក្នុងចន្លោះបរិស័ទ ។ ព្រះអង្គមានទឹកព្រះនេត្រដោកនេត្រាចេញអំពីហិប វារឈមមុខឆ្ពោះទៅរកបងប្រុស ។ មហាជនឃើញនាគរាជមក ខ្លាច នាំគ្នាថយគេចចេញ នៅសល់តែសុទស្សនៈមួយនាក់គត់ដែលឈរនៅ មិនគេចចេញ ។ ពោធិសត្វ ទៅផ្តេកក្បាលលើខ្នងជើង

របស់សុទស្សនៈ ហើយយំ, រីឯសុទស្សនៈក៏ខ្សឹកខ្សួលដែរ ។ មហាសត្វ យំហើយ ត្រឡប់ចូលទៅកាន់ហិបវិញ ។ ចំណែកអាលម្ពាយ គិតថា "នាគនេះខាំតាបសហើយ អញនឹងលួងលោមគាត់" ហើយចូលទៅរក និយាយថា ៖

"នាគដែលរួចអំពីដៃរបស់យើង ក្រាបចុះលើជើងលោកយ៉ាង ខ្លាំង លោកត្រូវនាគចឹកឬ បពិត្រតាបស ខ្ញុំឈ្មោះអាលម្ពាយ លោក កុំខ្លាចឡើយ ការព្យាបាលដល់លោក ជាភារៈរបស់ខ្ញុំ លោកចូរដល់នូវសេចក្ដីសុខចុះ" ។

ដោយមានបំណងចរចាជាមួយនឹងអាលម្ពាយ សុទស្សនៈថា ៖

"នាគនេះ មិនអាចឲ្យទុក្ខណាមួយដល់អាត្មាទេ សូម្បីតែបន្តិច បន្តួច អ្នកចាប់ពស់មានទាំងប៉ុន្មាន មិនមែនមានច្រើនជាងអាត្មា ទេ គ្រូពស់ដែលស្មើនឹងអាត្មា មិនមានទេ" ។

អាលម្ពាយ មិនដឹងថា "តាបសនោះជានរណាទេ" បាននិយាយទាំង ក្រោធថា ៖

"អ្នកណាហ្ន៎ ភ្លីភ្លើ មានភេទដូចជាភេទនៃព្រាហ្មណ៍ មកកាន់បរិស័ទ ហើយហៅអញច្បាំង ពាលមានញាណផងឆឹតណានេះ ដូចជាឆ្កួតហ៊ានហៅអញច្បាំង ថាអញស្មើនឹងខ្លួនគេ មកកាន់បរិស័ទ បរិស័ទទាំងឡាយ ចូរស្ដាប់ពាក្យរបស់ខ្ញុំចុះ ខ្ញុំមិនមានទោសទេ អ្នកទាំងឡាយកុំខឹងនឹងខ្ញុំឡើយ" ។

គ្រានោះ សុទស្សនៈតបនឹងអាលម្ពាយវិញថា ៖

"ម្នាលអាលម្ពាយ ចូរអ្នកច្បាំងនឹងយើងដោយនាគ យើងក៏ច្បាំងនឹងអ្នក ដោយកូនកង្កែបដែរ ការភ្នាល់ក្នុងចម្បាំងនោះ ចូរមានដល់យើង ដោយកហាបណៈ៥.០០០ ជាកំណត់" ។

អាលម្ពាយថា ៖

"ម្នាលមាណព យើងជាអ្នកមានទ្រព្យស្ដុកស្ដម្ភ អ្នកឯងជាអ្នកទាល់ក្រ តើបុគ្គលណាជាអ្នកធានាអ្នក ម៉្យាងទៀត ទ្រព្យតម្កល់ទុកក្នុងការភ្នាល់ មានដែរឬ? ។ ទ្រព្យតម្កល់ទុកក្នុងការភ្នាល់របស់យើង មាន ទាំងបុគ្គលជាអ្នកធានាប្រាកដដូច្នោះក៏មានដែរ ការភ្នាល់ក្នុងចម្បាំងនោះ ចូរមានដល់យើងដោយកហាបណៈ៥.០០០ ជាកំណត់" ។

តាបសសុទស្សនៈ ស្តាប់សម្តីរបស់អាលម្ពាយហើយ តបថា ៖

"ភ្នាល់ដាក់ ៥.០០០ ក៏៥.០០០ ចុះ"

ហើយគាត់មិនខ្លាច ដើរឡើងទៅរាជនិវេសន៍ ឈរក្នុងសម្នាក់របស់ព្រះរាជាដែលជាឪពុកមា ក្រាបទូលថា ៖

"បពិត្រមហារាជ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យអាត្មាភាព សេចក្តីចម្រើនចូរមានដល់ព្រះអង្គ ព្រះអង្គមានកិត្តិគុណ សូមព្រះអង្គធានាដោយកហាបណៈ ៥.០០០ របស់អាត្មាភាព" ។

ព្រះរាជា គិតថា "តាបសនេះ សូមអញ នូវទ្រព្យច្រើនម៉្លេះ តើព្រោះហេតុអ្វីទៅ?" ហើយទ្រង់ត្រាស់ថា ៖

"នែព្រាហ្មណ៍ បំណុលគឺព្រះបិតាយើងខ្ចីស៊ីពីអង្គាល ឬខ្លួនយើងជំពាក់ដោយខ្លួនឯង? បិតារបស់យើងធ្លាប់ខ្ចីអ្វីពីដៃអ្នកឬ? ឬថាខ្ញុំធ្លាប់ខ្ចី? ហេតុអ្វីបានជាអ្នកទារយកទ្រព្យរបស់យើងច្រើនម៉្លេះ?" ។

កាលបើស្តេចត្រាស់យ៉ាងនេះ សុទស្សនៈក្រាបទូលថា ៖

"ដ្បិតអាលម្ពាយផ្ចាញ់អាត្មាភាពដោយនាគ អាត្មាភាពនឹងញ៉ាំង កូនកង្កែបឲ្យខាំព្រាហ្មណ៍ ។ ក្នុងចម្បាំងនោះ ថាបើអាលម្ពាយ ចាញ់ គេនឹងឲ្យ៥.០០០ ដល់ខ្ញុំ ប្រសិនបើខ្ញុំចាញ់ ខ្ញុំនឹងឲ្យ៥.០០០ ដល់គេ ហេតុនោះ ខ្ញុំសូមទ្រព្យច្រើននឹងព្រះអង្គ ។ បពិត្រមហា រាជ អ្នកញ៉ាំងដែនឲ្យចម្រើន ព្រោះហេតុនោះ ក្នុងថ្ងៃនេះ សូម ព្រះអង្គ មានពួកអ្នកកាន់ព្រះខ័នហែហម យាងទៅដើម្បីទតពស់ ដែលគួរទត" ។

ស្ដេចថា ៖

"បើអ៊ីចឹង តោះយើងទៅ"

ហើយទ្រង់យាងចេញទៅជាមួយនឹងតាបស ។ អាលម្ពាយឃើញ ដូច្នោះ នឹកខ្លាចក្នុងចិត្តថា "តាបសនេះទៅនាំព្រះរាជាមក គាត់ប្រាកដ ជាជីតុននៃរាជត្រកូល" ហើយគាត់បាននិយាយស្របតាមតាបសថា ៖

"ម្នាលមាណព ខ្ញុំមិនមើលងាយអ្នកដោយសិប្បៈទេ ចំណែក អ្នកមើលងាយដោយសិប្បៈ បានជាមិនកោតក្រែងនាគ មិនបូជា នាគនេះ" ។

គ្រានោះ សុទស្សនៈពោលថា ៖

"នែព្រាហ្មណ៍ អាត្មាក៏មិនមើលងាយអ្នកដោយសិប្បវាទទេ តែអ្នកបញ្ឆោតជនច្រើនដោយនាគដែលមិនមានពិស ។ អាត្មាដឹងអ្នកយ៉ាងណា ជនក៏ត្រូវដឹងអ្នកយ៉ាងនោះដែរ ម្នាលអាលម្ពាយអ្នកមិនបានអង្កាម ១ ក្តាប់ នឹងបានទ្រព្យអំពីណា ?" ។

គ្រានោះ អាលម្ពាយខឹងចំពោះតាបស ពោលថា ៖

"អ្នកស្លៀកដណ្តប់ស្បែកខ្លាទាំងក្រចក មានផ្នួងសក់ ជាមនុស្សកខ្វក់[៣២]ភ្លីភ្លើ មកកាន់បរិស័ទ ហើយមើលងាយនាគបែបនេះថាមិនមានពិស អ្នកចូលមក ហើយគង់តែនឹងដឹងនាគនោះ ដែលពេញដោយតេជះរបស់នាគដ៏ខ្ពង់ខ្ពស់ ខ្ញុំសម្គាល់ថា នាគនុ៎ះនឹងធ្វើអ្នកឲ្យដូចជាគំនរផេះយ៉ាងឆាប់" ។

គ្រានោះ សុទស្សនៈនិយាយឡកជាមួយនឹងអាលម្ពាយថា ៖

"ពិសនៃពស់ផ្ទះ ពស់ទឹក ពស់ខៀវគ្រាន់មានខ្លះ ឯពិសនៃនាគមានក្បាលក្រហម មិនមានសោះឡើយ" ។

គ្រានោះ អាលម្ពាយតបទៅសុទស្សនៈថា ៖

---

[៣២] ដែលគគ្រិចមិនស្អាត, ស្មោកគ្រោក ។

"ខ្ញុំបានស្ដាប់ពាក្យនេះ របស់ពួកព្រះអរហន្តដែលសង្រួមហើយ មានតបៈថា ទាយកទាំងឡាយក្នុងលោកនេះ ឲ្យទានទាំងឡាយ រមែងទៅកាន់ឋានសួគ៌ ថាបើអ្នកមានវត្ថុតិចតួចដែលគួរឲ្យ អ្នកទាន់នៅរស់ ចូរឲ្យទានទាំងឡាយចុះ ។ នាគនេះ មានឫទ្ធិច្រើន មានតេជះដែលគេកន្លងបានដោយក្រ ខ្ញុំនឹងប្រើនាគនេះឲ្យចឹកអ្នក នាគនោះនឹងធ្វើអ្នកឲ្យទៅជាផេះ" ។

សុទស្សនៈថា ៖

"ម្នាលសម្លាញ់ ខ្ញុំក៏បានស្ដាប់ពាក្យនេះរបស់ពួកព្រះអរហន្តដែលសង្រួមហើយមានតបៈថា ទាយកទាំងឡាយក្នុងលោកនេះ ឲ្យទានទាំងឡាយ រមែងទៅកាន់ឋានសួគ៌ ថាបើអ្នកមានវត្ថុតិចតួចដែលគួរឲ្យ អ្នកទាន់នៅរស់ ចូរឲ្យទានទាំងឡាយចុះ ។ កូនកង្កែបនេះ ឈ្មោះថា អច្ចិមុខី ពេញដោយតេជះរបស់ពស់ដ៏ខ្ពង់ខ្ពស់ អាត្មានឹងប្រើនាងអច្ចិមុខីនោះ ឲ្យខាំអ្នក នាងអច្ចិមុខីនោះនឹងធ្វើអ្នកឲ្យទៅជាផេះ ។ នាងអច្ចិមុខីនោះ ជាធីតារបស់ព្រះបាទធតរដ្ឋ មានមាតាផ្សេងគ្នា ជាប្អូនស្រីរបស់អាត្មា ដ៏ពេញដោយតេជះរបស់ពស់ដ៏ខ្ពង់ខ្ពស់ ចូរខាំចុះ" ។

## កម្លាំងពិសរបស់នាងអជមុខី

លុះពេលយ៉ាងនេះហើយ តាបសលាតដៃហៅប្អូនស្រី ក្នុងកណ្តាលមហាជនថា ៖

"នែនាងអជមុខី នាងចូរចេញពីចន្លោះជដាយើងហើយឋិតនៅលើដៃ" ។

នាងអជមុខី ឮសំឡេងរបស់តាបស អន្ទ្រើយ ដំអក់នៅចន្លោះជដាជាបែបកន្ត្រើប ៣ ដង ទើបបានលោតចេញមកអន្ទ្រើយលើចង្កើយស្មាហើយលោតញាំងពិស ៣ តំណក់ឲ្យធ្លាក់លើបាតដៃរបស់តាបស រួចចូលទៅកាន់ចន្លោះជដារបស់តាបសវិញភ្លាម ។ តាបស ចាប់ពិសឈរស្រែកសំឡេងយ៉ាងខ្លាំង ៣ ដងថា "វិនាស ហើយជនបទនេះវិនាសហើយជនបទនេះ" ។ សំឡេងតាបសដែលស្រែកនោះ បានលាន់ឮគ្រប់ដណ្តប់ក្រុងពារាណសីដែលមានទំហំ ១២ យោជន៍ ។ គ្រានោះព្រះរាជាឮសំឡេងនោះ សួរថា ៖

"ជនបទនឹងវិនាស ព្រោះហេតុអ្វី ?" ។

តាបសក្រាបទូលថា ៖

"បពិត្រមហារាជ អាត្មាភាពមិនឃើញកន្លែងដាក់ចុះនៃពិសនេះ"

ស្ដេចថា ៖

"នែអ្នក ផែនដីនេះ ធំណាស់ អ្នកចូរដាក់ចុះលើផែនដីចុះ" ។ គ្រានោះ តាបសជំទាស់នឹងស្ដេចថា ៖

"មិនអាចដាក់លើផែនដីទេ មហារាជ"

រួចក្រាបទូលថា ៖

"បពិត្រព្រះអង្គ ព្រះនាមព្រហ្មទត្ត សូមទ្រង់ជ្រាបចុះ បើអាត្មាភាព សាចពិសទៅលើផែនដី ស្មៅ វល្លិ ពួកឈើ ជាឱសថ នឹងស្វិតស្រពោនគ្មានសល់ ព្រោះហេតុដូច្នោះ មិនអាចដាក់វាលើផែនដីទេ" ។

ស្ដេចថា ៖

"នែ៎អ្នក បើដូច្នោះ ចូរបោះវាទៅអាកាសខាងលើ" ។

តាបសថា ៖

"សូម្បីទីនោះ ក៏មិនអាចដែរ"

ហើយតាបសបានបន្តពោលថា ៖

"បពិត្រព្រះអង្គ ព្រះនាមព្រហ្មទត្ត សូមទ្រង់ជ្រាបចុះ បើអាត្មាភាព សាចពិសទៅខាងលើ ភ្លៀងនឹងមិនបង្អុរចុះ ទឹកសន្សើមនឹងមិនធ្លាក់ចុះ អស់ ៧ ឆ្នាំ" ។

"នែ៎អ្នក បើអ៊ីចឹង សាចវាទៅក្នុងទឹក" ព្រះរាជាត្រាស់ ។
"សូម្បីទីនោះ ក៏មិនអាចដែរ" តាបសពោល និងបន្តថា ៖

"បពិត្រព្រះអង្គ ព្រះនាមព្រហ្មទត្ត សូមទ្រង់ជ្រាបចុះ បើអាត្មាភាព សាចពិសទៅក្នុងទឹក ត្រីនិងអណ្តើកដែលជាសត្វកើតក្នុងទិសទាំងប៉ុន្មាន នឹងស្លាប់ទាំងអស់" ។

គ្រានោះ ព្រះរាជានិយាយនឹងតាបសថា ៖

"នែ៎អ្នក យើងមិនដឹងអ្វីទេ អ្នកចូរដឹងឧបាយនោះដោយខ្លួនឯង ធ្វើយ៉ាងណាកុំឲ្យតែរដ្ឋរបស់យើងវិនាស" ។

តាបសថា ៖

"បពិត្រមហារាជ បើអ៊ីចឹង សូមព្រះអង្គឲ្យគេជីករណ្ដៅ ៣ តាមលំដាប់គ្នា ក្នុងទីនេះ" ។

ព្រះរាជាបានឲ្យគេជីក តាមយ៉ាងនោះ ។ តាបស បានឲ្យគេបំពេញរណ្ដៅដំបូង ដោយកេសជ្ជនានា, រណ្ដៅទីពីរ ដោយអាចម៍គោ, រណ្ដៅទីបី ដោយឱសថទិព្វ ។ គ្រានោះ តាបសទម្លាក់តំណក់ពិស ក្នុងរណ្ដៅដំបូង ។ ក្នុងខណៈនោះឯង អណ្ដាតភ្លើងឆេះសន្ធោសន្ធៅឡើង ។ អណ្ដាតភ្លើងឆេះរាលទៅរណ្ដៅអាចម៍គោ ។ បន្ទាប់ពីនោះ អណ្ដាតភ្លើងឆេះរាលឡើងទៅរណ្ដៅ ដែលពេញដោយឱសថទិព្វ ហើយឆេះឱសថទិព្វនោះរួចទើបរលត់ ។ អាលម្ពាយ ឈរមិនឆ្ងាយ ប៉ុន្មានអំពីរណ្ដៅនោះ ។ គ្រានោះ ចំហាយពិស បានចូលទៅរកគាត់ ញ៉ាំងសម្បុរឲ្យពុរពងដោរឡើងសាច់ដោរជ្រាក របកចេញស្បែកស ដូចកើតរោគឃ្លង់ ។ គាត់ភ័យខ្លាច បានបញ្ចេញវាចា ៣ ដងថា ៖

"ខ្ញុំនឹងដោះលែងនាគរាជ ៗ" ។

ពុទ្ធដូច្នោះ ពោធិសត្វយើង បានចេញអំពីហិបកែវ និម្មិតនូវអត្តភាពខ្លួនប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ទ្រង់ឈរជំហរដូចទេវរាជ ។ សុទស្សនៈនិងនាងអជមុខី បានឈរ ដោយលំនាំដូច្នោះដែរ ។ គ្រានោះ សុទស្សនៈបានក្រាបទូលព្រះរាជាថា ៖

"ស្គាល់ពួកទូលបង្គំឬទេ មហាបពិត្រ ?, ថាយើទាំងនេះជាបុត្រ របស់នរណា ?" ។

"ទេ យើងមិនស្គាល់ទេ" ស្តេចត្រាស់ ។

សុទស្សនៈថា ៖

"ព្រះអង្គមិនស្គាល់យើង ក៏ហីទៅចុះ, ចុះព្រះអង្គស្គាល់សមុទ្ទជា ជាធីតានៃស្តេចក្រុងពារាណសី ដែលទ្រង់បានថ្វាយដល់ស្តេច ធតរដ្ឋឬទេ ក្រាបទូល ?" ។

"អើយើងស្គាល់, នាងជាប្អូនស្រីពៅរបស់យើង" ស្តេចត្រាស់ ។

សុទស្សនៈថា ៖

"ពួកទូលបង្គំ គឺជាបុត្ររបស់ព្រះនាងសមុទ្ទជានុ៎ះឯង ព្រះអង្គ ត្រូវជាព្រះមាតុលារបស់ពួកទូលបង្គំ" ។

ព្រះរាជា ទ្រង់ព្រះសណ្តាប់ដូច្នោះហើយ ទ្រង់ញាប់ញ័រក្នុងឱរា ស្ទុះពីបល្ល័ង្កទៅឱបពួកគេ ថើបជញ្ជក់ព្រះសីសៈ ហូរទឹកព្រះនេត្រា ហើយនាំឡើងលើប្រាសាទ ឲ្យគេធ្វើសក្ការៈដ៏ធំ ហើយទ្រង់ធ្វើនូវ បដិសណ្ឋារៈជាមួយនឹងភូរិទត្ត និងសាកសួរថា "នែ៎អ្នក អ្នកមានតេជះ

ខ្ពង់ខ្ពស់ជាបែបនេះ ម្ដេចឡើយក៏អាលម្ពាយចាប់បាន" ។ ភូរិទត្តបាន ក្រាបទូលដោយពិស្ដារ នូវរឿងរ៉ាវសព្វគ្រប់ កាលនឹងផ្ដល់នូវដំបូន្មាន ដល់ព្រះរាជា លោកបានសម្ដែងធម៌ដល់ព្រះមាតុលាថា "បពិត្រមហារាជ ធម្មតាការដែលស្ដេចសោយរាជ្យតាមទំនងនេះទើបគួរ"។ គ្រានោះ សុទស្សនៈ ក្រាបទូលស្ដេចថា "បពិត្រព្រះមាតុលា ព្រះមាតារបស់ទូលបង្គំ កាលមិនឃើញភូរិទត្ត ទ្រង់កំពុងតែលំបាក ពួកទូលបង្គំមិនអាចនៅបង្អង់យឺតយូរបានទេ" ។ ស្ដេចថា "ប្រពៃណាស់ ក្មួយ ពួកអ្នកទៅក៏ទៅចុះ ប៉ុន្ដែយើងវិញនឹកប្អូនស្រីយើងចង់ឃើញនាងណាស់ ធ្វើម្ដេចទៅយើងបានទៅឃើញនាង ?" ។ សុទស្សនៈសួរ "បពិត្រព្រះមាតុលា ស្ដេចកាសិរាជ ជាព្រះអយ្យកោរបស់ពួកទូលបង្គំ តើស្ដេចគង់នៅឯណា ?" ។ ព្រះរាជាថា "ក្មួយ ៗ អើយ ព្រះអយ្យកោមិនអាចរស់នៅដោយគ្មានប្អូនស្រីយើងបានទេ ទ្រង់បានលះបង់រាជ្យ ទៅបួសគង់នៅក្នុងព្រៃ ឈ្មោះវនសណ្ឌៈឯណោះបាត់ទៅហើយ" ។ សុទស្សនៈថា "បពិត្រព្រះមាតុលា ព្រះមាតារបស់ទូលបង្គំ មានបំណងចង់ឃើញព្រះអង្គផង ព្រះអយ្យកោផង ។ សូមព្រះអង្គទៅកាន់សម្នាក់របស់ព្រះអយ្យកោនៃទូលបង្គំ ក្នុងថ្ងៃនោះ ចាំពួកទូលបង្គំនាំយកព្រះមាតាមកកាន់សម្នាក់របស់ព្រះអយ្យកោ ព្រះអង្គគង់តែបានជួបព្រះមាតានៃពួកទូលបង្គំ ក្នុងទីនោះពុំខាន" ។ ពួកគេបានកំណត់ថ្ងៃដល់ព្រះមាតុលា

ដូច្នេះហើយ ក៏នាំគ្នាយាងចុះចាករាជនិវេសន៍ ។ ព្រះរាជា តាមជូនដំណើរពួកព្រះភាគិនេយ្យ (ក្មួយ) ហើយទ្រង់ស្រក់ទឹកព្រះនេត្រាយាងត្រឡប់មកវិញ ។ ជនទាំងនោះ បានមុជជ្រែកដីទៅកាន់ភពនាគវិញ ។

នគរបវេសនកណ្ឌ ចប់ ។

# ជំពូកទី៧

## ទន្លេយមុនាមិនអាចលាងបាបដែលបុគ្គលធ្វើហើយទេ នេសាទព្រាហ្មណ៍ទៅលាងបាបក្នុងទន្លេយមុនា

នាកាលព្រះមហាសត្តទៅដល់ភពនាគទាំងមូល មានតែសំឡេងខ្សឹកខ្សួលតែម្យ៉ាង ។ ព្រះអង្គលំបាកព្រះកាយ ព្រោះនៅក្នុងហិបរយៈពេលមួយខែ ក៏ទ្រង់ផ្ទំដោយអាការៈឈឺ ។ នាគទាំងឡាយ មកកាន់សម្នាក់របស់ព្រះអង្គ មានចំនួនឥតគណនា ។ ព្រះអង្គត្រូវនិយាយទាំងលំបាក ជាមួយនឹងពួកគេ ។ កាណារិដ្ឋដែលទៅកាន់ទេវលោក លុះមិនឃើញព្រះមហាសត្ត ក៏បានមកវិញមុនគេ ។ គ្រានោះ ពួកគេបានចាត់កាណារិដ្ឋៈធ្វើជាឆ្មាំទ្វារ ក្នុងកន្លែងអង្គុយរបស់ព្រះមហាសត្ត ដោយនឹកថា "គេកាចឃោរឃៅ, គេមានសមត្ថភាពឃាត់នាគបរិស័ទបាន" ។ ចំណែកសុភោគៈ ដែលត្រាច់ទៅរកពេញព្រៃហិមពាន្ត លុះពិនិត្យនូវមហាសមុទ្រនិងទន្លេផ្សេង ៗ ក្នុងភូមិភាគនោះហើយ ក៏ទៅពិនិត្យនូវទន្លេយមុនា រួចត្រឡប់មកវិញ ។ ចំណែកនេសាទព្រាហ្មណ៍ ឃើញអាលម្ពាយកើតឃ្លង់ គេគិតថា "អាលម្ពាយនេះកើតឃ្លង់ ព្រោះញ៉ាំងភូរិទត្តឲ្យលំបាក ប៉ុន្តែភូរិទត្តដែលមានឧបការច្រើនដល់អញជាដំបូងនោះ ក៏ត្រូវអញបង្ហាញដល់អាលម្ពាយ ព្រោះល្មោភ

កែវមណី បាបនោះនឹងមកដល់អញដែរ, ដរាបណាបាបនោះ មិនទាន់មកដល់ ដរាបនោះអញនឹងទៅទន្ទេយមុនា ធ្វើការបន្សាត់បាប ក្នុងកំពង់ទឹក ឈ្មោះបយាគៈ" លុះគិតដូច្នេះហើយ គេបានទៅទីនោះមុជនិយាយក្នុងទឹកថា "ខ្ញុំបានធ្វើអំពើប្រទូស្តមិត្រចំពោះភូរិទត្ត ខ្ញុំសូមបន្សាត់បាបនោះ" ។

## សុភោគៈចាប់ជ្រមុជនេសាទព្រាហ្មណ៍នៅក្នុងទឹក

គាប់ចួនខណៈនោះឯង សុភោគនាគរាជ បានមកដល់ទីនោះ ឮពាក្យរបស់នេសាទព្រាហ្មណ៍ ក៏គិតថា "ឮដំណឹងថាមនុស្សបាបនេះដំបូងគឺបងអញ បានប្រទានយសដ៏ធំដល់គេ ប៉ុន្តែគេបែរជាបង្ហាញបងអញដល់អាលម្ពាយ ព្រោះហេតុតែចង់បានកែវមណី អញនឹងមិនឲ្យជីវិតដល់គេទេ" ហើយរុំជើងទាំងពីររបស់នេសាទព្រាហ្មណ៍នោះដោយកន្ទុយ ទាញពន្លិចក្នុងទឹក និងបន្ធូរបន្តិច ក្នុងកាលរកដង្ហើមដក ។ នេសាទព្រាហ្មណ៍នោះ ងើបក្បាលឡើង ។ គ្រានោះ សុភោគៈទាញគេពន្លិចម្តងទៀត ។ កាលត្រូវនាគធ្វើឲ្យលំបាកជាច្រើនដង យ៉ាងនេះ នេសាទព្រាហ្មណ៍ងើបក្បាលឡើង ពោលថា ៖

"ទឹកដែលតាំងនៅក្នុងកំពង់បយាគៈ ដែលអញកំពុងស្រោច ជាទឹកដែលលោកសន្មតថា សម្រាប់លាងបាប ចុះខ្មោចអ្វីជ្រមុជអញចុះទៅក្នុងស្ទឹងយមុនាដ៏ជ្រៅ" ។

គ្រានោះ សុភោគៈតបទៅគេថា ៖

"នាគណាជាធំក្នុងលោក មានយសបានមកព័ទ្ធក្រុងពារាណសីដោយជុំវិញ អញជាកូននាគដ៏ប្រសើរនោះ ម្នាលព្រាហ្មណ៍ នាគទាំងឡាយហៅអញថា **សុភោគៈ** ដូច្នេះ" ។

គ្រានោះ ព្រាហ្មណ៍គិតថា "នេះជាប្អូនប្រុសរបស់ភូរិទត្ត គេនឹងមិនឲ្យជីវិតដល់អញទេ បើដូច្នោះមានតែអញធ្វើនូវចិត្តទន់ដោយការសរសើរនូវគុណរបស់សុភោគៈនោះផង របស់ព្រះមាតាបិតាគេផង ហើយសូមនូវជីវិតរបស់ខ្លួន" រួចគាត់បានពោលនឹងសុភោគៈថា ៖

"បើអ្នកជាកូននៃនាគដ៏ប្រសើរ ជាព្រះរាជាក្នុងដែនកាសី ជាធំជាងនាគដែលមានអាយុវែង បិតារបស់អ្នក ជានាគមានសក្តិធំមួយដែរ បណ្តាសត្វទាំងឡាយ មាតារបស់អ្នក ក៏មិនមានស្ត្រីណាផ្ទឹមបានឡើយ បុគ្គលមានអានុភាពច្រើនដូចអ្នក មិនគួរចាប់ជ្រមុជបុគ្គលសូម្បីជាទាសៈនៃព្រាហ្មណ៍ទេ" ។

គ្រានោះ សុភោគៈពោលនឹងព្រាហ្មណ៍ថា ៖

"នែ៎អាព្រាហ្មណ៍ អាក្រក់ចង្រៃ អ្នកសម្គាល់ថាឯងបញ្ឆោតអញ ហើយរួចខ្លួន អញនឹងមិនឲ្យជីវិតឯងទេ"

កាលនឹងប្រកាសអំពើដែលនេសាទព្រាហ្មណ៍បានធ្វើហើយ សុភោគៈ ក៏បានពោលថា ៖

"ឯងអែបដើមឈើ ហើយបាញ់ទ្រាយដែលមកផឹកទឹក ទ្រាយនោះដែលឯងបាញ់ហើយ ក៏ងាកមើលដោយកម្លាំងនៃសរ ក៏ស្ទុះទៅកាន់ទីឆ្ងាយ ។ ឯងបានឃើញទ្រាយនោះដួលក្នុងព្រៃធំ ក៏នាំសាច់មួយអម្រែកចូលទៅដើមជ្រៃ ក្នុងវេលាល្ងាច ជាឈើដែលគឹកកងដោយសត្វសេកនិងសាលិកា មានស្លឹកលឿង ដេរដាសដោយពួរ ដែលសត្វតៅវៅទំយំ ជាទីគួររីករាយ មានផែនដីដុះស្មៅខៀវជានិច្ច បងរបស់អញ ដែលមានអានុភាពច្រើន រុងរឿងដោយឫទ្ធិនិងយសដែលពួកនាគកញ្ញាចោមរោម ក៏ប្រាកដដល់ឯងក្នុងទីនោះ ។ ឯងនោះ ដែលបងរបស់អញនោះផ្គាប់ឲ្យស្កប់ស្កល់ដោយកាមទាំងពួង ឯងបានប្រទូស្តចំពោះបងដែលមិនប្រទូស្ត ពៀរនោះមកដល់ឯង ក្នុងទីនេះហើយ ។ ឯងចូរដេកក

*យ៉ាងឆាប់ អញនឹងមិនឲ្យជីវិតដល់ឯងទេ អញរលឹកឃើញពៀរដែលឯងធ្វើចំពោះបងអញ អញនឹងកាត់ក្បាលឯងឥឡូវនេះ" ។*

**សុភោគៈចាប់នេសាទព្រាហ្មណ៍ទៅភពនាគ**

*គ្រានោះ ព្រាហ្មណ៍គិតថា "គេមិនឲ្យជីវិតដល់អញទេ ការដែលអញព្យាយាមនិយាយអ្វីមួយដើម្បីរួចខ្លួន ទើបគួរ" រួចពោលថា ៖*

*"ព្រាហ្មណ៍ជាអ្នករៀនមន្ត ១ ជាអ្នកប្រកបដោយការសូម ១ ជាអ្នកបូជាភ្លើង ១ ព្រាហ្មណ៍ប្រកបដោយហេតុទាំង ៣ នេះ អ្នកមិនគួរសម្លាប់ទេ អ្នកមិនគួរសម្លាប់ព្រាហ្មណ៍ទេ អ្នកនិយាយអ្វីមែនពិត ជនណាសម្លាប់ព្រាហ្មណ៍ ជននោះគង់កើតក្នុងនរក" ។*

*ឮដូច្នោះ សុភោគៈកើតក្តីសង្ស័យ គិតថា "អញនឹងនាំព្រាហ្មណ៍នេះទៅកាន់ភពនាគ សាកសួរបងអញហើយ គង់តែនឹងដឹង" រួចបានពោលតបថា ៖*

*"នាគបុរីរបស់ព្រះបាទធតរដ្ឋ ជាវិការៈនៃមាសទាំងអស់ ដែលចូលទៅស្ទឹងយមុនា ទល់នឹងភ្នំហិមពាន្ត ដែលនៅជិតស្ទឹងយមុនារមែងរុងរឿង ។ បងប្អូនរបស់អញទាំងនោះ ជាបុរសក្លៀវក្លា ជាអ្នករួមផ្ទៃ នៅក្នុងបុរីនោះ កាលបើឯងត្រូវអញនាំទៅទីនោះ បង*

ប្អូនទាំងនោះ របស់អញក្នុងបុរីនោះ និយាយយ៉ាងណា ឯងនឹងទៅជាយ៉ាងនោះ មែនពិត ប្រសិនបើឯងនិយាយពាក្យពិត ឯងនឹងមានជីវិត តែបើមិនទេ អញនឹងកាត់ក្បាលឯង ក្នុងទីនោះពុំខាន" ។

និយាយនឹងគេដូច្នេះហើយ សុភោគៈចាប់ត្រង់ក ខាកស្តោះដេរ ផ្ដាសាទៅកាន់ទ្វារប្រាសាទរបស់ព្រះមហាសត្វ ។

មហាសត្តបរិយេសនយកណ្ឌ ចប់ ។

# ជំពូកទី៨

## ទ្រឹស្តីកាណារិដ្ឋៈខុសពីសេចក្តីពិត

### កាណារិដ្ឋៈពោលថាព្រាហ្មណ៍ជាបុត្រមហាព្រហ្ម

*គ្រានោះ កាណារិដ្ឋៈដែលអង្គុយធ្វើជាឆ្មាំទ្វារ ឃើញសុភោគៈជាបងនាំព្រាហ្មណ៍មកដោយធ្វើឲ្យលំបាកដូច្នោះ ក៏ដើរបញ្ច្រាសទៅស្រែកប្រាប់ថា ៖*

*"បងសុភោគៈ កុំធ្វើឲ្យគេលំបាកអី ដែលហៅថា ព្រាហ្មណ៍ ៗ គឺជាបុត្ររបស់មហាព្រហ្ម ប្រសិនបើមហាព្រហ្មដឹង ប្រាកដជាមហាព្រហ្មខឹងថាយើងរុកគួនកូនរបស់គេ ហើយនឹងញុាំងភពនាគទាំងមូលរបស់យើងឲ្យវិនាស ។ មែនពិត ក្នុងលោកនេះឈ្មោះថា ព្រាហ្មណ៍ ៗ គឺជាអ្នកប្រសើរ មានអានុភាពធំ អ្នកមិនដឹងអានុភាពរបស់ព្រាហ្មណ៍ទាំងឡាយទេឬអី ប៉ុន្តែខ្ញុំដឹង" ។*

### កំណត់ចំណាំ

*បានឮមកថា កាណារិដ្ឋៈ ធ្លាប់កើតជាព្រាហ្មណ៍អ្នកបូជាយញ្ញ ក្នុងភពបន្ទាប់ដែលកន្លងទៅ ហេតុនោះ បានជាគេពោលយ៉ាងនោះ ។*

លុះនិយាយយ៉ាងនេះហើយ ហេតុតែគេជាអ្នកបូជាយញ្ញជាប្រក្រតី តាមទម្លាប់ដែលធ្លាប់ គេក៏បានហៅសុភោគៈផង នាគបរិស័ទផងមក ប្រាប់ថា "មកណេះអ្នកទាំងឡាយ ខ្ញុំនឹងពណ៌នាគុណនៃពួកបុគ្គល អ្នកបូជាយញ្ញដល់ពួកអ្នក" ហើយកាណារិដ្ឋៈផ្ដើមពណ៌នាសរសើរ យញ្ញដូច្នេះ ៖

"បពិត្រសុភោគៈ យញ្ញនិងវេទទាំងឡាយក្នុងលោកនេះ ដែលព្រាហ្មណ៍ឯទៀតប្រកបហើយ មិនមែនជារបស់ផ្ដេសផ្ដាសទេ ព្រោះហេតុនោះ បុគ្គលកាលតិះដៀលព្រាហ្មណ៍ដែលមិនគួរតិះដៀល ឈ្មោះថាលះបង់ទ្រព្យនិងធម៌របស់ពួកសប្បុរស" ។

បានឮថា កាណារិដ្ឋៈនោះ បាននិយាយដូច្នេះដែរថា "សូមនាគបរិស័ទ កុំចេះតែនិយាយថា តាព្រាហ្មណ៍នេះ បានធ្វើអំពើប្រទូស្តមិត្រចំពោះភូរិទត្ត" ។

## កាណារិដ្ឋៈពោលថាព្រហ្មអ្នកបែងចែកវណ្ណៈ៤

គ្រានោះ កាណារិដ្ឋៈពោលនឹងសុភោគនោះថា "សុភោគៈ តើអ្នកដឹងឬទេថា លោកនេះ នរណាសាង ?" ។ សុភោគៈថា "ខ្ញុំមិនដឹងទេ" ។

ដើម្បីសម្តែងថា "មហាព្រហ្មដែលជាមហាបិតារបស់ពួកព្រាហ្មណ៍ ជាអ្នកសាង" កាណារិដ្ឋៈបានពោលជាបន្តថា ៖

"តាមឮត ។ មកថា ព្រហ្មបាននិម្មិតវណ្ណៈទាំង ៤ មានព្រាហ្មណ៍ជាដើមឲ្យមានឡើង ហើយបានចាត់ផែនការដល់ព្រាហ្មណ៍ដ៏ប្រសើរមុនគេថា "ម្នាលព្រាហ្មណ៍ អ្នកទាំងឡាយចូរគ្រាន់ខាងការរៀនមន្តចំណេះវិជ្ជា កុំធ្វើអ្វីផ្សេងឲ្យសោះ" បន្ទាប់មក ចាត់ផែនការដល់ពួកជាធំជាងជន គឺក្សត្រិយ៍ថា "អ្នកទាំងឡាយ ចូរប្រកាន់ខាងការផែនដី" បន្ទាប់មក ចាត់ផែនការដល់ពួកវេស្សៈថា "អ្នកទាំងឡាយចូរប្រកាន់ខាងការភ្ជួររាស់" បន្ទាប់មក ចាត់ផែនការដល់ពួកសូទ្រៈថា "អ្នកទាំងឡាយ ចូរប្រកាន់ខាងការបម្រើផ្សេង ។ គ្នា តាមសមគួរដល់ត្រកូលនិងប្រទេសរបស់ខ្លួន" ជនទាំងឡាយបានពោលថា ត្រកូលទាំង ៤ នេះ គឺមហាព្រហ្ម អ្នករស់នៅដោយប្រក្រតី បានតាក់តែងឲ្យមានឡើង ។ ពីគ្រានោះមក ជនទាំងឡាយតែងនិយាយថា ព្រាហ្មណ៍ប្រកាន់ខាងការ រៀនសូត្រ, ក្សត្រិយ៍ប្រកាន់ខាងការគ្រប់គ្រងអាណាចក្រ, វេស្សៈប្រកាន់ខាងការងារកសិកម្ម, សូទ្រៈគ្រាន់ខាងការបម្រើ" ។

កាណារិដ្ឋៈបន្ថែមថា ៖

"ដែលហៅថា ព្រាហ្មណ៍ ៗ នោះតែងមានគុណច្រើនយ៉ាងនេះ ។ មែនពិត ជនណាញុំាងចិត្តឲ្យជ្រះថ្លាចំពោះព្រាហ្មណ៍ទាំងនោះ ហើយឲ្យទាន បដិសន្ធិរបស់គេ រមែងមិនមានក្នុងទីដទៃទេ រមែងទៅកាន់ទេវលោកតែម៉្យាង"

រូបបន្តពោលថា ៖

"ទេវរាជព្រះនាមធាតុ វិធាតុ វរុណៈ កុវេរៈ សោមៈ យមៈ ចន្ទិមៈ វាយុ សុរិយៈ ស្ដេចទាំងនេះ បានបូជាយញ្ញដ៏ច្រើន ទាំងបានឲ្យវត្ថុជាទីប្រាថ្នាគ្រប់យ៉ាង ដល់ពួកព្រាហ្មណ៍អ្នករៀនមន្ត ។ ព្រះបាទអជ្ជុន ដែលមានកម្លាំង មានសេនាគួរខ្លាច មានដៃមួយពាន់ មិនមានបុគ្គលណាស្មើលើផែនដី ជាអ្នកឃឹតធ្នូ ៥០០ បាន ទ្រង់ក៏បូជាភ្លើង ទាំងបានឲ្យវត្ថុជាទីប្រាថ្នាគ្រប់យ៉ាង ដល់ពួកព្រាហ្មណ៍ក្នុងកាលនោះដែរ ទ្រង់កើតក្នុងទេវលោកដោយហេតុនោះឯង ។ ព្រោះដូច្នោះ ដែលហៅថា ព្រាហ្មណ៍ ៗ គឺជារៀមច្បងលើគេក្នុងលោកនេះ" ។

កាណារិដ្ឋៈនោះ បានពោលសរសើរព្រាហ្មណ៍ទាំងឡាយបន្ថែមដូច្នេះថា ៖

"មានស្តេចក្រុងពារាណសីជំនាន់បុរាណមួយអង្គ ដែលមានចិត្តជ្រះថ្លា រីករាយ បានញុាំងព្រាហ្មណ៍ឲ្យបរិភោគបាយនិងទឹក អស់កាលយូរ ដ៏សមគួរតាមអានុភាព ។ បពិត្រសុភោគ ស្តេចអង្គនោះបានកើតជាទេវរាជមានសក្តិធំមួយអង្គ ។ តាមដែលពោលមកនេះ ហៅថា ព្រាហ្មណ៍ គឺជាអគ្គទក្ខិណេយ្យបុគ្គល" ។

គ្រានោះ កាណារិដ្ឋៈទាញហេតុផលមួយទៀតយកមកពោល ៖

"ព្រះបាទមុចលិន្ទ អាចញុាំងទេវតាភ្លើងជាអ្នកស៊ីច្រើន មានពន្លឺមិនថោកទាប ឲ្យស្កប់ស្កល់ដោយសប្បិ បានបូជាវិធីយញ្ញចំពោះទេវតាភ្លើងដ៏ប្រសើរ ទ្រង់បានទៅកាន់គតិជាទិព្យ" ។

តាមឮមកថា ព្រះរាជាមួយអង្គ ព្រះនាមថា **មុចលិន្ទ** ក្នុងក្រុងពារាណសី ទ្រង់ឲ្យគេអញ្ជើញព្រាហ្មណ៍ទាំងឡាយមកហើយ ទ្រង់បានសួរនូវផ្លូវឋានសួគ៌ ។ គ្រានោះ ព្រាហ្មណ៍ទាំងឡាយក្រាបទូលដល់ព្រះ អង្គថា "សូមព្រះអង្គធ្វើនូវសក្ការៈ ដល់ព្រាហ្មណ៍ទាំងឡាយផង ដល់ទេវតាព្រាហ្មណ៍ទាំងឡាយផង" ។ "នរណា ជាទេវតាព្រាហ្មណ៍ ?" ស្តេចសួរ ។ ពួកព្រាហ្មណ៍ក្រាបទូល "គឺព្រះអគ្គី សូមព្រះអង្គញុាំងព្រះអគ្គីនោះឲ្យស្កប់ស្កល់ ដោយទឹកដោះជូរនិងទឹកដោះស្រស់" ។ ព្រះបាទមុចលិន្ទ ទ្រង់បានធ្វើតាមយ៉ាងនោះ ។ កាណារិដ្ឋៈ

*បានលើករឿងនេះមកជាអំណះអំណាង ដើម្បីប្រកាសទស្សនាទាន របស់ខ្លួនឲ្យបានជាក់ច្បាស់ ។ កាណារិដ្ឋៈ បានសម្ដែងនូវហេតុផល មួយទៀតថា ៖*

*"ព្រះរាជា ព្រះនាមទុទីបៈ មានអានុភាពច្រើន មានព្រះជន្ម ១.០០០ ឆ្នាំ កាលសោយរាជ្យ ៥០០ ឆ្នាំ ទ្រង់បានបូជាធ្វើសក្ការៈ ដល់ព្រាហ្មណ៍ទាំងឡាយ ហើយបានលះបង់ដែនព្រមទាំងសេនា មិនមានទីបំផុត ទៅបួសបានជាទក្ខិណេយ្យបុគ្គល គួររមឹល មើលដ៏លើសលុប ទ្រង់បានទៅកាន់ឋានសួគ៌" ។*

## កាណារិដ្ឋៈថ្លែងពីមូលហេតុកើតស្ទឹងទន្លេសមុទ្រ

*កាណារិដ្ឋៈ បានសម្ដែងនូវឧទាហរណ៍ជាច្រើនទៀតដល់សុភោគៈ ដូច្នេះថា ៖*

*"បពិត្រសុភោគៈ ព្រះបាទសាគរឈ្នះផែនដីមានសាគរជាទីបំផុត ទ្រង់បានសួរផ្លូវសួគ៌ នឹងព្រាហ្មណ៍ទាំងឡាយ ។ ព្រាហ្មណ៍ទាំង ឡាយថា សូមព្រះអង្គឲ្យគេលើកឡើងសសរមាស ស្ដេចអង្គនោះ ក៏បានឲ្យគេលើកសសរយញ្ញដ៏ល្អ ជាវិការៈនៃមាសដ៏លើសលុប ដើម្បីសម្លាប់ បសុសត្វបូជាភ្លើង ។ បពិត្រសុភោគ ស្ដេចអង្គនោះ*

ឯង ក្រោយពីបូជាភ្លើងហើយ ទ្រង់បានជាទេវតាសក្តិធំមួយអង្គ ។ បពិត្រសុភោគៈ តើលោកដឹងថាទន្លេគង្គានិងមហាសមុទ្រ នរណា សាងឬទេ ? ។

សុភោគៈថា ៖

"ខ្ញុំមិនដឹងទេ" ។

កាណារិដ្ឋៈថា ៖

"រឿងអ៊ីចឹង ៗ លោកមិនដឹងទេ ដឹងតែរឿងវាយព្រាហ្មណ៍ ។ មែនពិត កាលពីអតីត កាលស្តេចក្រុងពារាណសី ដែលមានពោមត្រង់ព្រះបាទព្រះនាមថា អង្គៈ ទ្រង់បានសួរផ្លូវសួគ៌នឹងព្រាហ្មណ៍ទាំងឡាយដែរ កាលបើពួកគេក្រាបទូលថា បពិត្រមហារាជដ៏ចម្រើន សូមទ្រង់ ចូលទៅព្រៃហិមពាន្ត ធ្វើសក្ការៈដល់ព្រាហ្មណ៍ទាំងឡាយហើយ បម្រើភ្លើងចុះ, ស្តេចអង្គៈនោះបានយកមេគោមេក្របី មិនមានប្រមាណ ចូលទៅព្រៃហិមពាន្ត ហើយបានធ្វើតាមយ៉ាងនោះ ។ ពួកព្រាហ្មណ៍សួរថា ទឹកដោះស្រស់និងទឹកដោះជូរ ដែលសល់ពី ការបរិភោគ តើត្រូវធ្វើដូចម្តេច ? ។ ស្តេចថា សូមលោកម្ចាស់ចាក់ចោល ។ កន្លែងចាក់ទឹកដោះស្រស់បន្តិច ទីនោះ

បានក្លាយជាស្ទឹង ។ កន្លែងចាក់ចោលច្រើន វាបានហូរកាត់បណ្តាលឲ្យទីនោះ ក្លាយជាទន្លេគង្គា មិនតែប៉ុណ្ណោះ ទឹកដោះស្រស់ដែលនៅតែហូរនោះ បានទៅនៅជាមួយគ្នា ហើយក្លាយទៅជាជួរនៅកន្លែងណា កន្លែងនោះក៏ក្លាយទៅជាសមុទ្រ ហៅរហូតដល់សព្វថ្ងៃ ។ ដោយប្រការដូចពោលមកនេះ ព្រះបាទអង្គៈមានពោមត្រង់ព្រះបាទនោះ បានធ្វើសក្ការៈបែបនេះ បម្រើភ្លើងតាមវិធានដែលពួកព្រាហ្មណ៍ប្រាប់ ក៏ទ្រង់បានទៅកាន់បុរីព្រះឥន្ទ្រសហស្សក្ខ" ។

លុះនាំអតីតនិទាននេះមកតំណាលដល់សុភោគដូច្នេះ កាណារិដ្ឋៈបានពោលតទៅថា ៖

"បពិត្រសុភោគៈ ទេវបុត្រដ៏ប្រសើរ មានឫទ្ធិច្រើន មានយស ជាសេនាបតីនៃព្រះបាទវាសវៈ គឺសក្កទេវរាជ ក្នុងឋានត្រៃត្រិង្ស ដើមឡើយ គេជាស្តេចក្រុងពារាណសីមួយអង្គបានសួរផ្លូវសួគ៌នឹងព្រាហ្មណ៍ទាំងឡាយដែរ កាលបើពួកគេពិតទូលថា សូមព្រះអង្គលាងជម្រះនូវមន្ទិលរបស់ខ្លួន ដោយសោមយាគវិធី ហើយចូរទៅកាន់ទេវលោក ។ ស្តេចអង្គនោះ បានរៀបគ្រឿងសក្ការៈជូនដល់ព្រាហ្មណ៍ទាំងឡាយ ធ្វើសោមយាគវិធីតាម

*វិធានដែលពួកគេប្រាប់ ជម្រះនូវមន្ទិលរបស់ខ្លួន ដោយវិធីនោះ ហើយក៏បានជាទេវតាមួយអង្គ" ។*

## **កាណារិដ្ឋៈថ្លែងពីមូលហេតុកើតភ្នំ**

*កាណារិដ្ឋៈ បានសម្តែងនូវឧទាហរណ៍ជាច្រើនទៀត ដល់សុភោគៈ ដូច្នេះថា ៖*

*"ទេវតាដ៏ប្រសើរ គឺមហាព្រហ្មមានឫទ្ធិច្រើន មានយសធំ បានសាងលោកនេះផង លោកដទៃផង និងគង្គាភាគីរថីផង ភ្នំហិមពាន្តផង ភ្នំវិជ្ឈៈផង គេមុននឹងកើតជាព្រហ្មនោះ ដើមឡើយគឺជាមាណពម្នាក់ ក៏បានបូជាភ្លើងក្នុងកាលនោះដែរ លុះបូជាភ្លើងហើយ បានកើតជាមហាព្រហ្ម សាងអ្វី ៗ ទាំងពួងនេះ ។ មហាព្រហ្ម មានឫទ្ធិច្រើនយ៉ាងនេះឯង។ ម៉្យាងទៀត តាមពុត ៗ មកថា ពីមុន ស្តេចក្រុងពារាណសីមួយអង្គ បានសួរផ្លូវសួគ៌ នឹងព្រាហ្មណ៍ទាំងឡាយ ។ ពួកគេប្រាប់ថា សូមព្រះអង្គ ធ្វើនូវសក្ការៈដល់ព្រាហ្មណ៍ទាំងឡាយ ។ ស្តេចអង្គនោះបានឲ្យគេតាំងមហាទាន ដល់ពួកព្រាហ្មណ៍ រួចសួរថា អ្វីមិនមានក្នុងទានរបស់ខ្ញុំព្រះករុណា ។ ពួកព្រាហ្មណ៍ថា មានសព្វគ្រប់អស់ហើយព្រះសម្មតិទេព ប៉ុន្តែអាសនៈមិនគ្រប់គ្រាន់សម្រាប់ពួកព្រាហ្មណ៍*

ទេ ។ ព្រះរាជាចេញបញ្ជាឲ្យធ្វើអាសនៈទាំងឡាយកដោយឥដ្ឋ ។ កៅអីអាសនៈដ៏វិចិត្រក្នុងគ្រានោះ បេះតែខ្ពង់ ៗ ឡើងដោយអានុភាពរបស់ព្រាហ្មណ៍ទាំងឡាយ ហើយបានទៅជាភ្នំមាលាគិរី ១ ភ្នំហិមពាន្ត ១ ភ្នំវិជ្ឈៈ ១ ភ្នំសុទស្សនៈ ១ ភ្នំនិសកៈ ១ ភ្នំកាកវេរុ ១ ។ ពួកព្រាហ្មណ៍ពោលថា ភ្នំទាំងនេះក្តី ភ្នំដទៃធំ ៗ ក្តី គឺពួកព្រាហ្មណ៍អ្នកបូជាយញ្ញ បានធ្វើឲ្យវិចិត្រហើយ" ។

## កាណារិដ្ឋៈថ្លែងពីមូលហេតុទឹកសមុទ្រប្រៃ

គ្រានោះ កាណារិដ្ឋៈសួរបងគេថា ៖

"បពិត្របង ចុះលោកដឹងឬទេថា សមុទ្រនេះ ហេតុម្តេចឡើយបានជាវាមានទឹកប្រៃផឹកមិនបាន ?" ។

សុភោគថា ៖

"អញមិនដឹងទេ អរិដ្ឋៈ" ។

ទើបកាណារិដ្ឋៈថា ៖

"បងឯងដឹងតែវាយធ្វើបាបពួកព្រាហ្មណ៍ទេ, ល្ងង់អើយ ! ចូរស្ដាប់ចុះ"

រួចពោលថា ៖

"ជនទាំងឡាយ បានហៅព្រាហ្មណ៍អ្នករៀនមន្ត បរិបូណ៌ដោយគុណនៃមន្ត មានតបៈក្នុងលោកនេះ ថាជាអ្នកប្រកបដោយការសូម ។ តាមឮមកថា ក្នុងថ្ងៃមួយ ព្រាហ្មណ៍នោះកំពុងធ្វើកម្មគឺការបណ្ដែតបាប គាត់បានឈរលើច្រាំង ក្បួងទឹកអំពីសមុទ្រសាចប្រោះព្រំពីខាងលើក្បាលរបស់ខ្លួន ។ គ្រានោះ សាគរបានជន់ឡើងក្ដួចពន្លិចព្រាហ្មណ៍ ដែលគាត់កំពុងតែធ្វើយ៉ាងនេះ ។ មហាព្រហ្មជ្រាបស្ដានការណ៍នោះ ខឹងសម្បាថា ឮថាសាគរនេះនេះវាហ៊ានប្រហារបុត្ររបស់អញ ហើយផ្ដាសាថា ចូរសមុទ្រមានទឹកប្រៃផឹកមិនបាន ។ ដោយហេតុនោះ បានជាសមុទ្រមានទឹកប្រៃ ផឹកមិនបាន រហូតដល់សព្វថ្ងៃ ។ ដែលហៅថា ព្រាហ្មណ៍ ៗ នោះ តែងមានអានុភាពធំជាបែបនេះឯង" ។

កាណារិដ្ឋៈពោលបន្ថែមទៀតថា ៖

"កាលដើមឡើយ ស្តេចវាសវៈឲ្យទានដល់ព្រាហ្មណ៍ទាំងឡាយ ទើបដល់នូវភាពជាស្តេចវាសវៈ ។ ឥឡូវនេះ ព្រាហ្មណ៍ទាំងឡាយ ជាទីសក្ការបូជា ជាបុញ្ញក្ខេត្ត ជាអគ្គទក្ខិណេយ្យ មានច្រើនលើផែនដី មានក្នុងទិសខាងកើត ទិសខាងលិច ទិសខាងត្បូង និងទិសខាងជើង តែងញ៉ាំងសេចក្តីត្រេកអរឲ្យកើតដល់វាសវៈ នាំមកនូវបីតិសោមនស្ស" ។

ដោយប្រការដូចដែលពោលមកនេះ អរិដ្ឋៈ បានសរសើរនូវព្រាហ្មណ៍ទាំងឡាយផង យញ្ញផង វេទទាំងឡាយផង ដោយគាថា ១៤ ដូចសេចក្តីប្រែខាងលើ ។

មិច្ឆាកថា ចប់ ។

# ជំពូកទី៩

## ព្រះនាងសមុទ្ទជាជួបព្រះបិតានិងព្រះជេដ្ឋា

### ភូរិទត្តដោះស្រាយមិច្ឆាកថា

*នាគទាំងឡាយជាច្រើន ដែលមកកាន់គិលានុបដ្ឋានរបស់ព្រះមហាសត្ត លុះឮសម្ដីនោះរបស់អរិដ្ឋៈ ម្នាក់ ៗ កើតអាការប្រកាន់ដោយសេចក្ដីប្រកាន់ខុសថា "អរិដ្ឋៈនេះ និយាយនូវពាក្យពិតឥតខ្ចោះ" ។ ព្រះមហាសត្តកំពុងផ្ទំដោយអាការឈឺ នៅមិនទាន់ក្រោករួចនៅឡើយក៏បានឮនូវរាល់សម្ដីរបស់អរិដ្ឋៈនោះ ទាំងនាគទាំងឡាយក៏មកជម្រាបឲ្យព្រះអង្គបានជ្រាបដែរ ។ គ្រានោះ ព្រះមហាសត្តគិតថា "អរិដ្ឋៈបានសរសើរផ្លូវខុស អញនឹងបំបែកទ្រឹស្ដីរបស់គេធ្វើបរិស័ទឲ្យទៅជាអ្នកមានសម្មាទិដ្ឋិ" ។ ព្រះមហាសត្ត ក្រោកឡើង ងូតទឹក ប្រដាប់អលង្ការទាំងពួង ហើយអង្គុយលើធម្មាសនៈ ញុំាងនាគបរិស័ទទាំងពួងឲ្យជួបជុំគ្នា រួចប្រើឲ្យគេទៅហៅអរិដ្ឋៈចូលមកជួប និងបានប្រាប់ថា ៖*

> *"នែ៎អរិដ្ឋៈ អ្នកនិយាយពាក្យមិនពិត សរសើរវេទទាំងឡាយផង យញ្ញទាំងឡាយផង ព្រាហ្មណ៍ទាំងឡាយផង, ជាការពិតណាស់ ដែលហៅថាការបូជាយញ្ញ ដោយវេទវិធី របស់ព្រាហ្មណ៍ទាំង*

ឡាយ គឺវាសន្មតឡើងដោយ អនរិយជន មិនមែនជាផ្លូវទៅកាន់ឋានសួគ៌ទេ អ្នកចូរមើលនូវភាពមិនពិត ក្នុងវាទៈរបស់អ្នក"

ដូច្នេះហើយភូរិទត្តបានពោលប្រាប់ទៅនឹងវាទៈស្តីពីប្រភេទយញ្ញថា ៖

"ម្នាលអរិដ្ឋៈ ការរៀនយកនូវវេទទាំងឡាយ ជាទោសរបស់អ្នកប្រាជ្ញទាំងឡាយ តែជាអំពើរបស់បុគ្គលពាលទាំងឡាយ ត្រៃវេទជាធម៌ ដូចថ្ងៃបណ្តើរកូនព្រោះសម្ទឹងមើលមិនស្មើវេទទាំងឡាយជាចំណែកនៃកលឧបាយ ទង់ទាញអ្នកមានបញ្ញាមិនបានទេ ការពារជនអ្នកទ្រុស្តមិត្រ បំផ្លាញសេចក្តីចម្រើននោះ ក៏មិនបានទេ ភ្លើងដែលបុគ្គលបម្រើហើយ រមែងមិនការពារនូវសត្វមានកម្មបានទេ ជារបស់មិនប្រសើរ ប្រកបដោយទោស ។ មួយទៀតសត្វទាំងឡាយមានទ្រព្យ មានភោគ យកទ្រព្យទាំងអស់លាយដោយឧសនិងស្មៅហើយដុតភ្លើងមានតេជះ មិនមានអ្វីស្មើ កាលឆេះវត្ថុដែលគេដុតហើយ ក៏មិនគប្បីឆ្អែត ម្នាលអ្នកដឹងរសដោយអណ្តាតទាំងពីរ ចុះបុគ្គលណាគប្បីធ្វើភ្លើងនោះឲ្យឆ្អែត ។ ខីរៈមានការប្រែប្រួលជាធម្មតា ក្លាយទៅជាទធិ ហើយទៅជា នវនីតយ៉ាងណា ភ្លើងជាតេជោធាតុ មានការប្រែប្រួលជាធម្មតា យ៉ាងនោះដែរ លុះតែប្រកបដោយគ្រឿងពួត ទើបឆេះ ។ ភ្លើងដែល

ចូលទៅ ក្នុងឈើស្ងួតឬឈើស្រស់ ក៏មិនប្រាកដ ភ្លើងដែលនរជន មានឈើ ពំនួតក្នុងដៃ មិនបានពួត ក៏មិនឆេះ ភ្លើងមិនមែនឆេះ ដោយការមិនធ្វើ ទេ ។ ប្រសិនបើភ្លើងនៅក្នុងឈើស្ងួត ឬឈើ ស្រស់ នៅខាងក្នុង នៅក្នុងព្រៃទាំងអស់ក្នុងលោក គប្បីស្ងួតក្រៀម ឯឈើស្ងួតទាំងឡាយគប្បីឆេះ ។ ថាបើនរជនញ៉ាំងភ្លើងដ៏ក្តៅ ប្រកបដោយផ្សែង និងអណ្តាតឲ្យស៊ី ដោយឧសនិងស្មៅ ឈ្មោះ ថា ធ្វើបុណ្យឬជនអ្នកធ្វើ ធ្យូង អ្នកធ្វើអំបិល អ្នកធ្វើអាហារ និង អ្នកដុតសរីរៈនៃបុគ្គលស្លាប់ ឈ្មោះថា ធ្វើបុណ្យដែរឬ ។ ប្រសិន បើព្រាហ្មណ៍ទាំងនុ៎ះ ញ៉ាំងការរៀនមន្តនិងភ្លើងឲ្យឆេះតក្នុងលោក នេះ ទើបឈ្មោះថាធ្វើបុណ្យ នរជនណាមួយ ក្នុងលោក កាល ញ៉ាំងភ្លើងមានកម្តៅប្រកបដោយផ្សែងនិងអណ្តាត ឲ្យស៊ី មិន ឈ្មោះថាធ្វើបុណ្យទេ ។ ម្នាលអ្នកដឹងរសដោយអណ្តាតពីរ អគ្គិ- ទេពរបស់អ្នក ដែលលោកគោរពហើយ ម្តេចក៏ស៊ីវត្ថុមានក្លិនមិន ជាទីគាប់ចិត្ត មិនជាទីត្រេកអរនៃជនដ៏ច្រើន ដែលពួកមនុស្ស តែងវៀរ ជាវត្ថុមិនប្រសើរនោះ ។ មនុស្សពួកខ្លះ ពោលថាភ្លើងជា ទេវតាមួយអង្គ ក្នុងពួកទេវតា ឯពួកមិលក្ខុជន ពោលថាទឹកជា ទេវតា ជនទាំងអស់នុ៎ះ ពោលខុស ភ្លើងមិនមែនជាទេវតាណា មួយទេ ទឹកក៏មិនមែនដែរ ។ ភ្លើងមិនមានឥន្ទ្រិយ ជាពួកមិនមាន

ចេតនា សម្រាប់ធ្វើការងាររបស់ពួកមនុស្ស អ្នកធ្វើបាបកម្មទាំងឡាយកាលបម្រើភ្លើង គប្បីទៅកាន់សុគតិដូចម្ដេចកើត ។ ពួកព្រាហ្មណ៍ជាអ្នកត្រូវការដោយជីវិត ក្នុងលោកនេះ ពោលថា មហាព្រហ្ម ជាអ្នកគ្រប់សង្កត់លោកទាំងអស់ ហើយពោលថា ព្រហ្មជាអ្នកបម្រើភ្លើងដូច្នេះ បើមហាព្រហ្មមាននូវអានុភាពជាងលោកទាំងអស់ មានអំណាចមិនមានអ្នកណាសាង ហេតុអ្វីក៏សំពះភ្លើងដែលខ្លួននិម្មិតវិញ ។ ពាក្យព្រាហ្មណ៍ជាពាក្យគួរសើច មិនគួរដល់ការពិនិត្យ ជាពាក្យមិនពិត ពួកព្រាហ្មណ៍ក្នុងកាលមុន តាក់តែងពាក្យមិនពិត ព្រោះហេតុនៃសក្ការៈ ព្រាហ្មណ៍ទាំងនោះ កាលបើ លាភសក្ការៈមិនកើតឡើងទេ ក៏តនូវសន្តិធម៌ពោលគឺលទ្ធិ របស់ខ្លួនជាមួយនឹងពួកសត្វ ។ ពួកអ្នកប្រសើរ (ព្រាហ្មណ៍) ប្រកាន់ការ រៀនមន្ត ពួកជាធំជាងជន (ក្សត្រិយ៍) ប្រកាន់ផែនដី ពួកវេស្សៈប្រកាន់ ការភ្ជួររាស់ ពួកសូទ្រៈប្រកាន់ការបម្រើផ្សេង ៗ គ្នា សមគួរតាមប្រទេស ជនទាំងឡាយបានពោលថា ត្រកូលទាំង ៤ នេះ ព្រហ្មបានតាក់តែងហើយ ។ ប្រសិនបើពាក្យនុ៎ះ ជាពាក្យពិត ដូចយ៉ាងពាក្យដែល ព្រាហ្មណ៍ទាំងឡាយពោលហើយនេះ បុគ្គលមិនមែនជាក្សត្រិយ៍ មិនត្រូវបានរាជ្យដោយដាច់ខាត បុគ្គលមិនមែនជាព្រាហ្មណ៍ មិនគប្បីសិក្សានូវ

បទនៃមន្ត បុគ្គលរៀនចាកពួកវេស្សៈ មិនគប្បីធ្វើការភ្ជួររាស់ ពួកសូទ្រៈមិន គប្បីរួចអំពីការប្រើនៃជនដទៃ ។ ពាក្យនេះ ជាពាក្យមិនពិត ព្រោះហេតុណា ហេតុនោះ ព្រាហ្មណ៍ទាំងនេះ ពោលពាក្យកុហក ដើម្បីការបំពេញផ្ទៃ បុគ្គលអ្នកមិនមានប្រាជ្ញាទាំងឡាយ រមែងជឿស៊ប់នូវពាក្យនោះ ចំណែកខាងពួកបណ្ឌិត រមែងឃើញហេតុនោះ ដោយខ្លួនឯង ។ ពួកក្សត្រិយ៍នាំយកពលី (ហូតពន្ធ) របស់ពួកវេស្សៈ ពួកព្រាហ្មណ៍កាន់យកគ្រឿងសស្ត្រាទាំងឡាយ ហើយដើរទៅសម្លាប់សត្វ ហេតុអ្វីព្រហ្ម មិនធ្វើលោកដែលជ្រួលជ្រើម បែកខ្ញែកបែបនោះនោះឲ្យត្រង់ ។ ប្រសិនបើព្រហ្មជាឥស្សរៈនោះជាប្រធាន ជាម្ចាស់លើភូត របស់ពួកសត្វក្នុងលោកទាំងអស់ ហេតុអ្វីក៏ចាត់ចែងលោកទាំងអស់ឲ្យមានទុក្ខ ? ហេតុអ្វីមិនធ្វើលោកទាំងអស់ឲ្យបានសេចក្ដីសុខ ? ។ ប្រសិនបើព្រហ្មជាឥស្សរៈនោះ ជាប្រធាន ជាម្ចាស់លើភូតរបស់ពួកសត្វក្នុងលោកទាំងអស់ ហេតុអ្វីក៏ធ្វើលោកឲ្យវិនាស ដោយកលឧបាយនិងការញុំាញី ដោយការពោលពាក្យកុហក ដែលមិនមែនជាធម៌ ។ ប្រសិនបើ ព្រហ្មជាឥស្សរៈនោះ ជាប្រធាន ជាម្ចាស់លើភូតរបស់ពួកសត្វក្នុង លោកទាំងអស់ ម្នាលអរិដ្ឋៈ ព្រហ្មជាម្ចាស់លើភូតមិនប្រកបដោយធម៌ទេ ព្រោះកាលបើធម៌មាន បែរ

ជាចាត់ចែងអធម៌ទៅវិញ ។ បុគ្គលសម្លាប់កណ្តូប កន្ធិរុយ ពស់ កង្កែប ដង្កូវ រុយ ទើបឈ្មោះថា បរិសុទ្ធ ឯធម៌ទាំងនេះ ជាធម៌របស់ពួកជនអ្នកនៅក្នុងដែនកម្ពុជៈដ៏ច្រើន ជាធម៌មានសភាពមិនប្រសើរ ជាធម៌មិនពិត" ។

តទៅនេះ ភូរិទត្តបានបង្ហាញអំពីភាពមិនពិតរបស់ព្រាហ្មណ៍ទាំងឡាយនោះដូច្នេះៈ

"ប្រសិនបើអ្នកសម្លាប់នោះ បរិសុទ្ធ ឬអ្នកដែលត្រូវសម្លាប់នោះទៅកាន់ឋានសួគ៌បាន ពួកព្រាហ្មណ៍គប្បីសម្លាប់ពួកព្រាហ្មណ៍ ឬសម្លាប់ពួកជនអ្នកជឿពាក្យព្រាហ្មណ៍នោះមុន ។ មិនមានពួកម្រឹគ មិនមានពួកសត្វចិញ្ចឹម ពួកគោណាមួយអង្វរឲ្យសម្លាប់ខ្លួនទេ សត្វទាំងឡាយ ក្នុងលោកនេះ សុទ្ធតែញាប់ញ័រត្រូវការដោយជីវិត ព្រោះថា ជនទាំងឡាយ ប្រារព្ធនឹងសម្លាប់សត្វទាំងឡាយនិងសត្វចិញ្ចឹម ក្នុងយញ្ញទាំងឡាយ ។ ពួកបុគ្គលពាល រមែងបើកមាត់និយាយ ដោយហេតុទាំងឡាយដ៏វិចិត្រ ក្នុងការលើកឡើងនូវសសរយញ្ញ និងទីចងនៃសត្វចិញ្ចឹមថា សសរយញ្ញនេះបង្ហូរសេចក្តីប្រាថ្នាដល់អ្នក ក្នុងបរលោក និងឲ្យសេចក្តីទៀងទាត់ក្នុងបរលោក ។ ប្រសិនបើបុគ្គលគប្បីបានកែវ

មណី ស័ង្ខ កែវមុក្តា ស្រូវ ទ្រព្យ ប្រាក់ និងមាស ក្នុងសសរយញ្ញ គប្បីបង្ហូរសេចក្តីប្រាថ្នាគ្រប់យ៉ាង ក្នុងឋានសួគ៌ ពួកជន អ្នកចេះត្រៃវេទដ៏ច្រើនគប្បីបូជា បុគ្គលមិនមែនជាព្រាហ្មណ៍មិនគប្បីបូជាតិចតួចទេ ។ កែវមណី ស័ង្ខ កែវមុក្តា ស្រូវ ទ្រព្យ ប្រាក់ មាស ក្នុងសសរយញ្ញ ក្នុងឈើស្ងួតនិងឈើស្រស់ នឹងមានពីណា សសរយញ្ញនឹងបង្ហូរសេចក្តីប្រាថ្នាគ្រប់យ៉ាងក្នុងឋានសួគ៌ដូចម្តេចកើត ? ពួកព្រាហ្មណ៍ ជាអ្នកបោកប្រាស ជាពួកចិត្តអាក្រក់ ជាពួកពាលប្រលោមលោក តែងបើកមាត់និយាយដោយហេតុដ៏វិចិត្រថា អ្នកឯង ចូរយកភ្លើងចុះ ហើយឲ្យទ្រព្យដល់យើង លំដាប់នោះ អ្នកឯងនឹងបាននូវសេចក្តីគ្រប់យ៉ាង ហើយនឹងដល់នូវសេចក្តីសុខ ។ ពួកព្រាហ្មណ៍ នាំបុគ្គលជា សរណៈ (ព្រះរាជានិងមហាមាត្រ) ចូលទៅកាន់រោង សម្រាប់បូជា ភ្លើងនោះ ក៏បើកមាត់និយាយដោយហេតុដ៏វិចិត្រ ឲ្យកោរសក់ពុក មាត់ កាត់ក្រចក ហើយគាបយកទ្រព្យដោយវេទទាំងឡាយ ។ ពួកព្រាហ្មណ៍ជាអ្នកកុហកដ៏ច្រើន បានទាយកម្នាក់ ហើយក៏ចោមស៊ីបាយ ដូចជាក្អែកទាំងឡាយ ចោមចាប់មៀម ក្នុងទីស្ងាត់ កុហកធ្វើឲ្យរលីង ហើយដាក់ចុះទៅក្នុងផ្លូវនៃយញ្ញ ។ ទាយកតែម្នាក់នោះ ត្រូវពួកព្រាហ្មណ៍បញ្ឆោតហើយដោយអាការយ៉ាងនេះឯង ព្រាហ្មណ៍ទាំងនោះជា

ច្រើន ចោមបូន់ដោយការប្រកបដោយឧបាយ ក៏នាំយកទ្រព្យ ដែលឃើញ ដោយទេវលោកដែលមិនឃើញសោះ ។ ដូចយ៉ាង ពួករាជបុរសដែលព្រះរាជាប្រើទៅហើយ ក៏នាំយកទ្រព្យនោះ របស់គេ ម្នាលអរិដ្ឋ ពួកព្រាហ្មណ៍ប្រាកដដូច្នោះ ប្រហែលនឹង ពួកចោរ ជាអសប្បុរស ជាបុគ្គលគួរសម្លាប់ តែគេមិនសម្លាប់ក្នុង លោក ។ ពួកព្រាហ្មណ៍បានកាត់ដើមចា មកប្រើក្នុងវិធីយញ្ញប្រាប់ ថានេះ ជាដៃស្តាំរបស់ព្រះឥន្ទ្រ បើពាក្យនោះពិត ព្រះឥន្ទ្រទៅជា ដាច់ដៃ ចុះព្រះឥន្ទ្រឈ្នះពួកអសុរ ដោយកម្លាំងដៃដូចម្តេច ។ ពាក្យនោះ ទទេសោះ ព្រះឥន្ទ្រនៅមានដើមដៃគ្រប់គ្រាន់ជា ទេវតាដ៏ប្រសើរ មិនមានអ្នកណាសម្លាប់បាន បានកម្ចាត់ពួក អសុរ មន្តទាំងឡាយនេះ របស់ពួកព្រាហ្មណ៍ មានសភាពជា របស់ទទេ នេះជាការ បញ្ឆោត ដែលគេឃើញច្បាស់ក្នុងលោក ។ ភ្នំមាលាគិរី ១ ភ្នំ ហិមពាន្ត ១ ភ្នំវិជ្ឈៈ ១ ភ្នំសុទស្សនៈ ១ ភ្នំនិសភៈ ១ ភ្នំកាកវេរុ ១ ភ្នំទាំងនុ៎ះក្តី ភ្នំធំ ៗ ឯទៀតក្តី ព្រាហ្មណ៍ទាំងឡាយ ពោលថា ពួកព្រាហណ៍ អ្នកបូជាយញ្ញកសាងហើយដ៏វិចិត្រ ដូច្នោះ ។ ព្រាហ្មណ៍ ទាំងឡាយពោលថា ភ្នំទាំងឡាយដែលពួក ព្រាហ្មណ៍អ្នកបូជាយញ្ញ កាន់យកឥដ្ឋទាំងឡាយ មានបការៈ យ៉ាងណា ធ្វើវិចិត្រហើយ ភ្នំទាំងឡាយមិនមែនមានបការៈដូច្នោះ

ទេ ឯភ្នំទាំងឡាយ មិនដូចរបស់ដទៃទេ ជារបស់មិនកម្រើក ជាថ្មសុទ្ធដែលគេឃើញច្បាស់ ។ ភ្នំទាំងឡាយ មិនមែនជាឥដ្ឋទេ ជាថ្មយូរយារហើយ ដែកមិនមែនកើតក្នុងឥដ្ឋនោះទេ លោហៈក៏មិនមែនកើតក្នុងឥដ្ឋ នោះដែរ ពួកព្រាហ្មណ៍កាលសរសើរនូវយញ្ញនះ បានពោលថា ភ្នំទាំងឡាយ ដែលពួកព្រាហ្មណ៍អ្នកបូជាយញ្ញ ធ្វើវិចិត្រហើយ ។ ព្រាហ្មណ៍ទាំងឡាយ ក្នុងលោកនេះ បានពោលនូវព្រាហ្មណ៍ អ្នករៀនមន្ត្រ បរិបូណ៌ដោយគុណនៃមន្ត្រ មានតបៈថា ជាអ្នកប្រកបដោយការសូម សាគរពន្ទិចព្រាហ្មណ៍នោះ ដែលកំពុង សាចទឹកនៃសមុទ្រលើច្រាំងព្រោះហេតុនោះ បានជាទឹកសមុទ្រ នោះប្រៃ ផឹកមិនបាន ។ ស្ទឹងទាំងឡាយ កួចយកពួកព្រាហ្មណ៍ អ្នកបរិបូណ៌ ដោយវេទបរិបណ៌ដោយមន្ត្រ ច្រើនជាងពាន់នាក់ ទឹកទាំងឡាយមិនខូចរសព្រោះហេតុនោះទេ សមុទ្រមិនមានអ្វីស្មើ មានរសប្រៃផឹកមិនបាន តើព្រោះហេតុអ្វី ? ។ អណ្តូងខ្លះ ក្នុងជីវលោកនេះ មានទឹកប្រៃដែល ពួកជនអ្នកផឹក អណ្តូងបាន ផឹកហើយ ម្នាលអ្នកដឹងរសដោយអណ្តាតទាំងពីរ ជនទាំងឡាយ មិនពោលថា ទឹកក្នុងអណ្តូងទាំងនោះ មានរសប្រៃផឹកមិនបាន ព្រោះតែកួចយកព្រាហ្មណ៍ទេ ។ តាំងពីមុនដំបូងមក ស្ត្រីទាំងឡាយជាភរិយា

របស់បុរសណា មនោបានញ៉ាំងមនុស្សឲ្យ កើតឡើងក្នុងកាលមុន មិនមានអ្នកណាមួយ ថោកទាបជាងគ្នា ដោយធម៌នោះ ព្រាហ្មណ៍ទាំងឡាយបានពោលនូវការចែកវណ្ណៈ ដោយការលះបង់ធម៌នោះ យ៉ាងនេះឯង ។ សូម្បីកូនចណ្ឌាល ជាអ្នកឈ្លាសវៃ មានប្រាជ្ញា បានរៀនវេទទាំងឡាយ ពោលមន្តទាំងឡាយ ក្បាលនៃកូនជនចណ្ឌាលនោះ មិនបែកជា ៧ ភាគទេ មន្តទាំងនេះ ពួកព្រាហ្មណ៍ បានតាក់តែងហើយ ការចង់បាន ពួកព្រាហ្មណ៍ បានតាក់តែងកាន់យកហើយ កើតឡើងតាមគន្លង នៃកាព្យឃ្លោង ដែលគេស្រាយបានដោយក្រ ចិត្តរបស់បុគ្គល ពាលទាំងឡាយ ជឿស៊ប់ក្នុងអំពើមិនស្មើ បុគ្គលឥតប្រាជ្ញា រមែងជឿពាក្យនោះ ។ ព្រាហ្មណ៍មិនប្រកបដោយ កម្លាំងដ៏មាំ ដូចកម្លាំង នៃរាជសីហ៍ ខ្លាំធំ និងខ្លាដំបង មនុស្សភាពរបស់ ព្រាហ្មណ៍ទាំងនោះ ត្រូវយល់ថា ដូចគោដែរ ព្រោះជាតិរបស់ ព្រាហ្មណ៍ទាំងនោះ ស្មើដោយគោ ស្មើដោយសីហៈជាដើម ។ ប្រសិន បើព្រះរាជា ឈ្នះផែនដី ប្រកបដោយអាមាត្យមានអ្នកស្តាប់បង្គាប់ មានបរិស័ទ ព្រះរាជានោះគប្បីឈ្នះពួកសត្រូវដោយ ព្រះអង្គឯង ប្រជាជនរបស់ព្រះរាជានោះ គប្បីបានសេចក្តីសុខ ជានិច្ច ។ មន្តរបស់ក្សត្រិយ៍ និងវេទទាំង ៣ នេះ ស្មើគ្នាដោយអត្ថ

តែក្សត្រិយ៍ក្តី ព្រាហ្មណ៍ ក្តី មិនបានវិនិច្ឆ័យនូវអត្ថនៃមន្ត និងវេទ ទាំងនោះទេ ទាំងមិនដឹងដូច បុគ្គលកាលមិនដឹងផ្លូវ ដែលកំបាំង ដោយទឹក ។ មន្តរបស់ក្សត្រិយ៍និង វេទទាំង ៣ នេះ ស្មើគ្នាដោយ អត្ថ លាភ ឥតលាភ យស និងឥតយសទាំងអស់នេះ ជាធម៌របស់ វណ្ណៈ ទាំង ៤ នោះ ។ ពួកគហបតីជាច្រើន លើផែនដី ញុំាង បុគ្គលឲ្យធ្វើការងារទាំងឡាយ ព្រោះហេតុតែទ្រព្យ និងស្រូវ យ៉ាងណា សូម្បីពួកអ្នកមានត្រៃវេទ ជាច្រើនលើផែនដី ក៏ញុំាង បុគ្គលឲ្យធ្វើការងារទាំងឡាយ ក្នុងថ្ងៃនេះ យ៉ាងនោះដែរ ។ ព្រាហ្មណ៍ទាំងនោះ ស្មើគ្នានឹងគហបតី ព្រាហ្មណ៍ទាំងឡាយ ជាច្រើន លើផែនដី ជាអ្នកខ្វល់ខ្វាយជានិច្ច ប្រកបក្នុងកាមគុណ ទាំងឡាយ តែងញុំាងបុគ្គលឲ្យធ្វើការងារទាំងឡាយ ម្នាលអរិដ្ឋៈ អ្នកដឹងរសដោយអណ្តាតពីរ ព្រោះហេតុនោះ ព្រាហ្មណ៍ទាំង នោះ ជាអ្នកឥតបញ្ញា" ។

## គ្រួសារភូរិទត្តជួបជុំគ្នា

ព្រះមហាសត្តបានបំបែកវាទៈរបស់អរិដ្ឋៈនោះយ៉ាងនេះហើយ ញុំាងវាទៈរបស់ខ្លួនឲ្យតាំងនៅស៊ប់ ។ នាគបរិស័ទទាំងឡាយទាំងពួង លុះស្តាប់នូវធម្មកថារបស់ភូរិទត្តពោធិសត្វហើយ កើតសោមនស្ស

ត្រេកអរ រីករាយ គ្រប់គ្នា ។ ព្រះមហាសត្តបញ្ជាឲ្យគេនាំនូវនេសាទ-ព្រាហ្មណ៍ចេញអំពីភពនាគ ទាំងមិនបានធ្វើការជេរអ្វីដល់គាត់សូម្បីតែមួយម៉ាត់ ។ ចំណែកស្ដេចសាគរព្រហ្មទត្ត មិនរំលងថ្ងៃកំណត់ ទ្រង់បានយាងទៅកាន់លំនៅឋានរបស់ព្រះបិតា ជាមួយនឹងចតុរង្គសេនា ។ ចំណែកភូរិទត្តពោធិសត្វ គិតថា "អញនឹងទៅជួបព្រះមាតុលានិងព្រះអយ្យកោ" ដូច្នេះហើយ បានបង្គាប់ឲ្យគេទូងស្គរជូនដំណឹង ហើយឡើងអំពីទន្លេយមុនា ដោយសិរីសម្បត្តិដ៏ធំលើសលប់ ធ្វើដំណើរឆ្ពោះទៅកាន់អាស្រមបទនោះឯង ។ បងប្អូនប្រុសផ្សេង ៗ និងព្រះមាតាបិតាបានដើរតាមក្រោយភូរិទត្តនោះ ។ ក្នុងខណៈនោះ សាគរព្រហ្មទត្តរាជា មិនចំណាំភូរិទត្តបានសោះ កាលដែលលោកមកដោយមានបរិស័ទជាច្រើន ទ្រង់បានក្រាបទូលសួរព្រះបិតាថា ៖

"ស្គរធំ សម្ភោរ ស័ង្ខ ស្គរជ័យនិងស្គរទ័ព របស់អ្នកណាដែលដើរខាងមុខ ហើយញ៉ាំងព្រះរាជាដ៏ប្រសើរក្នុងរថឲ្យរីករាយ ។ សម្បុរមុខរបស់អ្នកណា ដ៏រុងរឿងដោយដំបារមាសដ៏ក្រាស់ មានពន្លឺដូចផ្លេកបន្ទោរ អ្នកណានៅកំលោះ ប្រដាប់ដោយបំពង់ព្រួញ រុងរឿង ដោយសិរីហើយដើរមក ។ មុខអ្នកណាស្រស់បស់ដូចមាសធ្មិន លើមាត់ជើងក្រាន ឬប្រាកដស្មើដោយរងើកនៃឧសគគីរ អ្នក

ណារុងរឿង ដោយសិរីហើយដើរមក ។ ឆត្ររបស់បុគ្គលណា ជាវិការៈនៃមាសជម្ពូនទ ប្រកបដោយឆ្អឹងជាទីរីករាយនៃចិត្ត ជាគ្រឿងបិទបាំងរស្មីនៃព្រះអាទិត្យ អ្នកណារុងរឿងដោយសិរីហើយដើរមក ។ អង្គអ្នកកាន់ផ្ចិត បានកាន់យកវាលវិជនីដ៏ឧត្តម ខាងលើក្បាលទាំងពីរខាង នៃបុគ្គល មានបញ្ញាដ៏ប្រសើរណា ។ បាច់នៃកន្ទុយក្ងោកដ៏វិចិត្រផង ទន់ផង មានដងជាវិការៈនៃមាសនិងកែវមណី ប្រព្រឹត្តទៅទាំងពីរខាងមុខ របស់បុគ្គលណា ។ កុណ្ឌលទាំងឡាយនេះ ដ៏ល្អមានពន្លឺដូចជាពណ៌រងើក ភ្លើងនៃឧសគគីរដ៏ភ្លឺលើមាត់ដើងក្រាន រមែងរុងរឿងទាំងពីរខាងមុខ របស់បុគ្គលណា ។ សក់របស់បុគ្គលណា មានចុងដ៏ស្និទ្ធ ទន់ ខ្មៅ ត្រូវ ខ្យល់បក់ហើយ ក៏ញុំាងទីបំផុតនៃថ្ងាសឲ្យល្អ ដូចជាផ្ទេកបន្ទោរ ដែលចេញអំពីមេឃ ។ ភ្នែកទាំងនេះវែងធំរបស់អ្នកណា អ្នកមានភ្នែកទូលាយសម មុខនេះរបស់អ្នកណា ភ្លឺថ្លុះដូចកញ្ចក់មាស មាត់នេះរបស់អ្នកណាដ៏ស្អាត ដូចជាស័ង្ខដ៏ប្រសើរ ធ្មេញរបស់បុគ្គលណា កាលនិយាយឡើងដូចជាផ្កាមណ្ឌាក្រពុំ ។ ដៃនិងជើងទាំងឡាយរបស់អ្នកណា ដូចជាទឹកល័ក្ត តាំងនៅក្នុងសេចក្ដីសុខ អ្នកណាមានរឹមបបូរមាត់ ដូចផ្លែបាស ដ៏ល្អដូចជាព្រះអាទិត្យក្នុងវេលាថ្ងៃ ។ អ្នកណាមានសំពត់បាវារៈដ៏សដូចដើមរាំងដ៏ធំមាន

ផ្ការីកហើយ ក្នុងព្រៃហិមពាន្តក្នុងកាល ដែលកន្ទង់ទៅនៃទឹក សន្ទើមល្អដូចព្រះឥន្ទ្រដែលមានជ័យជម្នះ ។ អ្នកណានៅក្នុង បរិស័ទដោះដាវនៅលើស្មា ដែលមានដងដ៏វិចិត្រដោយកែវមណី ដ៏ដេរដាសដោយពកជាវិការៈនៃមាស ។ អ្នកណាដោះស្បែក ជើង ដែលប៉ាក់ដោយមាស វិចិត្រដោយកែវ ៧ ប្រការ ដេរដោយ សូត្រដ៏វិចិត្រ រចនាល្អហើយ ក៏ថ្វាយបង្គំតាបសអ្នកស្វែងរកគុណ ដ៏ធំ" ។

តាបសអ្នកមានឫទ្ធិនិងអភិញ្ញា កាលបើត្រូវស្តេចសាគរព្រហ្ម-ទត្តជាបុត្រសួរយ៉ាងនេះ បានប្រាប់ថា "ម្នាលបុត្រ កូនរបស់ស្តេច ធតរដ្ឋទាំងនេះ ជានាគក្មួយ ៗ របស់អ្នក" និងប្រាប់ថា ៖

"នាគទាំងនោះ ជានាគមានឫទ្ធិ មានយស ជាកូននៃព្រះបាទ ធតរដ្ឋ កើតអំពីនាងសមុទ្ទជា នាគទាំងនេះ សុទ្ធតែជានាគមាន ឫទ្ធិច្រើន" ។

កាលបើជនទាំងនោះ កំពុងនិយាយគ្នាយ៉ាងនេះនៅឡើយ នាគ បរិស័ទទាំងឡាយ បានទៅដល់ថ្វាយបង្គំព្រះបាទារបស់តាបសហើយ អង្គុយក្នុងទីដ៏សមគួរ ។ ចំណែកព្រះនាងសមុទ្ទជា ថ្វាយបង្គំព្រះបិតា

ទ្រង់ព្រះកន្សែងយោបំ ហើយទៅកាន់ភពនាគវិញ ជាមួយនឹងពួកនាគបរិស័ទ ។ ស្តេចសាគរព្រហ្មទត្ត ស្នាក់នៅទីនោះពីរបីថ្ងៃ រួចទ្រង់យាងទៅកាន់ក្រុងពារាណសីវិញ ។ ព្រះនាងសមុទ្ទជា បានសោយព្រះវិលាល័យ ក្នុងភពនាគហ្នឹងឯង ។ ភូរិទត្តពោធិសត្វនៃយើង រក្សាសីលធ្វើឧបោសថកម្មរហូតជីវិត ក្នុងទីបំផុតនៃជីវិត លោកបានទៅញ៉ាំងបុរីសួគ៌ឲ្យកុះករមួយអន្លើដោយបរិស័ទ ។

## ព្រះសាស្តាប្រជុំជាតក

លុះនាំធម្មទេសនានេះមកបរិយាយហើយ ព្រះសាស្តាត្រាស់ថា ៖

> "ម្នាលឧបាសក បុរាណបណ្ឌិត បើទោះបីព្រះពុទ្ធមិនកើតឡើង ក៏លោកលះបង់នូវសម្បត្តិបែបនេះ ធ្វើឧបោសថកម្មបានយ៉ាងនេះ"

ក្នុងកាលចប់នៃទេសនា ឧបាសកទាំងឡាយបាន តាំងនៅស៊ប់ ក្នុងសោតាបត្តិផល ។ ព្រះសាស្តាទ្រង់ប្រជុំជាកតថា ៖

- ព្រះមាតាបិតានៅគ្រានោះ បានមក ជាមហារាជត្រកូល

- នេសាទព្រាហ្មណ៍ បានមកជាទេវទត្ត

- សោមទត្ត បានមកជាអានន្ទ

- នាគីអជមុខី បានមកជាឧប្បលវណ្ណា

- សុទស្សនៈ បានមកជាសារិបុត្រ

- សុភោគៈ បានមកជាមោគ្គល្លាន

- កាណារិដ្ឋៈបានមកជាសុនក្ខត្តៈ

- ចំណែកឯភូរិទត្ត គឺជាតួអង្គអញសម្មាសម្ពុទ្ធនេះឯង។

ភូរិទត្តជាតកវណ្ណនា ទី៦ ចប់ដោយបរិបូណ៌ ៕



នេះកាលព្រាហ្មណ៍អាលម្ពាយនាំព្រះពោធិសត្វ
សម្តែងឫទ្ធិថ្វាយព្រះបាទពារាណសីទត

ISBN 9789996341045

PUC Press